អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jul-2016, 16:00
CMS/CFO: Sann Rada

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅដំណាក់កាលពីរ**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦**

**ម៉ោង ០៩:០០នាទី**

**សវនាការលើកទី៤១៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

កញ្ញា អេវេលីន ខាំផូស សង់ចេស
*(Ms. Evelyn CAMPOS SANCHEZ)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

កញ្ញា សុង ឆវិន្ត

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ *(Mr.Victor KOPPE)*

កញ្ញា ដូរីន ឈិន *(Ms. Doreen CHEN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល | បារាំង |
| លោក រ៉ិចឌ័រ កូប៉េ | អង់គ្លេស |
| លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច (2-TCW-916) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ការ៉ង ហ្គេកអ៊ាវ ហៅ ឌុច** (2-TCW-916)

សួរបន្តដោយលោក ខេល លីសាក់ ផ្តើមពី ............................................................. ទំព័រ ២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:០២]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច។

ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយការណ៍ពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលនឹងត្រូវមកផ្ដល់សក្ខីកម្មនៅថ្ងៃនេះ គឺលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ សូមអរគុណលោកប្រធាន។

[០៩:០១:៣៨]

**ប្រធានអង្គជំនុំ៖**

អរគុណលោក ឯម ហ៊ុយ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងសវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និង

មានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទ នៅ អ.វ.ត.ក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះ និងវិលមុខម្តងម្កាល មិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថា សូមឱ្យអង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់ពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០២:៥៤]

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទនួន ជាអាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម ជាទីគោរពមេធាវី និងភាគីមេធាវីទាំងអស់ ហើយនិងលោក កាំង ហ្កេកអ៊ាវ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ឌេល លីសាក់៖**

**ស៖** កាលពីម្សិលមិញ យើងបានពិភាក្សាគ្នាអំពីការសម្លាប់កូនប្អូននាក់របស់ ថាច់ ជា និងប្រពន្ធរបស់គាត់។ នៅក្នុងបញ្ជីឯកសារ E3/1539 បញ្ជីអ្នកទោសដែលត្រូវបានកាប់សម្លាប់ ដែលខ្ញុំបានបង្ហាញកាលពីម្សិលមិញ គេដាក់នៅក្នុងនោះថា កូនជាកូនរបស់ ថាច់ ជា ក៏ប៉ុន្តែមិនបានរៀបរាប់ឈ្មោះនីមួយៗនោះទេ។ តើលោកអាចជម្រាបតុលាការបានដែរឬទេ ហេតុអ្វីបានជាកូនរបស់ ថាច់ ជា ទាំង

ប្អូនមិនបានសរសេរឈ្មោះច្បាស់លាស់នៅក្នុងបញ្ជីនោះ?

[០៩:០៥:២៩]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា កិច្ចការនេះ គេដំណើរការជាហូរហែមករបៀបហ្នឹង។ បើតាមខ្ញុំសន្និដ្ឋាននៅពេលនេះ គឺកូនរបស់ ចាច់ ជា នេះមិនមានតួនាទីអី ព្រោះខ្ញុំបានឮគេនិយាយប្រាប់ ដូចខ្ញុំបានជម្រាបអង្គជំនុំជម្រះម្សិលមិញហើយ មុនទៅដេកវាៗបឺតមាត់គ្នាសិនបានវាទៅដេក។ ដូច្នេះវានៅក្មេង។ បញ្ជីក្មេងៗ អត់មានទេនៅស-២១។ សូមបញ្ចប់។

**ស៖** សូមអរគុណ។ កាលពីម្សិលមិញ យើងនិយាយផងដែរ ថាតើប្រពន្ធ ចាច់ ជា ត្រូវបានគេសម្លាប់ដោយរបៀបណា គឺតាមរយៈការប្រើប្រាស់ការវះកាត់ទាំងរស់។ ហើយកិច្ចប្រជុំមួយដែលលោក <និង ណាត> ជួបជាមួយនឹង សុន សេន ដែលក្នុងនោះគឺមានការធ្វើស្វ័យទិតៀន ធ្វើការទិតៀនអំពីការប្រព្រឹត្តចំពោះបុគ្គលស្ត្រីរូបនោះ <ដែលជាប្រពន្ធរបស់មនុស្សល្បី>។ ក្នុងអំឡុងពេលដែលលោកធ្វើការជាមួយនឹង នួន ជា ហើយរាយការណ៍ទៅ នួន ជា ថាតើក្រោយពេលនោះមក នៅពេលដែលលោកធ្វើការជាមួយ នួន ជា តើគាត់មាននៅតែអនុវត្តការយកមនុស្សទៅធ្វើការវះកាត់ទាំងរស់ទេ ជាពិសេសយកអ្នកទោសទៅវះកាត់ទាំងរស់នោះ?

**ឆ៖** រឿងកសាងពេទ្យវះកាត់ បើតាមខ្ញុំចាំ ចប់ត្រឹមមួយហ្នឹងឯង អត់មានតទៅទៀតទេ។ ពេលនោះជាពេលចាប់ផ្តើមដំបូងនៃការកសាងពេទ្យរបស់ស-២១។ ដល់ក្រោយពីនោះមកគេអ្នកចាត់-ចែង ដូចៗជាអត់មានការរៀនសូត្រ ដោយយកមនុស្សទៅវះកាត់ទៀតទេ។

**ស៖** ចុះចំពោះការពិសោធន៍ផ្នែកវេជ្ជសាស្ត្រផ្សេងទៀត តើក្រោយមក តើមាន នួន ជា <បានបញ្ជា>លោក<ឲ្យ>យកមនុស្សអ្នកទោសហ្នឹង ទៅធ្វើការពិសោធន៍តាមផ្នែកវេជ្ជសាស្ត្រដោយការប្រើប្រាស់ថ្នាំពេទ្យដែរឬទេ?

[០៩:០៧:១៧]

**ឆ៖** អរគុណ។ រឿងនេះ ខ្ញុំចាំអត់ភ្លេចទេ មាន។ នៅពេលដែលចម្លើយខ្លាំង ឆ្លើយដាក់ថា មានគ្រៀមថ្នាំសម្រាប់សម្លាប់កម្មាភិបាលដឹកនាំ និយាយឲ្យចំគឺ បងប៉ុល។ ដល់ទៅ ខាងមន្ទីរ ខាងអង្គការទៅរើយកផ្ទះអ្នកណាទេ បានថ្នាំបួនគ្រាប់។ ហើយ បង នួន ខ្ចប់នឹងក្រដាសហ្នឹង យកមកហៅខ្ញុំទៅធ្វើការ ហើយឲ្យប្រគល់ថ្នាំហ្នឹងឲ្យ។ ដល់ប្រគល់ថ្នាំឲ្យហ្នឹងទៅ ខ្ញុំយកមកដល់ផ្ទះ ចាក់អាថ្នាំហ្នឹងចោល

កិនប៉ារ៉ាឲ្យល្អិត ហើយដាក់ក្នុងថ្នាំហ្នឹង។ ថ្នាំហ្នឹងជាប្រភេទកាប់ស៊ុល។ រួចដល់ទៅ ខ្ញុំយកទៅឲ្យអ្នកទោសហូប ដោយឲ្យផ្ទាល់ដៃតាមបណ្ដាំរបស់ ពូនួន ប៉ុន្តែវាអត់មានស្អីប៉ារ៉ា វាមានទៅស្អីវា។

**ស៖** នៅពេល នួន ជា ផ្ដល់ថ្នាំបួនគ្រាប់ជូនលោក តើគាត់មានប្រាប់ថា ឲ្យធ្វើយ៉ាងម៉េច យកថ្នាំហ្នឹង នឹងធ្វើយ៉ាងម៉េច? ហើយថ្នាំហ្នឹងសម្រាប់ព្យាបាលអ្វីដែរឬទេ?

**ឆ៖** អរគុណ។ ថ្នាំនោះ មិនមែនជាថ្នាំសម្រាប់ព្យាបាលស្អីទេ។ ថ្នាំនោះ រើតាមចម្លើយខ្មាំងដែលយើងចាប់បាន ហើយឆ្លើយ ថាគេមានត្រៀមថ្នាំសម្រាប់បំពុល ប៉ុល ពត។ រួចដល់ទៅមន្ទីរនេះចេញទៅរើផ្ទះអ្នកទោសដែលឆ្លើយហ្នឹង បានថ្នាំយកមកឲ្យ ពូនួន ហើយ ពូនួន ឲ្យខ្ញុំទៅសាក តើថ្នាំហ្នឹងវាពុលមែន ឬមិនមែន មិនមែនយកព្យាបាលអី ថ្នាំនុ៎ងពុលមែន ឬមិនមែន។ ហ្នឹងនិយាយឲ្យចំប៉ុណ្ណឹង។ តែថ្នាំនោះ វាអត់ពុលទេ ព្រោះខ្ញុំប្ដូររួចបាត់ទៅហើយ។

[០៩:០៩:៤៥]

**ស៖** សូមអរគុណ។ ខ្ញុំទទួលបានចម្លើយច្បាស់ហើយ។ កាលពីម្សិលមិញ យើងក៏បានលើកឡើងអំពីអ្នកទោសដំបូង តើជានរណាខ្លះនៅក្នុងមន្ទីរស-២១នាពេលនោះ។ ខ្ញុំសូមលើកឡើងអ្វីដែលលោកបានលើកឡើងក្នុងពេលដែលលោកឆ្លើយក្នុងការជំនុំជម្រះ ឯកសារE3/5799 ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ<២០០៩> ចន្លោះ០៩:៣១<នាទីព្រឹក>។ នេះជាអ្វីដែលលោកឡើង៖ “ក្នុងពេល<> ខ្ញុំជាអនុប្រធានអ្នកដែលចូលមកស-២១ ភាគច្រើនជាអតីតអ្នកបច្ចេកទេស និងមន្ត្រីរដ្ឋការ។ ក្រោយពេលដែលខ្ញុំក្លាយជាប្រធាន១នៅមន្ទីរនោះ <អតីតមន្ត្រីរាជការដែលគេចាប់បញ្ជូនមកពីជនបទចូលមកមិនសូវញឹកញាប់ទេ។> អ្នកដែលជាអ្នកទោសដំណាក់កាលទី២ គឺភាគច្រើនអ្នកដែលចេញមកពីក្នុងជួរបក្សនៃបក្សកុម្មុយនីស្តកម្ពុជា<>។” <តើត្រឹមត្រូវទេដែលថា> ក្នុងអំឡុងពេលដែលលោកជាអនុប្រធានស-២១ <> អ្នកទោស<ដែលបានចូល ស-២១ ភាគច្រើន>ជា អតីតអ្នកបច្ចេកទេស និងអតីតទាហានមន្ត្រីរដ្ឋការ<លន់ នល់>។ តើលោកមានន័យយ៉ាងម៉េច នៅពេលដែលលោកនិយាយថា ជាអ្នកអតីតបច្ចេកទេស?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ដែលខ្ញុំនិយាយថាអតីតអ្នកបច្ចេកទេសហ្នឹង ខ្ញុំចាំឈ្មោះតិចណាស់ ប៉ុនខ្ញុំចាំមួយ ម្នាក់មកពីរោងចក្រក្រដាស។ ឈ្មោះ អាផាត មិនដឹងស្អី ផាត ទេភ្លេចបាត់ទៅហើយ ហ្នឹងបែបជាកម្មករទេ។ ហើយក្នុងចំណោមនុ៎ង ដូចមានជាវិស្វករម្នាក់ឈ្មោះ លាវ សុតសុភ័ណ្ឌថា។ ហ្នឹងនិយាយនៅពេលដែលខ្ញុំធ្វើជាអនុប្រធាន ហើយចុះទៅសួរផង និងអប់រំផង អប់រំឲ្យ

គេចេះសួរនុំង។ ហើយឯចំណែកពួកទាហាននេះ គឺខ្ញុំនៅចាំម្នាក់ គឺអធិការប៉ូលិសឈ្មោះ ឈិត អ៊ីវ។ ក្រៅពីនោះ ខ្ញុំភ្លេចឈ្មោះអស់ហើយ មិនដឹងជានរណា ជាអ្នកណាខ្លះទេ។

**ស៖** តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ<អ៊ីចឹង> នៅពេលដែលលោកនិយាយថា ជាអតីតអ្នកបច្ចេក-ទេស លោកចង់បានន័យថា អ្នកដែលមានតួនាទីផ្នែកបច្ចេកទេស<នៅក្នុងរបបចាស់> ឧទាហរណ៍ថា ជាវិស្វករជាដើម បានន័យថា អ្នកដែលកាន់តួនាទីខាងបច្ចេកទេស មែនដែរឬទេ?

[០៩:១២:០៨]

**ឆ៖** ជម្រាបប្រសាសន៍ ត្រឹមត្រូវហើយ។

**ស៖** ប្រធានបទមួយទៀត ដែលខ្ញុំសុំឱ្យលោកបញ្ជាក់បំភ្លឺ គឺមុខងារតួនាទីគុកតាខ្មៅ។ នៅដំណាក់កាលដំបូងនៃដំណើរការស-២១ ខ្ញុំលើកឡើងពីដំណាក់កាលខែតុលា ឆ្នាំ៧៥ រហូតដល់ខែមីនា ឬក៏មេសា ឆ្នាំ១៩៧៦ នៅ<មុន>ពេលដែលស-២១ប្តូរទៅសាលា ទីតាំងសាលាទួលស្លែង។ ថាតើកន្លែង<ដែលលោក>នៅ<>ក្នុងទីក្រុងភ្នំពេញនោះ <ផ្ទះ> ឬក៏ប៉េហ្ស៊ីនោះ តើ<ត្រូវបាន>គេយក<ធ្វើ>ជាកន្លែង<សួរចម្លើយទេ ហើយថាតើ>អ្នកទោសដែល<>ជាប់ឃុំខ្លួននៅតាខ្មៅ<មិនត្រូវបានគេសួរចម្លើយ>ទេ<ឬនៅពេលនោះ>?

**ឆ៖** ខ្ញុំជម្រាបប្រសាសន៍លោកប្រធាន ទៅគុកតាខ្មៅហ្នឹង បានតែម្តងគត់ ណាត នាំទៅ។ ហើយទៅឃើញអ្នកទោសម្នាក់ដែលខ្ញុំធ្លាប់ស្គាល់ពីកាលខ្ញុំនៅតំបន់២៥ដូចគ្នានោះ ក្រៅពីនោះខ្ញុំអត់មានបានទៅទៀតទេ។ ហើយព័ត៌មានពីតាខ្មៅយ៉ាងម៉េច ក៏ខ្ញុំអត់បានទទួលការណែនាំបញ្ជាក់ពី ណាត ដែរ ខ្ញុំអត់ក្តាប់បញ្ហើបញ្ហានៅតាខ្មៅអីសោះ។ ដូច្នេះអ្នកដែលយកមកខាងម៉ុំជុំវិញសាលាវិទ្យាល័យពញាយ៉ាតនេះ ជាមនុស្សផ្សេងដែលខ្ញុំឃើញនៅខាងតាខ្មៅ។ នេះខ្ញុំអាចជម្រាបបានប៉ុននុំង ឲ្យច្បាស់ជាងហ្នឹង ខ្ញុំអត់ក្តាប់បានទេ។

**ស៖** ខ្ញុំសូមអានជូនលោក នូវចំណុចដកស្រង់មួយចំនួនចេញពីសក្ខីកម្មរបស់លោកក្នុងពេលលោកឆ្លើយក្នុងពេលការជំនុំជម្រះ។ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ ត្រង់ម៉ោង១៥:២៨ ឯកសារ E3/524។ លោកបានផ្តល់សក្ខីកម្មដូចខាងក្រោម នៅវេលា១៥:២៨នាពេលរសៀល៖ "គុកតាខ្មៅគឺជាគុកធំមួយ ក៏ប៉ុន្តែគុកនៅខាងត្បូងនៃ<សារ>មន្ទីរទួលស្លែង<បច្ចុប្បន្ននេះ>គឺជា<កន្លែងសួរចម្លើយមួយ>។ <បន្តិចក្រោយមក ណាត ប្តូរកន្លែងពីខាងលិចសារមន្ទីរទួលស្លែងបច្ចុប្បន្ននេះទៅទីបញ្ជាការសេនាធិការ ឬសេនាធិកានគរបាល ដែលគេហៅថា ប៉េហ្ស៊ី ប៉ុន្តែវាគ្រាន់តែជា>កន្លែងសួរចម្លើយតែ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ប៉ុណ្ណោះ វាខុសពីគុក<តាខ្មៅ>។"

[០៩:១៦:៣៧]

បន្ទាប់មកនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ឯកសារ E3/5795 នៅថ្ងៃនោះត្រង់ម៉ោង១៥:៣៤ នាពេលរសៀលដដែល លោកបានលើកឡើងថា ខ្ញុំសូមដកស្រង់៖ "ចំពោះគុកតាខ្មៅដំបូង វាជាកម្មសិទ្ធិរបស់កងពល៧០៣ ក្រោយមកវាជាកម្មសិទ្ធិរបស់ស-២១។ ហើយក្រោយមកទៀតគឺក្រោមការក្តោបក្តាប់របស់ខាងក្រសួងសង្គមកិច្ច។"

តើលោកនឹកឃើញទេ? តើលោកចងចាំទេ ក្រោយពីខ្ញុំអាន? <តើត្រឹមត្រូវទេ ដែលថា>អគារ<ដែលលោកបានប្រើ>នៅភ្នំពេញមុនពេលដែលផ្លាស់ប្តូរទៅ<ទួលស្លែង> អគារហ្នឹងគឺប្រើចម្បងបំផុតនោះគឺសម្រាប់សួរចម្លើយតែប៉ុណ្ណោះ ហើយគុកតាខ្មៅ គឺស្ថិតនៅក្រោមការក្តោបក្តាប់របស់ស-២១ <នៅរយៈពេលប៉ុន្មានខែដំបូង> តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ ពាក្យ ស-២១ នេះវាកើតជាផ្លូវការពីថ្ងៃ១៥ ខែសីហា ឆ្នាំ១៩៧៥ នៅពេលដែល សុន សេន ហៅខ្ញុំ និង ណាត ទៅជួប ថាអង្គការចាប់ផ្តើមបង្កើតមន្ទីរសម្ងៃ -- បង្កើតមន្ទីរសន្តិបាលថ្មី ហើយដាក់លេខប៉ុន្មាន ណាត ឆ្លើយថាដាក់លេខ២១ទៅ លេខតេអូ។ រួច សុន សេន ដាក់ថា អើ!អ៊ីចឹងឈ្មោះ "ស" ទៅ។ "ស" ហ្នឹងគឺសន្តិបាល។ ឈ្មោះហ្នឹងវាកើតតាំងពីនុំង។ ដូច្នេះអាមន្ទីរពេទ្យតាខ្មៅដែលខ្ញុំគិតថា អាហ្នឹងជាកម្មសិទ្ធិរបស់ ណាត ពីមុន របស់កងពល៧០៣ពីមុននោះ ដែលខ្ញុំគិតថាលេខ៤៣ ឬលេខ៤៤ ក៏វានៅ វាចូលមករបស់មន្ទីរស-២១ដែរ ក៏ប៉ុន្តែជាក់ស្តែងអ្នកទោសគេដឹកជញ្ជូនយ៉ាងម៉េច ខ្ញុំមិនដឹងទេ។ ប៉ុនខ្ញុំឃើញការដឹកជញ្ជូនពីខាងៗត្បូង ពីខាងត្បូងលីសេពញាយ៉ាតទៅ ប៉េហ្ស៊ី គេដឹកទៅ ហៅខ្ញុំទៅ ហ្នឹងពេលហ្នឹង។

[០៩:១៩:១៧]

ដូច្នេះវាៗច្របូលច្របល់អ៊ីចឹង។ វាទៅជាកម្មសិទ្ធិរបស់ស-២១មែន ក៏ប៉ុន្តែខ្ញុំអត់ដែលបានយកមនុស្សពីនោះយកមកសួរទេ។ ហើយភារកិច្ចខ្ញុំដំបូងកាលនៅជាអនុប្រធាននោះ ក៏មិនមែននេះដែរ មិនមែនគ្រប់គ្រងដឹកនាំរួមអីៗទេ គឺសួរមនុស្សខ្លះ ហើយបង្រៀនគេឲ្យរៀនសួរ បង្រៀនគេឲ្យចេះសួរ។ ឯកសារនៅមានទេ ឯកសារដែលខ្ញុំបង្រៀនទៅមានក្មេងម្នាក់គេកត់ ឈ្មោះ ពូល ផារិក -- ពូល ផល្លី កត់។ ហើយឯកសារហ្នឹងមានតម្កល់ទុកនៅក្នុងសំណុំរឿងស្រាប់។ ដូច្នេះអារឿងសួរគឺអ៊ីចឹង។ អារឿងគុកតាខ្មៅគឺអ៊ីចឹង។ ហើយដល់ក្រោយមកគុកតាខ្មៅនេះ បោះបង់ចោល យកអ្នកទោសចេញអស់ទៅ

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

បោះបង់ចោល ណាត ក៏ចេញទៅបាត់ មកធ្វើជាប្រធាន -- អនុប្រធាន -- ណាត ក៏ចេញទៅនេះបាត់ទៅ ទៅសេនាធិការបាត់ទៅ គុកតាខ្មៅហ្នឹងវាចោលទទេ។ ដល់គុកតាខ្មៅហ្នឹងវាចោលទទេ ដល់ក្រោយមកខាងសង្គមកិច្ចហ្នឹង សុន សេន គាត់តេទៅខ្ញុំ គាត់ថា “មិត្តឌុច អ្ហា! គុកតាខ្មៅខាងសង្គមកិច្ចគេសុំ។ ខ្ញុំថា អត់ទេបង អត់ទាន់ជូនបានទេ ព្រោះអី ព្រោះមានកប់សាកសពខ្លាំងនៅនឹងនុំងច្រើន។ ដូច្នេះបងទុកពេលឲ្យខ្ញុំ ឲ្យរើកកាយយកទៅដុតដាលចោលឲ្យអស់សិន។” រួចដល់ខ្ញុំហៅ មិត្តហ៊ិ មកប្រាប់។ ដល់ហៅមិត្តហ៊ិ មកប្រាប់ មួយសន្ទុះ ប្រហែលជា៧ថ្ងៃ ឬ៣ថ្ងៃអីមិនដឹង មិត្តហ៊ិ មកប្រាប់វិញថា បងខ្ញុំរើដុតអស់ហើយ នៅសល់តែពីរនាក់ ក្រោមទំនប់ដែលយើងមិនអាចទៅកាត់ឆ្កឹះកកាយបាន។ ដូច្នេះខ្ញុំក៏តេទៅបងសុន សេន វិញ ហើយគាត់ក៏ប្រគល់ទៅខាងសង្គមកិច្ចតាមការណែនាំរបស់បក្សទៅ។ នេះតួនាទីរបស់គុកតាខ្មៅ តួនាទីរបស់គុកនៅអគ្គនាយកដ្ឋានប៉ូលិសជាតិ ហើយនិងគុកនៅជុំវិញលីសេពញាយ៉ាតហ្នឹង។ ខ្ញុំសូមបញ្ចប់ប៉ុណ្ណឹង។

[០៩:២១:៤៧]

**ស៖** សូមអរគុណចំពោះការបញ្ជាក់បំភ្លឺរបស់លោក។ ក្នុងអំឡុងពេលចាប់ពីខែតុលា ឆ្នាំ៧៥ រហូតដល់ខែមីនា ឬមេសា ឆ្នាំ៧៦ មុនពេលដែលលោកប្តូរទៅវិទ្យាល័យពញាយ៉ាតនាពេលនោះ តើអ្នកទោសគេយកទៅសម្លាប់នៅទីណា? តើនៅអំឡុងពេលនុំង តើគេមានយកអ្នកទោសទៅតាខ្មៅដើម្បីសម្លាប់ចោលដែរឬទេ?

**ឆ៖** ខ្ញុំមុននឹងឆ្លើយបញ្ហានេះ ខ្ញុំសូមនិយាយអំពីគោលការណ៍ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាបន្តិច។ សមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវដោយឡែក។ ខ្ញុំទទួលការដឹកនាំមែន ក៏ប៉ុន្តែការងារនោះគេទទួលខុសត្រូវជាហូរហែពីមុនមករបស់គេ។ ខ្ញុំអត់បានគិតគូរទេ។ ហើយអាជើងឯកនេះ គេយកពីអង្កាល់ក៏ខ្ញុំអត់ដឹង។ ដល់ក្រោមមកបានដឹងថា ជើងឯកជាកន្លែងសម្រាប់កម្ទេចមនុស្ស។ ហើយដល់ក្រោមកទៀត បានដឹងថា ពេលខ្លះកុនការកម្ទេចមនុស្សនៅជុំវិញផ្ទះនៅស-២១ហ្នឹង។ ដូច្នេះបញ្ហានេះ គឺឲ្យច្បាស់មែនទែន ជាកាលបរិច្ឆេទអីៗ ខ្ញុំអត់ច្បាស់ទេ ព្រោះកិច្ចវាដំណើរការវាទៅអ៊ីចឹង។ ខ្ញុំដឹកនាំរួមមែន តែបុគ្គល គេទទួលខុសត្រូវដោយឡែក។ ហ្នឹងគឺសូមបញ្ជាក់ ជម្រាបប៉ុណ្ណឹង។

[០៩:២៣:៤០]

**ស៖** ដើម្បីបញ្ជាក់ ខ្ញុំឮពាក្យ “ជើងឯក” នៅក្នុងការបកប្រែ គឺខ្ញុំឮជើងឯក ក៏ប៉ុន្តែខ្ញុំលើកឡើងអំពីសម័យមុនជើងឯក។ បានន័យថា មុនពេលដែលប្តូរទៅវិទ្យាល័យពញាយ៉ាតនោះទេ។ នៅពេលនេះ

ខ្ញុំសូមអានសក្ខីកម្មដកស្រង់ចេញមកពីការជំនុំជម្រះ គឺចេញពីថ្ងៃ១៧ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ E3/5801– E3/5801 ត្រង់ម៉ោង០៩:២០នាទី នាពេលព្រឹក។ នេះជាសក្ខីកម្មរបស់លោក៖ "សំណួរ៖ ទីតាំងដែលគណៈស-២១ ជ្រើសរើសសម្រាប់ការសម្លាប់អ្នកទាំងអស់នោះ តើនៅទីណាដែរ? ខ្ញុំសំដៅលើទីតាំងសម្លាប់មនុស្សនិងកប់សព។ ចម្លើយរបស់លោក៖ លោកប្រធាន មានទីតាំងបីធំៗ។ ១) គឺនៅមន្ទីរពេទ្យឆ្កួតនៅតាខ្មៅ យើងកាយយកឆ្អឹងឡើងមក ហើយបន្ទាប់មកយើងដុតឆ្អឹងទាំងអស់នោះ កុំឲ្យនៅសេសសល់។ ទីតាំងទី២ គឺនៅជុំវិញស-២១ ក្នុងទីក្រុងភ្នំពេញដែលគេហៅថា គុកទួលស្លែង។ ហើយទីតាំង<ទី>៣ គឺនៅវាលពិឃាដនៅជើងឯក"។ បញ្ចប់ការដកស្រង់។

តើឲ្យលោកនឹកឃើញវិញទេ? <នៅ>ដំណាក់កាលដំបូងនាពេលនោះ តើលោកដឹងដែរឬទេថា អ្នកទោសនាពេលនោះ គឺត្រូវបានសម្លាប់នៅតាខ្មៅ ក្នុងអំឡុងពេលដំបូង<នោះ ឬក៏នៅដំណាក់>នៃស-២១? តើលោកនៅចាំទេ?

**ឆ៖** ជម្រាបប្រសាសន៍ កាលដែលមាននៅក្នុងកំណត់ហេតុសួរចម្លើយនេះ ឬក៏កំណត់ហេតុនៅសម័យដេញដោលក៏មិនដឹង មិនច្បាស់ទេ ហើយនិងការដែលខ្ញុំបកស្រាយជូនអង្គប្រជុំអំមិញនេះ ខ្ញុំគិតថា អត់ខុសគ្នាទេ។ កន្លែងពិឃាដ ពិតជាមានមួយមែននៅតាខ្មៅ ហ្នឹងហើយបានដែលពេលដែលខាងសង្គមកិច្ចគេសុំខ្ញុំ បងសុន សេន គាត់ទូរស័ព្ទមកខ្ញុំ ហើយខ្ញុំប្រាប់ថា កុំអាលបង ខ្ញុំឲ្យគេកកាយយកទៅបូជា យកទៅដុតឲ្យនេះសិន។ នេះខ្ញុំបានអធិប្បាយអ៊ីចឹង។ ហើយក្រោយមកជុំវិញស-២១ហ្នឹងពេលណាដែលកុនខ្លាំង ដូចខ្ញុំបានជម្រាបអំមិញអ៊ីចឹង កប់ក្បែរៗនុ៎ង។ ដល់វាយ៉ាប់ពេក ខ្ញុំស្នើសុំកំបោរថ្មយកទៅដាក់ពីលើសពហ្នឹង ក្រែងលោកវាមានមេរោគឆ្លងទៅកងការពារងាប់អស់ទៅ។ ពេលនោះខ្ញុំសុំពូនួន។ ហើយបន្ទាប់មកទៀត បាននៅជើងឯក។ ជើងឯកនេះគេប្រើពីអង្កាល់ ខ្ញុំជម្រាបថា ជាក់ស្ដែងខ្ញុំមិនដឹង។ ដល់ខ្ញុំដឹង ចាប់អារម្មណ៍គិត ជើងឯកហ្នឹងគេដំណើរការហើយស្រេច ពីយូរមកហើយ។ ដូច្នេះមិនដឹងពីអង្កាល់ អីពីអង្កាល់ទេ។ បើបញ្ចូលមនុស្សពីនេះ ពីខាងក្រៅទៅក្នុងលីសេពញាយ៉ាត គឺខ្ញុំដឹង។ អាហ្នឹងវាច្បាស់អ៊ីចឹង។ ដូច្នេះវាមានដំណើរពីមុនមក ហើយនិងដំណើរដែលខ្ញុំចាត់ចែង។ ហ្នឹងសូមបញ្ចប់ប៉ុណ្ណេះ។

[០៩:២៧:៣២]

**ស៖** សូមអរគុណ។ យើងនឹងលើកឡើងអំពីជើងឯកនេះ នាពេលក្រោយ។ សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងគុកតាខ្មៅ។ តើនៅពេលណាដែលគេប្ដូរតាខ្មៅនេះទៅក្រសួងសង្គមកិច្ច?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ខ្ញុំមិនចាំថ្ងៃខែច្បាស់ទេ ក៏ប៉ុន្តែគ្រាន់តែសូមបញ្ជាក់ថា មុនពេលដែល បងសុន សេន គាត់អញ្ជើញទៅសមរភូមិមុខ ព្រោះគាត់ និងខ្ញុំនៅទាក់ទងគ្នាតាមទូរស័ព្ទ។

**ស៖** ខ្ញុំសូមលើកឡើងចំណុចដកស្រង់មួយ ទំនងដែលអាចឲ្យលោកចងចាំ គឺ៦ឆ្នាំមុនពេលដែលលោកផ្តល់នូវសក្ខីកម្ម ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ ឯកសារE3/524 ត្រង់ម៉ោង១៥:៤៩នាពេលរសៀល។ លោកបានលើកឡើងថា ខ្ញុំសូមដកស្រង់៖ “គុកតាខ្មៅមានអត្ថិភាពរហូតទៅដល់ខែឧសភា ឬក៏ខែកក្កដា។ ហើយក្រោយមកយើងរៀបចំវិទ្យាល័យពញាយ៉ាត ដើម្បីឃុំខ្លួនអ្នកទោស។”

ហើយ<ប្រាំមួយថ្ងៃ>ក្រោយមកទៀត<គឺ>នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ ពេលដែលលោកផ្តល់សក្ខីកម្មផងដែរនោះ នៅក្នុងឯកសារ E3/5794 ត្រង់ម៉ោង០៩:៤៨ ដល់ម៉ោង០៩:៥៧នាពេលព្រឹក លោកបានលើកឡើងថា៖ “គុកនៅមន្ទីរពេទ្យឆ្កួតតាខ្មៅត្រូវបានប្រើប្រាស់ដោយស-២១ រហូតទៅដល់យ៉ាងហោចណាស់ ក៏ខែមិថុនា ឆ្នាំ៧៦ ដែលក្រោយមកទើបបានប្រគល់ទៅឲ្យក្រសួងសង្គមកិច្ច។” <តើវាធ្វើឲ្យលោកនឹកឃើញឡើងវិញទេ? តើនៅពាក់កណ្តាលឆ្នាំ១៩៧៦ ឬក៏នៅ>ខែឧសភា ឬខែមិថុនា <ឬកក្កដា> ឆ្នាំ៧៦ <>ទើប<ប្រគល់តាខ្មៅ>ទៅក្រសួងសង្គមកិច្ច តើអ៊ីចឹងដែរឬទេ? តើលោកនឹកឃើញទេ?

[០៩:៣០:០៩]

**ឆ៖** ជម្រាបប្រសាសន៍ រឿងលទ្ធភាពបញ្ចប់ពន្ធនាគារតាខ្មៅនេះ ប្រហែលជាក្នុងនុ៎ងមែន។ ខ្ញុំវិភាគនេះ ខ្ញុំសន្និដ្ឋានទៅតាមការដែល ណាត គាត់ចេញទៅ។ ណាត គាត់ចេញទៅនេះ គាត់នៅមានលទ្ធភាពមកដឹកនាំមិត្ត ហ៊ី ឲ្យមកបង្ហើយការងារចាស់។ ហ្នឹងហើយបាន១ខ្ញុំកំណត់ថា ប្រហែលជាខែមិថុនា បានចប់។ នេះជាការសន្និដ្ឋានសុទ្ធសាធ។ ហើយគុកតាខ្មៅនោះ ក៏នៅទំនេររហូតមក ហើយមានផ្ទះមួយចំនួននៅតាខ្មៅនេះ ក៏នៅជាកម្មសិទ្ធិរបស់ស-២១ដែរ។ ហើយដល់ក្រោយមក បានប្រគល់អាគុកតាខ្មៅនេះទៅជូនសង្គមកិច្ច។ ដូច្នេះមាននៅ អាគុកហ្នឹងវានៅចោលទទេ មួយរយៈ។ ហើយដល់ប្រគល់ទៅឲ្យក្រសួងសង្គមកិច្ច ខ្ញុំអត់ចាំថ្ងៃខែច្បាស់ទេ គ្រាន់តែដូចខ្ញុំបានជម្រាបលោកព្រះរាជអាជ្ញាអំមិញអ៊ីចឹង មុន គឺពិតជាមុនពេលដែលបង សុន សេន គាត់អញ្ជើញទៅសមរភូមិមុខ។ ដូច្នេះយកពេលកំណត់ហ្នឹង វាច្បាស់ជាង។ នេះសុទ្ធតែជាការសន្និដ្ឋានទាំងអស់។

**ស៖** តើ ហ៊ី គាត់ឈរជើងនៅគុកតាខ្មៅឬ? បើដូច្នេះមែន តើគាត់ចាប់ផ្តើមចាកចេញពីគុក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តាខ្មៅ ហើយមកចាប់ផ្តើមមកធ្វើការជាមួយនឹងលោក នៅស-២១នេះ នៅពេលណាដែរ?

**ឆ៖** មុនតែងតាំងខ្ញុំជាអនុប្រធាននេះ ហ៊ា នៅជាប់ជាមួយ ណាត គឺនៅកាន់កាប់កិច្ចការនៅភ្នំពេញ។ អាគុកតាខ្មៅហ្នឹង មិនដឹងមិត្តណាកាន់កាប់ទេ។ ដូចឃើញមានឯកសារមួយ ដូចឈ្មោះ មិត្ត ហ៊ុន។ ដូច្នេះ ហ៊ា អត់នៅនឹងតាខ្មៅហ្នឹងជាប់លាប់ទេ។ ហ៊ា ដូចខ្ញុំជម្រាបលោកព្រះរាជអាជ្ញាម្សិលមិញអ៊ីចឹង ពេលដែលខ្ញុំទៅឃើញ សោ ភន នោះ ហ៊ា គាត់នៅអង្គុយខាងក្រៅលើជើងម៉ាមួយ អានចម្លើយអ្នកទោស នៅខាងក្រៅគុក នៅខាងក្រៅនេះ។ ហើយសូមបញ្ជាក់ថា ខ្ញុំឃើញ ហ៊ា ខ្ញុំស្គាល់ ព្រោះខ្ញុំនិង ហ៊ា ធ្លាប់ជាប់គុកសម័យ លន់ នល់ -- អ៎ សម័យសីហនុជាមួយគ្នា មុនរដ្ឋប្រហារជាមួយគ្នា នៅព្រៃស។ ដូច្នេះខ្ញុំឃើញ ខ្ញុំស្គាល់ ប៉ុន្តែវាមាន អត់ទាន់មានការអីនិយាយជាមួយគ្នា។ ដូច្នេះ ហ៊ា សរុបមក ហ៊ា នៅជាប់ជាមួយ ណាត រហូត។ ការចាត់តាំងកន្លងមកហ្នឹងគឺ ណាត ហើយ ហ៊ា។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតផ្តល់ឯកសារពីរជូនទៅឲ្យសាក្សីមើល គឺឯកសារ E3/3187ៗ និងឯកសារ E3/2017 – E3/2017។

[០៩:៣៣:២៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំបានប្រគល់ឯកសារពីរទៅឲ្យលោកមើល គឺទី១ E3/3187 គឺ<បញ្ជី> មានចំណងជើងថា “គុកយោធា” ដែលមានអតីតកងទ័ពទាហានលន់ នល់ ៤៩នាក់ ដែលយកមកពីទីកន្លែងផ្សេងៗ គឺតំបន់១៥ និង២៥ <និងកន្លែងមួយ គឺ>នៅភូមិតាឡី ដែលត្រូវបានបញ្ជូនមកស-២១ នៅចន្លោះ<ខែ> មិថុនា និង<ខែ> កញ្ញា ១៩៧៦។ ERN សម្រាប់ឯកសារនេះ សម្រាប់ប្រតិចារឹក ខ្មែរ គឺ 00008785 ដល់86, អង់គ្លេស 00874237 ដល់41 មិនទាន់មានការបកប្រែជាភាសាបារាំងនៅឡើយទេ។ បញ្ជីដំបូងនេះ គឺថាមានចំណារសរសេរដោយដៃ បើលោកមើលទំព័រទី១។ ហើយបន្ទាត់បញ្ចប់ពីឈ្មោះអ្នកទោស ហ្នឹងលោកឃើញមានចំណារសរសេរដោយដៃហើយ ដោយមានទាំងកាលបរិច្ឆេទផងដែរ។ តើលោកស្គាល់ទេ ចាំទេថាចំណារដែលសរសេរដោយដៃនេះ ជាចំណាររបស់អ្នកណាដែរ? <តើវាមានន័យយ៉ាងម៉េច?>

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍ ចំណារនេះ ខ្ញុំអត់ច្បាស់ទេ។ ម្ចាស់ៗអក្សរខ្ញុំអត់ច្បាស់ទេ មិនដឹងថារបស់ មិត្តហ៊ី ក៏ដូចជាមិនមែន។

[០៩:៣៦:១៩]

**ស៖** ហើយសូមលោកពិនិត្យមើលឯកសារទី២ គឺឯកសារ E3/2017, ERN ខ្មែរ 00021137, អង់គ្លេស 00183670 ដល់672។ នេះជាបញ្ជីអ្នកទោសដែលយកមកពីតាឡី។ សូមទោស ខ្លាចក្រែងខ្ញុំអានឈ្មោះភូមិនេះមិនច្បាស់ ប៉ុន្តែនេះគឺជាបញ្ជីអ្នកទោសនៃអតីតទាហាន លន់ នល់ ៣១នាក់ ដែល <បានមកដល់>នៅចុងខែសីហា ឆ្នាំ១៩៧៦ ហើយអ្នកទាំងអស់នេះបានស្លាប់អស់ហើយ។ តើលោកអាចជម្រាបជូនតុលាការបានទេ ថាភូមិតាឡីនេះនៅកន្លែងណាដែរ? ហើយថាហេតុអ្វីបានជាអតីតទាហាន លន់ នល់ ត្រូវបានបញ្ជូនពីភូមិតាឡីនេះមកកាន់ស-២១ នៅខែសីហា ឆ្នាំ១៩៧៦?

**ឆ៖** ជម្រាបប្រសាសន៍ ភូមិតាឡីនេះខ្ញុំអត់ដឹងនៅត្រង់ណាទេ មិនដែលបានទៅអើត។

**ស៖** ខ្ញុំសូមចូលទៅប្រធានបទបន្ទាប់របស់ខ្ញុំ ពាក់ព័ន្ធនឹងអ្វីដែលលោកបានលើកឡើងកាលពីម្សិលមិញ គឺក្មេងៗ <និង>ប្រពន្ធរបស់អ្នកទោសដែលត្រូវបានគេបញ្ជូនមកស-២១។ លោកក៏បានលើកឡើងពីម្សិលមិញដែរហើយ ពាក់ព័ន្ធទៅនឹងកូនរបស់ <ថាច់> ជា។ តើលោកអាចជម្រាបជូនតុលាការជាទូទៅសិនបានទេ ថាមានអ្វីកើតឡើងទៅដល់កូនៗ និងប្រពន្ធរបស់អ្នកដែលត្រូវបានគេបញ្ជូនទៅស-២១ ហើយត្រូវបានគេចោទថា ជាខ្មាំងដែលចេញពីរបបនោះ និងជាគិញផង? តើមានអ្វីកើតឡើងទៅដល់ជោគវាសនារបស់កូនៗ និងប្រពន្ធរបស់អ្នកទាំងនោះ?

**ឆ៖** ជម្រាបប្រសាសន៍ ខ្ញុំសូមបញ្ជាក់បន្តិច តាជា ណា? ខ្ញុំសូមបញ្ជាក់។ លោកព្រះរាជអាជ្ញាអានអំមិញកូនចៅ តាជា តើ តាជា ណា? ខ្ញុំអត់ស្តាប់បានទេ ឈ្មោះហ្នឹង។

**ស៖** គឺ ថាច់ ជា លោកសាក្សី។ ម្សិលមិញលោកបាននិយាយថា ហេតុអ្វីបានជាកូនៗរបស់គាត់ត្រូវបានចាប់ខ្លួន។ សំណួរខ្ញុំជាទូទៅសិនទេ ថានៅក្នុងពេលដែលលោកធ្វើការនៅស-២១នោះ តើមានអ្វីកើតឡើងទៅដល់កូនៗ និងប្រពន្ធរបស់អ្នកដែលគេបញ្ជូនទៅស-២១ ដែលត្រូវបានគេចោទថាជាខ្មាំងនោះ?

[០៩:៤០:០៣]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា កូននិងប្រពន្ធអ្នកដែលមានទោស គេចាត់ទុកដូច

អ្នកមានទោសអ៊ីចឹង ត្រូវតែកម្ទេច។ បើមិនមានសារៈសំខាន់អីចាំបាច់សម្រាប់សួរចម្លើយទេ គេកម្ទេចហើយ។ កុំថាតែកូន ចាច់ ជា ដែលគាត់ធ្វើជារដ្ឋមន្ត្រីរបស់ លន់ នល់ សូម្បីតែកូនបងវន តួនាទី វន វ៉េត មិនស្មើរទេ ជាអចិន្ត្រៃយ៍មជ្ឈិមបក្ស ជាឧបនាយករដ្ឋមន្ត្រី។ នៅពេលដែលគេចាប់ បងវន, បងវិន ក៏គេចាប់។ ហើយបើតាមខ្ញុំចាំ គឺអាភេន អត់ចូលទៅដល់ស-២១ទេ។ អាភេន នេះជាកូនរបស់ បងវន បក្សបញ្ជូនឲ្យទៅរៀននៅចិន ខាងប្រដេញ យន្តហោះប្រដេញ។ ដូច្នេះ អាភេន ប្រហែលជាខាងមិត្ត ប៉ង់ គេសម្រេចយកទៅកម្ទេចនៅខាងរបស់គេហើយ។ ដូច្នេះកាលណាបើគេចាប់ឪពុកហើយ គឺគេចាប់កូននិងប្រពន្ធហើយ។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេ ថាតើលោកបានទទួលការណែនាំពីមេរបស់លោក ឬក៏យ៉ាងណា? តើការអនុវត្តការចាប់ខ្លួន និងការកម្ទេចកូនៗនិងប្រពន្ធរបស់អ្នកទោសហ្នឹង វាកើតមានឡើងពីពេលណាមកដែរ? សុំទោស ខ្ញុំសួរ ថាតើលោកមានទទួលការបង្គាប់បញ្ជាពីថ្នាក់លើមកដែរឬក៏យ៉ាងណា? <ថាតើលោកបានពិភាក្សាជាមួយមេរបស់លោកអំពីបញ្ហានេះទេ?> ហើយថាតើគោលការណ៍នៃការចាប់ខ្លួនកូនៗនិងប្រពន្ធហ្នឹង វាចេញមកដោយរបៀបណាដែរ?

[០៩:៤២:១៦]

**ឆ៖** គោលការណ៍នេះ បើតាមខ្ញុំចាំ គឺអនុវត្តវាទៅជារបៀបស្វ័យប្រវត្តិ ក្រោយ១៧មេសា។ ពីមុនមក ខ្ញុំធ្លាប់បានទទួលក្មេងៗដែរ នៅម-១៣។ ខំសាកល្បងចិញ្ចឹមខ្លះ តែវាមិនរស់។ ពេលនោះយើងអត់ទាន់មានគោលការណ៍មួយកម្ទេចកូនៗទេ។

**ស៖** លោកប្រាកដទេ បញ្ហានេះ? តើ<មាន>កូនៗ<>នៅម-១៣នោះ <>លោក<ចង់ជួយសង្គ្រោះជីវិត ប៉ុន្តែមិន>អាចជួយសង្គ្រោះបាន<អ៊ីចឹងមែន>ទេ? តើលោកនៅចាំទេ ថាមានព្រឹត្តិការណ៍មួយកើតឡើងនៅម-១៣ ដែលគេតម្រូវឲ្យលោកសម្លាប់ក្មេងៗ ក្មេងៗទាំងនោះ តើលោកនៅចាំទេ?

**ឆ៖** អ្នកដែលសង្គ្រោះបាន មាន។ ទី១ គឺកូននិងប្រពន្ធមេស្រុក ភឿង។ ដល់ក្រោយមកត្រូវបញ្ជូនទៅខាងពោធិ៍សាត់។ ហើយតាមសក្ខីកម្មរបស់ បងស៊ន នៅភូមិព្រែក ទៅជួបនិយាយនុ៎ងឯខាងពោធិ៍សាត់នុ៎ង ហើយត្រឡប់មកអមលាំងវិញជាមួយគ្នា។ ដូច្នេះកូនរបស់មេស្រុក ភឿង ពីរនាក់នៅរស់ ប្រពន្ធមេស្រុក ភឿង ក៏រស់ដែរ ហើយប្រហែលជា អាគ្រែក នៅភូមិយាយអង្គ ក៏ប្រហែលជារស់ដែរ។ នេះ គឺវាជាបញ្ហាមួយ។ ឯចំណែកព្រឹត្តិការណ៍មួយផ្សេងទៀត គឺខ្ញុំបានសង្គ្រោះក្មេងម្នាក់ដែលចាប់ដំបូងពេលដែលខ្ញុំទៅទទួលធ្វើប្រធានមន្ទីរ១៣ហ្នឹង គេចាប់ចាមពីផ្សារសំរោង ឈ្មោះ តាឡឹប ទៅ វាដោយ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក្មេងម្នាក់ ឈ្មោះស៊ីទេ។ ដល់ក្រោយមកខ្ញុំក៏បញ្ជូនឲ្យទៅនៅនឹងមន្ទីរឃុំអមលាំង។ ហើយចំណែកឯដែលខ្ញុំសាកល្បងចិញ្ចឹមនោះ គឺមានកូនអា សូ អ៊ុន នេះមួយ។ ឯចំណែកអ្នកដែលគេតម្រូវឲ្យសម្លាប់នោះខ្ញុំមិនចាំ។ គ្រាន់តែនឹកឃើញថា មានពេលមួយនោះហ្នឹង គេឲ្យសម្លាប់ប្រពន្ធទាហាន ដែលចូលទៅគេចាត់ទុកថា ចូលទៅយកការណ៍នោះ ប្រពន្ធពួកទាហានអង់តាឡឹកនោះ ក្នុងនោះមានមនុស្សម្នាក់ផើម។

[០៩:៤៥:៣៩]

**ស៖** ខ្ញុំសូមអានឲ្យលោកស្តាប់នូវកំណត់ហេតុស្តាប់ចម្លើយដែលលោកបានឆ្លើយ គឺឯកសារ E3/5752 – E3/5752។ ឯកសារនេះពាក់ព័ន្ធទៅនឹងមនុស្សម្នាក់ដែលលោកទើបតែលើកឈ្មោះយកមកនិយាយ <គឺឈ្មោះ សង់ អ៊ុន>។ សូមដកស្រង់៖ "នៅពេលដែលខ្ញុំនៅម-១៣ ខ្ញុំព្យាយាមជួយសង្គ្រោះក្មេងបីនាក់របស់ <សង់ អ៊ុន> ប៉ុន្តែដោយសារតែយើងមិនអាចជួយចិញ្ចឹម និងឲ្យគេរស់រានមានជីវិតបាន ហើយគឺគេខ្លាចថា ក្មេងៗទាំងនេះមានការសងសឹក ជាពិសេសគឺក្រោយការទទួលយោបល់ពីលោកគ្រូ សុន សេន។ ភាសារបស់កុម្មុយនីស្ត គឺបក្សកុម្មុនីស្តកម្ពុជានេះឯង គេ<បានហៅ>ជំហរ<ខ្ញុំ>ថា <ការទុកឲ្យក្មេងៗនៅរស់ ជា>ជំហរ<ដែលខ្វះកំហឹង>វណ្ណៈ<>។ ក្រោយពីមានការបង្កើតស-២១ ខ្ញុំក៏អនុញ្ញាតឲ្យពួកគេធ្វើយ៉ាងដូច្នេះ។" បញ្ចប់ការដក ស្រង់។

នៅក្នុងកំណត់ហេតុស្តាប់ចម្លើយដែលមានចំណងជើងថា "ក្មេងៗនៅស-២១" គឺឯកសារ E3/5758 – E3/5758 កថាខណ្ឌ២(ក) ដែលនិយាយអំពីគោលបំណងរបស់លោក <ដែល>មិនបានជោគជ័យនៅក្នុងការជួយរក្សាក្មេងបីនាក់ <លោកនិយាយថា "ឆ្លៀត>ឱកាស<ដែលខ្ញុំបរាជ័យក្នុងការជួយ>សង្គ្រោះជីវិតរបស់ក្មេង<ៗ>នោះ<> សុន សេន បានផ្តល់ការណែនាំជាបន្ទាប់មកទៀត ថា<> យើងត្រូវតែមានជំហររឹងប៉ឹង។" បញ្ចប់ការដកស្រង់។ អ្វីដែលខ្ញុំចង់ឲ្យលោកបញ្ជាក់ជូនអង្គជំនុំជម្រះនាពេលនេះ ថាតើលោកចាំថា សុន សេន នេះនិយាយថាម៉េច ណែនាំថាម៉េច ពាក់ព័ន្ធទៅនឹងការសម្លាប់កូនក្មេង? ហើយជាពិសេសនិយាយអំពីជំហរ ត្រូវតែមានជំហររឹងមាំហ្នឹង តើជំហរហ្នឹងសំដៅលើអ្វី?

[០៩:៤៨:២៩]

**ឆ៖** ខ្ញុំជាមួយនឹងបង សុន សេន មានការទាក់ទងគ្នាស្ទើរតែរាល់ថ្ងៃ អ្ហែ!ស្ទើរអី រាល់ថ្ងៃតែម្តងលស់ថ្ងៃតិចណាស់។ នៅនឹងផ្ទះខ្ញុំមានទូរស័ព្ទពិសេសមួយ ពេលណាគាត់ចង់និយាយ ជាពិសេសល្ងាចប្រហែលជាម៉ោងបីម៉ោងបួននោះ ខ្ញុំដើរទៅណាអត់រួចទេ។ គាត់ហៅមក គាត់សួរសព្វគ្រប់ អាណា

ឆ្លើយយ៉ាងម៉េច ដល់ណាហើយ អាណាយ៉ាងម៉េចអី ទាំងអស់ ហើយគាត់ណែនាំ។ ដូច្នេះរឿងរ៉ាវដែលគាត់ណែនាំច្រើន។ ហ្នឹងជម្រាបដោយត្រង់ចុះ។ ទូរសព្ទហ្នឹងពិសេស នៅត្រង់ដែលថា ហៅឮទៅ ចុចប៊ូតុងមួយទៅ វាវ៉ៃប្រេ្វកង់ឲ្យទៅជាផ្សេង។ អ្នកផ្សេងទៀតយកម្ហូលខ្ទាស់ ទៅខ្ទាស់តាមខ្សែនុំង ស្តាប់អត់ឮទេ វាទៅប្រេ្វកង់ផ្សេងហើយ។ ដូច្នេះដែលហៅពិសេសគឺហ្នឹង។ ដូច្នេះខ្ញុំហើយជាមួយនឹងលោកគ្រូ សុន សេន និយាយគ្នាហូរហែ ពីជំហររឿងមួយទៅរឿងមួយ រឿងមួយទៅរឿងមួយ រឿងមួយទៅរឿងមួយ។ ដូច្នេះអាចមិនមែនដូចខ្ញុំនេះទេ អើ! រឿងវាយូរហើយ លំបាកនេះដែរ។ អំមិញខ្ញុំថាការអនុវត្តហ្នឹងវាទៅជាស្វ័យប្រវត្តិទៅហើយ។ រួចដល់អំមិញហ្នឹង បានឯកសារទៅ បានឃើញរឿងហ្នឹង។ ដូច្នេះកាលនោះ ខ្ញុំអាចនៅថ្មី ហើយនៅចាំរឿងច្បាស់ជាង។ ហ្នឹងសូមបញ្ជាក់ប៉ុណ្ណឹង។ រឿងអីក៏ដោយ យើងមិនដែលធ្វើរំលងបក្សទេ ព្រោះ -- ហើយជាក់ស្តែងដូចជារឿងសម័យចាប់ បងវន មក។ មិត្តណយ ក៏ចាប់មកដែរ កូនប្រសារ បងវន។ មិត្តណយ ណ៎ា! ប្រធានរោងចក្រស្ពដែកនៅនេះ លេខប៉ុន្មានទេ ចាប់។ ដូច្នេះតែមេគ្រួសារទៅហើយ នេះទៅទាំងអស់។ ដូច្នេះខ្ញុំសូមបញ្ចប់បញ្ហានេះត្រឹមប៉ុណ្ណេះ។

**ស៖** ខ្ញុំសូមឲ្យលោកនិយាយដោយសាមញ្ញៗ តើការដែលសម្លាប់កូនក្មេងៗ និងប្រពន្ធអ្នកទោសហ្នឹង គឺជាគំនិតផ្តួចផ្តើមរបស់លោក ឬក៏លោកទទួលការបង្គាប់បញ្ជាពី សុន សេន?

[០៩:៥១:០៩]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់សាក្សី!

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** តែគេចាប់ប្តីហើយ គេចាប់ប្រពន្ធបញ្ជូនមក។ ដូច្នេះតួនាទីរបស់ស-២១ ក៏ដូចប្រហែលជាសម្រាប់មន្ទីរសន្តិបាលទូទាំងប្រទេស តែប្តីគេចាប់ហើយ ប្រពន្ធក៏មកដែរ នេះគឺអ៊ីចឹង។ ដូចខ្ញុំបានលើកឧទាហរណ៍មួយអំមិញ ហើយជូនឧទាហរណ៍មួយទៀតជាក់ស្តែង។ មានកុមារម្នាក់ដែលកាលនោះនៅជាកុមារឈ្មោះ នង ចាន់ផល។ ខ្ញុំចាំច្បាស់ថាខាង តាម៉ុក មិនដែលបញ្ជូនកម្មាភិបាលមកឲ្យស-២១ទេ។ ដល់ទៅ នង ចាន់ផល មក គាត់ធ្វើសក្ខីកម្ម ខ្ញុំឆ្ងល់។ ដល់ទៅឃើញសាលាកប័ត្រដែលគេកត់ពីម្តាយគាត់នោះ បាន១ថា អ៎មែន។ ពេលនោះឪពុក និងម្តាយ នង ចាន់ផល គេបញ្ជូនចេញពីនិរតីមកនេះ។ ដូច្នេះគេចាប់ឪហើយ គេចាប់ម៉ែ គេចាប់ទាំង នង ចាន់ផល មកទៀត។ នេះជាគោលការណ៍ដែលគេអនុវត្ត។ គេៗអ្នកចាប់ប្រគល់មកឲ្យស-២១ មិនមែនស-២១ដើរតែចាប់ខ្លួនឯងសេរីទេ ដើរទៅចាប់ខ្លួន

ឯងកំបុតក អាប្រធានស-២១ហ្នឹងហើយ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ឥឡូវយើងចូលនិយាយអំពីក្មេងៗបីនាក់របស់ <សង់ អ៊ុន> នៅម-១៣។ តើឈ្មោះ <សង់ អ៊ុន> នេះជាអ្នកណាដែរលោក?

[០៩:៥៣:០៥]

**ឆ៖** ឈ្មោះវាអាស្អី សាំង អ៊ុន ទេ។ អានោះដូចជាទាហាន ឬក៏ជនជម្លៀសពីឧដុង្គ មិនដឹងខ្ញុំភ្លេចបាត់ទៅហើយ។ ប៉ុន្តែមិនមែនជានេះទេ មិនមែនជាផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជាទេ ឬក៏ទាហានចាស់ ឬក៏ជាជនជម្លៀសពីឧដុង្គ។

**ស៖** ទាក់ទងទៅនឹងក្មេងៗទាំងបីនាក់នេះ តើលោកចាំថា សុន សេន មាននិយាយអ្វីទៅប្រាប់លោកទេ ត្រូវចាត់ការយ៉ាងម៉េចទៅលើកូនៗទាំងបីនាក់របស់ <សង់> អ៊ុន នេះដែរទេ?

**ឆ៖** អរគុណ។ ខ្ញុំរំឭករឿងនេះឃើញខ្លះឡើងវិញហើយ។ ដល់ក្រោយមកនៅពេលដែលចិញ្ចឹមក្មេងនោះ ខ្ញុំ ព្រោះវាចិញ្ចឹមមិនរស់ បានៗខ្ញុំសរុបជូនបង សុន សេន ម្តង។ ខ្ញុំថាការចិញ្ចឹមក្មេងរបស់អ្នកទោសមិនរស់ទេ ពិបាកណាស់ ព្រោះវាគ្មានមនោសញ្ចេតនា ឲ្យអ្នកណាចិញ្ចឹមក៏ពិបាកដែរ យើងចិញ្ចឹមក្មេងត្រូវមានមនោសញ្ចេតនាជាមួយនឹងក្មេងផង។ ហើយក្នុងសភាពការណ៍ដែលអត់បាយហូបចុកអីនេះ នៅពេលហ្នឹងហើយដែលពេលរាយការណ៍ហ្នឹងហើយ ដែលបងសុន សេន គាត់ណែនាំថាយើងត្រូវដាច់ខាត ជំហរវណ្ណៈរបស់យើងគឺត្រូវដាច់ខាត ច្បាស់លាស់ បែងចែកឲ្យច្បាស់រវាងខ្មាំង និងមិត្ត។ ដូច្នេះខ្ញុំ ជាការពុះពាររបស់ខ្ញុំ ដើម្បីនឹងសង្គ្រោះក្មេងៗទេ ប៉ុន្តែវាទៅមិនរួច។ តាមពិសោធន៍ពេលនុ៎ង គឺខ្ញុំសន្និតថាចិញ្ចឹមមនុស្ស ចិញ្ចឹមទារក ចិញ្ចឹមកុមារ ត្រូវមានមនោសញ្ចេតនាបានរស់។ មិនមែនគ្រាន់តែការហូបចុកទេ។ បើប្រៀបអាក្មេងៗប៉ុន្មាននាក់កូន អាសាំង អ៊ុន នោះ ជាមួយនឹងកូនបង ម៉ម ណៃ កូនបង ម៉ម ណៃ គេរីកចម្រើនល្អលាស់ទៅ យ៉ាងសប្បាយរីករាយ ម៉ែគេក៏នៅនឹងនុ៎ង ឪគេក៏នៅនឹងនុ៎ង។ ឯចំណែកកូន អាសាំង អ៊ុន ស្លាប់អស់។ នេះការពិសោធន៍របស់ខ្ញុំដែលចង់សង្គ្រោះក្មេង។ ហើយដល់ក្រោយមក ខ្ញុំរាយការណ៍បញ្ហាហ្នឹងជូនមេ ជូនបងសុន សេន។ ដល់ទៅបងសុន សេន ថាអើ ឌុច ឯងមានពិសោធន៍ហើយ យើងត្រូវច្បាស់លាស់ខាងមាគ៌ាវណ្ណៈ ខាងជំហរវណ្ណៈរបស់បក្ស បែងចែកឲ្យច្បាស់រវាងខ្មាំង ហើយនិងយើង។ គាត់និយាយអ៊ីចឹង។ ហ្នឹងសូមចប់ប៉ុណ្ណឹង។

[០៩:៥៦:០៦]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើហេតុផលអ្វីដែលនាំឲ្យបក្សប្រកាន់នូវជំហរបែបនេះ ឈានទៅដល់ការសម្លាប់ក្មេងៗ និងប្រពន្ធៗរបស់អ្នកដែលត្រូវបានចាប់ខ្លួន? តើមូលហេតុអីដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី វិចទ័រ កូប៉េ!

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ។ យើងកំពុងនិយាយគ្នាអំពី សុន សេន។ តាមដែលខ្ញុំចាំ ឥឡូវនេះ ងាកចេញពីសុន សេន ឈានទៅដល់និយាយបក្សទៀត។ ព្រោះខ្ញុំស្តាប់ឮសាក្សីមិនទាន់និយាយដល់ចំណុចនេះនៅឡើយទេ។ <បន្ថែមពីលើនោះទៀត ខ្ញុំមិនទាន់បានជំទាស់ទៅលើរឿងនោះទេ> ប៉ុន្តែខ្ញុំកត់សម្គាល់ឃើញថា សំណួរមួយចំនួនធំដែលបានសួរកន្លងមកហ្នឹង គឺស្ថិតនៅក្រៅវិសាលភាពនៃ<>សវនាការ<>វគ្គនេះហើយ។ <ខ្ញុំភ្ញាក់ផ្អើលណាស់ ដែលសាក្សីនៅពេលនេះឆ្លើយនឹងសំណួរទាំងអស់នោះ។ ប៉ុន្តែគិតដល់អ្វីដែល>លោកប្រធានបានលើកឡើងកាលពីម្សិលមិញថា សំណួរអាចសួរទៅកាន់សាក្សីបាន បើសិនណាវាពាក់ព័ន្ធទៅនឹង -- មិនត្រូវសួរសំណួរណាក្រៅពីវិសាលភាពទេ។ អ៊ីចឹងព្រះរាជអាជ្ញាគួរតែចាំចំណុចនេះ។

[០៩:៥៧:២១]

**លោក ឌេល លីសាក់៖**

សាក្សីនិយាយអំពីការអនុវត្តដែលចាប់ផ្តើមឡើងនៅម-១៣ ហើយបន្តរហូតពេញមួយរបបនោះ។ អ៊ីចឹង<នេះជាភស្តុតាង>ពាក់ព័ន្ធទៅនឹងគោលនយោបាយ <និងការអនុវត្ត> ដែលវាជាផ្នែកមួយនៃសំណុំរឿងរបស់យើងនេះ ហើយ<វាបានបន្តអនុវត្តនៅ>ស-២១ <ដូចដែលយើងបានឃើញហើយ>។ <ពាក់ព័ន្ធនឹងការតាំងសំណួររបស់ខ្ញុំ> ខ្ញុំសូមផ្តោតសួរតែទៅលើ សុន សេន ទៅចុះ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ <នៅក្នុង>ការពិភាក្សាគ្នាជាច្រើនជាមួយ សុន សេន <ឬជាមួយមេផ្សេងទៀត ឬជាមួយ>តំណាងរបស់បក្សនោះផងដែរ តើលោកមានបានដឹងទេ នៅពេលនោះ ថាហេតុអ្វីបានជាគេក៏ត្រូវចាប់ខ្លួន និង កម្មេចប្រពន្ធកូនរបស់អ្នកដែលត្រូវបានគេចោទថា ជាខ្មាំងដែរ? មានមូលហេតុអីនៅពីខាងក្រោយការចាប់ខ្លួន និង ការសម្លាប់អ្នកទាំងនោះ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា។ សុន សេន គាត់តែងតែនិយាយជាមួយនឹងខ្ញុំ គាត់ថា “ការដែលខ្ញុំមកជួបស-២១ ហ្នឹងមិនមែនក្នុងនាមសេនាធិការទេ គឺក្នុងនាមអង្គការ”។ ក្នុងនាមអង្គការហ្នឹងបានន័យថា ក្នុងនាម៨៧០។ ដូច្នេះគាត់ណែនាំមក យើងខ្ញុំកត់ទុក។ សេចក្តីណែនាំរបស់បង សុន សេន គឺជាសេចក្តីណែនាំរបស់បក្ស។ បក្ខជនគ្រប់រូបត្រូវតែអនុវត្តភារកិច្ចដែលបក្សប្រគល់ឱ្យ ហើយខំកសាងគោលជំហររបស់ខ្លួនឱ្យទៅជាគោលជំហរវណ្ណៈអធន។ ឯចំណែកបក្សកុម្មុយនីស្តកម្ពុជាគិតយ៉ាងម៉េច ខ្ញុំសូមនិយាយមួយម៉ាត់ទៅចុះ។ ពេលនោះគេប្រើពាក្យមួយម៉ាត់ “បំណុលឈាមត្រូវតែសងដោយឈាម”។ វាផ្ទុយនឹងពាក្យព្រះពុទ្ធ ពុទ្ធោវាទ គឺឱវាទរបស់ព្រះពុទ្ធជាអង្គម្ចាស់ថា “ពាររមែងរំងាប់ដោយការមិនចងពារ” វាខុសគ្នាអ៊ីចឹង។ ដូច្នេះ គោលជំហររបស់បក្សកុម្មុយនីស្តកម្ពុជាវាទៅផ្សេង វាផ្ទុយអំពីគោលជំហររបស់ព្រះពុទ្ធជាម្ចាស់។

[១០:០០:២០]

**ស៖** ខ្ញុំសូមអានឱ្យលោកស្តាប់ ដែលលោកបាននិយាយនៅថ្ងៃទី២៥ មិថុនា ២០០៩ គឺឯកសារ E3/5805ៗនៅម៉ោង០៩:២៩ព្រឹក គឺនៅថ្ងៃទី២៥ មិថុនា ២០០៩។ “សួរ៖ តើពិតទេដែលថា ដោយសារតែកូនៗទាំងនោះមិនមានកម្លាំងកាយធ្វើពលកម្មបាន ហើយដោយសារតែស-២១ មិនចង់ឱ្យផ្តល់បាយទឹកឱ្យពួកគេស៊ី ហេតុដូច្នេះឯងបានគេ បានជាពួកគេត្រូវបានយកទៅសម្លាប់ចោល? <លោកឆ្លើយថា៖> នេះគឺជាហេតុផលទី២។ ហេតុផលទី១ គឺបក្សកុម្មុយនីស្តកម្ពុជាខ្លាចកូនៗទាំងអស់ហ្នឹងធ្វើការសងសឹក។ នេះគឺជាកត្តាចម្បងបំផុតហើយ។ ហើយ<មិនមានអ្វីទៀតត្រូវបានប្រើ ដើម្បីប្រឆាំងនឹង>កត្តា<ចម្បង>នេះ<ទេ>។” បញ្ចប់ការដកស្រង់។

លោកទើបតែឮឃ្លាថា “ខ្លាចមានការសងសឹក”។ តើលោកស្តាប់ឮពីអ្នកណាដែលនិយាយថាខ្លាចកូនៗអ្នកទាំងនោះធ្វើការសងសឹក? ហើយអ្នកណាជាអ្នកនាំអាទិ៍និយាយឃ្លានេះ?

**ឆ៖** បើតាមខ្ញុំចាំដូចតាំងពីសម័យ បងវន ម៉ែ្ល៉ះ អង្កាល់ខ្ញុំនៅអមលាំង ខ្លាចការសងសឹក។ ពាក្យហ្នឹងដូចវាខ្ញុំឮតាំងពីនុ៎ង ក៏ប៉ុន្តែដែលញឹកញាប់ គឺជាមួយ បងសុន សេន។ រួចជំហរវណ្ណៈនេះជាពាក្យទ្រឹស្តីរបស់បក្សកុម្មុយនីស្តកម្ពុជា ក៏ដូចជារបស់បក្សផ្សេងទៀត។

[១០:០២:២៨]

**ស៖** លោកបានលើកឡើងអំពីចំណុចមួយនេះ ខ្ញុំចង់លើកឡើងលម្អិតត្រង់ចំណុចនេះពាក់ព័ន្ធ

ទៅនឹងប្រពន្ធរបស់ វន វ៉េត ហើយនិងប្រពន្ធរបស់អនុ វន វ៉េត។ នៅពេលដែល វន វ៉េត ត្រូវបានចាប់ខ្លួននៅក្នុងចុងឆ្នាំ៧៨ ហើយក្រោយមក ចេង អន ក៏ត្រូវបានចាប់ខ្លួនប្រហែលជាក្នុងពេលដំណាលគ្នានោះផងដែរ។ ថាតើមានអ្វីកើតឡើងចំពោះប្រពន្ធអ្នកទាំងពីរនោះ?

**ឆ៖** ជម្រាបប្រសាសន៍ រឿងហ្នឹងខ្ញុំនៅចាំ។ ការចាប់ខ្លួនប្រពន្ធបងវន វ៉េត ប្រពន្ធបងវន ហើយនិងប្រពន្ធ បងអន នៅថ្ងៃតែមួយជាមួយគ្នា។ គេនាំស្រីៗអស់នុ៎ងទៅនឹងពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹតហើយឲ្យខ្ញុំទៅទទួល។ យកពីរនាក់ហ្នឹងមក ដូចជាសួរចម្លើយ មិនជាប្រយោជន៍អីប៉ុន្មានទេ ក៏យកទៅកម្ទេចទៅ។ ការដែលសួរចម្លើយផ្ដោតអារម្មណ៍ខ្លាំងហ្នឹងគឺទៅលើ បងវន។ ដូចខ្ញុំនិយាយអំមិញអ៊ីចឹងកូនផ្សេងទៀតរបស់ បងវន ដូចអត់ឃើញទេ កូនស្រីៗ បើ អាភេន គឺអត់ឃើញតែម្ដង។ ខ្ញុំសន្និដ្ឋានថាខាង មិត្តប៉ង់ គេយកទៅខាងពួកគេនុ៎ងហើយ កម្ទេចចោលសម្ងាត់ទៅ ព្រោះវាអត់មានផលប្រយោជន៍អីក្នុងការទុក ក្នុងការសួរចម្លើយ។ ដូច្នេះប្រពន្ធបងវន ទៅដល់នុ៎ងមែន ទៅដល់ស-២១មែន ខ្ញុំអ្នកទៅដឹកនាំកម្លាំងទៅចាប់ តាមបញ្ជារបស់ ពូនួន។ តែកម្ទេច ក្រោយនោះបន្តិច រួចសួរចម្លើយអត់មានយកចិត្តទុកដាក់ទេ ដែលគេយកចិត្តទុកដាក់ ខ្ញុំសូមបញ្ជាក់ម្ដងទៀត តែបងវន ទេ បងអន យកចម្លើយដូចជាអត់បានអីច្បាស់លាស់ទេ។

**ស៖** តើមេណាដែលជាអ្នកណែនាំលោកឲ្យចាប់ខ្លួនប្រពន្ធទាំងពីរនោះ?

**ឆ៖** ជម្រាបប្រសាសន៍ ពេលនោះអ្នកដែលណែនាំខ្ញុំផ្ទាល់ហ្នឹងគឺ ពូនួន នៅលើពីលើខ្ញុំ។ ហើយក្រៅពីនោះ មិត្តប៉ង់ ហើយនិង មិត្តលីន នេះ អាចនាំខ្ញុំឲ្យទៅចាប់អ្នកនេះ នាំខ្ញុំឲ្យទៅចាប់អ្នកនោះ តាមបញ្ជាពីខាងលើ។ ដូច្នេះអ្នកដែលនាំខ្ញុំហ្នឹង ថ្ងៃនុ៎ងមិនដឹងជា ពូនួន គាត់ហៅទៅប្រាប់ត្រង់ ឬក៏ឲ្យមិត្តប៉ង់ ឬក៏មិត្តលីន មក អាចក្រោយ មិត្តប៉ង់ ចាប់ខ្លួនទៅទៀត។ អាចមិត្ត លីន មកប្រាប់។ ដូច្នេះ មិត្តលីន នេះ គេជាសមាជិកក្រសួង ស-៧១ ឯចំណែកខ្ញុំមន្ទីរស-២១ទេ នៅក្រោមអាក្រសួងស-៧១នោះ។ ឯចំណែកអ្នកដឹកនាំកិច្ចការធំដុំគឺ ពូនួន។ ឯចំណែកអារឿងអ៊ីចឹងៗ មិត្តលីន អាចមកជំនួសបាន។

**ស៖** លោកបានលើកឡើងថា ពួកគាត់ត្រូវបានចាប់នៅពុទ្ធិកវិទ្យាល័យ។ តើលោកសំដៅលើកន្លែងតែមួយដែលលោកធ្លាប់បានជួប នួន ជា នៅពេលនោះ មែនដែរឬទេ?

**ឆ៖** គឺពិត។

[១០:០៦:៥៨]

**ស៖** តើ នួន ជា នៅទីនោះដែរឬទេ នៅពេលដែលប្រពន្ធ វន វ៉េត ហើយនិង ចេង អន ត្រូវបាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចាប់ខ្លួននោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ក្មេងៗទេ គេឃើញ។ គេឃើញ ពូនួន លបមើលពីចម្ងាយ ដោយពីទីកំបាំងមួយ។ ហើយថ្ងៃនោះ បងវិន គាត់ភ័យគាត់ពេក គាត់ទន់ជើងទន់ដៃ គាត់ស្រែកថា "មិត្តខុច អើយ! ជួយបងផងអូន"។ ខ្ញុំក៏ទៅគ្រាបងវន -- បងវិន ហ្នឹង ចេញមក។ ហើយបានមិត្តស្រី គេមកទទួលខ្ញុំ ទទួលយក បងវិន ពីខ្ញុំទៅ។ ដូច្នេះថ្ងៃនុ៎ង តាមខ្ញុំដឹងគឺស្រីៗអស់ហ្នឹង បងនួន ហៅទៅធ្វើការ។ ហើយធម្មតាធ្វើការគឺធ្វើជាមួយនឹង បងនួន នៅនឹងសាលាវិទ្យា សូមទោស នៅនឹងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ប៉ុន្តែទៅដល់នុ៎ង គេឱ្យទៅនៅបន្ទប់មួយផ្សេងៗគ្នា។ ខ្ញុំដើរទៅ រកបន្ទប់ផ្សេងទៀត តាមមិត្តលីន ចង្កុល ស្រាប់តែឮ បងវិន គាត់ស្រែកអ៊ីចឹង។ ដូច្នេះព្រឹត្តិការណ៍ហ្នឹង វាអ៊ីចឹង។ អ្នកដែលហៅ បងវិន ហើយនិង បងភ័ស ទៅធ្វើការ។ បងភ័ស នោះប្រពន្ធ ចេង អន ទៅធ្វើការគឺ ពូនួន។ ឯចំណែកអ្នកដែលហៅទៅនោះ ក៏ប្រហែលជាបញ្ជា ពូនួន ឱ្យមិត្តប៉ង់ -- អ៎ មិត្តលីន ជូនខ្ញុំទៅ នាំកម្លាំងខ្ញុំទៅចាប់។

**ស៖** តើឈ្មោះប្រពន្ធ វន វ៉េត ឈ្មោះអ្វីដែរ? ហើយគាត់ធ្វើការងារអ្វីដែរ ក្នុងរបបនោះ?

**ឆ៖** ជម្រាបប្រសាសន៍ ឈ្មោះដើមពិតប្រាកដរបស់ប្រពន្ធ បងវន ខ្ញុំមិនចាំទេ។ តែឈ្មោះបដិវត្តន៍ គេហៅជាទូទៅ ដឹងជាទូទៅគឺឈ្មោះ បងវិន។ ប្ដីឈ្មោះ វន, ប្រពន្ធឈ្មោះ វិន។ ឯចំណែកប្រពន្ធបងចេង អន ឈ្មោះ បងភ័ស។ សូមទោស បងវិន នេះ ជាប្រធានមន្ទីរពេទ្យឧស្សាហកម្ម ដែលទីតាំងហ្នឹង គឺនៅពេទ្យចិនរាល់ថ្ងៃនេះ អ៎! ពេទ្យចិនពីមុន ឥឡូវពេទ្យចិនរាល់ថ្ងៃ មិនដឹងនៅឯណា គឺនៅពេទ្យចិនពីមុន។ ហើយនៅខាងក្រសួងឧស្សាហកម្មយកអាពេទ្យចិនទល់មុខលីសេយុគន្ធរនេះ ធ្វើជាមន្ទីរពេទ្យរបស់ឧស្សាហកម្ម ហើយចាត់តាំងឱ្យ បងវិន ទៅនៅៗនុ៎ង។

[១០:១០:០៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញារងអន្តរជាតិ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាក និងឱ្យអញ្ជើញគាត់ និងមកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សវនាការនេះវិញនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១០ នាទី ដល់ម៉ោង ១០:៣០ នាទី)*

[១០:៣០:៥៩]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី យើងនិយាយគ្នាអំពីការចាប់ខ្លួនប្រពន្ធរបស់ វន វ៉េត និង ចេង អន។ ហើយលោកក៏បានបញ្ជាក់ផងដែរថា ប្រពន្ធរបស់ វន វ៉េត ឈ្មោះ វិន ដែលជាពេទ្យនៅក្រសួងអី បាទជាពេទ្យប្រចាំក្រសួងឧស្សាហកម្ម។ <ខ្ញុំចង់អានឲ្យលោកស្តាប់នូវឈ្មោះ ដែលមាន>នៅក្នុង<បញ្ជីឈ្មោះអ្នកទោស ស-២១ ដែលរៀបចំដោយការិយាល័យ>សហចៅក្រមស៊ើប<អង្កេត និងការិយាល័យ>សហព្រះរាជអាជ្ញា។ <នេះគឺលេខ ១៤.៤៧៩ ក្នុងបញ្ជីរបស់ អូ.ស៊ី.អាយ.ជេ និងលេខ ៨០៩៧ ក្នុងបញ្ជីរបស់ អូ.ស៊ី.ភី គឺ>ស្ត្រីអាយុ៣៩ឆ្នាំម្នាក់ ដែលជាប្រធានមន្ទីរពេទ្យ៧៥ ព-៧៥ ឈ្មោះ ព្រំ ផល ហៅ វិន។ តើនេះជាឈ្មោះពេញទាំងនាម គោត្តនាម ឈ្មោះពេញរបស់<ប្រពន្ធ> វន វ៉េត ហើយគាត់ហ្នឹងគឺជាអ្នកទទួលជាប្រធានមន្ទីរពេទ្យ ព-៧៥ មែនទេ?

[១០:៣៣:១៩]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំស្គាល់ប្រពន្ធ បងវន គឺតែឈ្មោះ វិន ក៏ប៉ុន្តែដល់ឃើញឯកសារនេះ ខ្ញុំជឿថា នុំងហើយ ព្រោះគ្មានប្រធានមន្ទីរពេទ្យ ព-៧៥ ឯណាដល់ទៅពីរនាក់ទេ។ ដូច្នេះ បងវិន ឈ្មោះដើមពិត ជា ព្រំ ផល នេះឯង។

**ស៖** ទាក់ទងទៅនឹងប្រពន្ធ ចេង អន ដែលលោកបញ្ជាក់ថា ឈ្មោះបដិវត្តន៍ឈ្មោះ ភ័ស ខ្ញុំសូម ឲ្យលោកមើលឯកសារ E3/10 -- គឺ E3/10256។ លោកប្រធាន សូមផ្តល់ឯកសារនេះជូនទៅឲ្យ សាក្សីពិនិត្យមើល។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនសាក្សី)*

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំបានគូសជាពណ៌នៅត្រង់ទំព័រលេខ៣ ERN ជាខ្មែរ 01016798។ នេះជាឯកសារថ្មី មួយដែលមិនទាន់បានបកប្រែទៅជាភាសាពីរទៀតនៅឡើយទេ។ បើលោកមើលលេខរៀងទី៣៨ គឺពី ខាងលើមក លេខ៤។ សូមបញ្ចាំងនៅលើអេក្រង់ផង។ អ្នកទោសដែលមានលំដាប់លេខរៀងលេខ៤ ពី ខាងលើមកនោះ គឺឈ្មោះ យ៉ាន កាំង ហៅ ភ័ស អាយុ៤៣ឆ្នាំ ស្រីដែលបានចូលមកស-២១ នៅថ្ងៃទី ២១ វិច្ឆិកា ១៩៧៨ ត្រូវបានកំណត់អត្តសញ្ញាណថាជាប្រធានមន្ទីរ ប្រធានរោងចក្រធ្វើម្សៅ។ ហើយ សូមដកស្រង់៖ "គឺជាប្រពន្ធរបស់បង៣០"។ ដំបូងខ្ញុំសូមសួរលោកថា តើបង៣០នេះជាអ្នកណា ដែល បុគ្គលដែលគេៗកំណត់ជាលេខមកថា បង៣០? លោកដឹងដែរ លោកដឹងថាបង៣០នេះជាអ្នកណាដែរ?

[១០:៣៦:៤]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ការដែលខ្ញុំធ្វើការនៅទីនោះ មិនទាន់ មិនដែលឮ ឈ្មោះបង៣០ទេ ប៉ុន្តែអាចប៉ាន់ តាមសន្និដ្ឋានគឺ ចេង អន។

**ស៖** តើប្រពន្ធរបស់ ចេង អន ជាប្រធានរោងចក្រធ្វើម្សៅមែនទេ? តើលោកស្គាល់គាត់ទេ ស្គាល់ប្រពន្ធ ចេង អន ទេ? ហើយលោកធ្លាប់ជួបប្រពន្ធ ចេង អន ទេ?

**ឆ៖** ជម្រាបប្រសាសន៍ ប្រពន្ធបង ចេង អន ខ្ញុំធ្លាប់ជួប។ គាត់អាចចំណាំខ្ញុំបាន ព្រោះយើងខ្ញុំ ទាំងពីរនាក់ជាប់គុកមុនឆ្នាំ៧០នៅព្រៃស។ តែខ្ញុំមិនស្គាល់គាត់ទេ មិនចំណាំគាត់ទេ។ ហើយដល់ក្រោយ

មក គាត់ទៅធ្វើ បងចេង អន ទៅធ្វើប្រធានតំបន់១៥ ខ្ញុំទៅលេងជាមួយនឹង បងភ័ស ញឹកញាប់ដែរ ដោយសារខ្ញុំត្រូវទៅធ្វើប្រជុំជីវភាពបក្សនៅជាមួយបង ចេង អន។ ហើយដល់ក្រោយមក បងភ័ស ទៅធ្វើប្រធានរោងចក្រ ប៉ុន្តែមិនដឹងរោងចក្រណា។ ដល់គេដាក់ថា "រោងចក្រម្សៅមី" ខ្ញុំជឿថា គាត់ទៅធ្វើការនៅរោងចក្រម្សៅមីមែន។ ដូច្នេះខ្ញុំ ហើយនិងប្រពន្ធបងចេង អន មានការរាប់អានគ្នាច្រើនដែរ។ ហើយនិយាយឲ្យត្រង់ទៅ កាលនោះខ្ញុំមានសុំលុយបាន១០០អីចាយ ១០០រៀលខ្មែរ។

**ស៖** សូមឲ្យលោកមើលបញ្ជីដដែលនេះ។ បុគ្គលបន្ទាប់មកទៀត បន្ទាប់ពីឈ្មោះ ភ័ស នេះគឺលេខរៀង៣៩។ ទី៥ ពីខាងលើមក មនុស្សម្នាក់ឈ្មោះ សឹង បូរ៉ាត់ ជាប្រធានមន្ទីរពេទ្យបស្ចិមដែលជាកូនរបស់បងទី៣០ គឺចូលមកស-២១ នៅថ្ងៃទី០៦ <ធ្នូ> ៧៨។ លោកដឹងទេ<>ថា តើ<ចេង អន មានកូនប្រុសម្នាក់ជា>ប្រធានមន្ទីរពេទ្យភូមិភាគបស្ចិមនេះ <>ដែរ<ឬទេ>?

[១០:៣៩:០៩]

**ឆ៖** ជម្រាបប្រសាសន៍ គឺឈ្មោះ បូរ៉ាត់ នេះ ខ្ញុំធ្លាប់ឮឈ្មោះ តែដូចជាឃើញមុខបានតែម្ដងទេ។ តាម៉ុក យកមនុស្សនេះ ទៅចិញ្ចឹមជានីរសារ ឌុបម៉ូតូគាត់។ ក្រោយ៧៥នេះ អាចគាត់ឲ្យមនុស្សនេះទៅជាប្រធានមន្ទីរពេទ្យបស្ចិមមែន។ ដូច្នេះ បូរ៉ាត់ ៗហ្នឹង អត់ប្រែឈ្មោះទេ។ នៅនីរសារ តាម៉ុក ហ្នឹងក៏ឈ្មោះ ប៉ូរ៉ាត់ ដែរ កូនបងអន នេះ។ ដូច្នេះ បូរ៉ាត់ ហ្នឹងប្រហែលជាពិតហើយ គឺកូន បងអន។ ៣០ហ្នឹងក៏ពិតហើយ ប្រហែលជា បងអន ហើយ។

**ស៖** មនុស្សបួននាក់ទៀតនៅលើបញ្ជីដដែលនេះ។ ខ្ញុំសុំការអនុញ្ញាតបញ្ចាំងនៅលើអេក្រង់ផង គឺពីលេខ៤០ ដល់៤៣ គឺស្ត្រីវ័យក្មេងបួននាក់ ដែលអ្នកទាំងបួននេះគេកំណត់អត្តសញ្ញាណថា មានឈ្មោះ ហេង សុក ហៅ នី អាយុ២១, ហេង ចាន់ អាយុ១៨, ហេង ភាព អាយុ១៦ និង ហេង ថន -- ហេង ថាន អាយុ១៥ អ្នកទាំងអស់នេះ គេកំណត់ថាជាកូនរបស់ បង៣០។ តើលោកដឹងទេថា ចេង អន និងប្រពន្ធរបស់គាត់ឈ្មោះ ភ័ស មានកូន<ស្រី>បួននាក់អ៊ីចឹងមែនទេ? ហើយលោកនៅចាំទេថា ឈ្មោះទាំងនេះ វាពិតជាកូនរបស់ ចេង អន មែនទេ កូនរបស់ បង៣០ មែនទេ?

**ឆ៖** ជម្រាបប្រសាសន៍ លោកព្រះរាជអាជ្ញា ខ្ញុំទៅនឹងកន្លែង បងភ័ស នុំងឃើញកូនក្មេងតូចៗច្រើនដែរ កូនស្រីគាត់ ប៉ុនអត់ស្គាល់ អត់បាននិយាយរាក់ទាក់អីទេ។ គាត់ -- គេនៅដោយគេទៅ ខ្ញុំទៅធ្វើការជាមួយនឹង បងអន ខ្ញុំធ្វើការដោយឡែកទៅ។ ដូច្នេះអាចសន្និដ្ឋានបានថា ក្មេងស្រីទាំងបួននាក់នេះគឺជាកូនរបស់ បងអន ហើយនិង បងភ័ស។

**ស៖** តើលោកឃើញកូនៗរបស់គាត់ទាំងបួនហ្នឹង នៅពេលណា? តើលោកបានឃើញនៅក្នុងរបបនោះ ឬក៏លោកបានឃើញតាំងពីមុនថ្ងៃ១៧ មេសា ១៩៧៥?

[១០:៤២:១៨]

**ឆ៖** ខ្ញុំឃើញវាងឆ្នាំ១៩៧៣ ឬក៏៧៤ នៅពេលដែលខ្ញុំត្រូវទៅធ្វើជីវភាពបក្ស ក្រោមការដឹកនាំរបស់ បងអន។ ដូច្នេះមុន ១៧ មេសា ១៩៧៥។ ក្មេងៗអស់នោះ កាលនោះវានៅជាមួយម្ដាយវា។

**ស៖** ឈ្មោះចុងក្រោយដែលខ្ញុំចង់ឲ្យលោកពិនិត្យមើល គឺលេខរៀងទី៣៧ ត្រង់ទំព័រដដែលគឺជាបុគ្គលម្នាក់ យើងមកគឺលេខរៀងទី៣ ពីខាងលើមកវិញ លេខរៀងទី៣ទេ គឺជាក្មេងស្រីម្នាក់អាយុ១៨ឆ្នាំ ឈ្មោះ សុក ស្រ៊ី ដែលគេបានកំណត់ថា ជាកូនស្រីរបស់ បងទី១០ គឺជាពេទ្យនៅ ព-៧៥ ជាមន្ទីរពេទ្យមួយដែលប្រពន្ធរបស់ វន វ៉េត <ឈ្មោះ វិន> ហ្នឹងធ្វើជាប្រធាន។ តើលោកចាំទេថា វន វ៉េត និង វិន នេះមានកូនស្រីអាយុ១៨ឆ្នាំម្នាក់ ឈ្មោះ សុក ស្រ៊ី ដែលធ្វើការនៅពេទ្យរះកាត់នោះដែរទេ?

**ឆ៖** ខ្ញុំមិនចាំទេ ខ្ញុំមិនចាំទេ។

**ស៖** ខ្ញុំសុំបង្ហាញជូនឲ្យលោកពិនិត្យមើលនូវឯកសារពីរបីទៀត ពាក់ព័ន្ធទៅនឹងមនុស្សដែលគេចាប់ខ្លួននៅអំឡុងពេលនោះដែរ <ហើយត្រូវបានគេកំណត់ថាជាសាច់ញាតិរបស់>បងទី១០ <ឬអា១០>។ លោកប្រធានខ្ញុំសុំបង្ហាញជូននូវឯកសារប្រវត្តិរូបបីពីស-២១ ជូនទៅសាក្សីពិនិត្យមើល។ ទី១គឺឯកសារ E3/10546, ខ្មែរ ERN 01219656 គឺជាប្រវត្តិរបស់ TSL0703។ <>ឯកសារ E3/10546 ដដែល ដែលមានខ្មែរ ERN ខ្មែរហ្នឹងគឺ 01219657 នេះគឺជាប្រវត្តិរូបរបស់ TSL0704។ ហើយឯកសារមួយទៀត E3/10563 ERNខ្មែរ 01219750 នេះគឺជាប្រវត្តិរូបនៅស-២១ របស់ TSL3977។ សុំការអនុញ្ញាតបង្ហាញជូនឯកសារប្រវត្តិរូបទាំងបីនេះ ទៅសាក្សីពិនិត្យមើល។

[១០:៤៦:០៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមលោកពិនិត្យមើលឯកសារប្រវត្តិរូបទាំងបីច្បាប់នេះ លោកសាក្សី។ នេះគឺជាក្មេងស្រីៗបីនាក់ផ្សេងទៀត ដែលបានចូលមកស-២១ ថ្ងៃទី១៨ ធ្នូ ៧៨ ដែលគេរកឃើញថាគឺជាសាច់ញាតិរបស់បងទី១០។ សូមបញ្ចាំងប្រវត្តិរូបទាំងនេះ នៅលើអេក្រង់កុំព្យូទ័រផង។ ទី១ គឺប្រវត្តិរូបរបស់

TSL0703 ឈ្មោះ ប៊ី ខិន មានអាយុ៧៥ឆ្នាំ ជាម្តាយរបស់បងទី១០។ ប្រវត្តិរូបទី២ ឈ្មោះគឺ TSL0704 ក្មេងស្រីអាយុ១៧ឆ្នាំ ឈ្មោះ ព្រុំ ពៅ <ត្រូវបានគេកំណត់>ថា ជា<ក្មួយ>ស្រីរបស់បងទី១០ដែរ។ ហើយប្រវត្តិរូបទី៣ TSL3977 ជាក្មេងស្រីអាយុ៦ឆ្នាំ ឈ្មោះ នីន ដែលគេរកឃើញថាជាកូនស្រី<>របស់បងទី១០។ លោកសាក្សី តើ វន វ៉េត មានម្តាយដែលមានអាយុ៧៥ឆ្នាំ <និង>មានកូនស្រីអាយុ<៦>ឆ្នាំម្នាក់ ត្រូវបានគេចាប់ខ្លួនមកស-២១ នៅថ្ងៃទី១៨ ខែធ្នូ ៧៨ មែនទេ?<>

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍ គឺឯកសារនេះ ទាំងបីច្បាប់នេះ គឺឯកសារដែលយកចេញមកពី ស-២១ ពិត នេះដែលខ្ញុំហ៊ានបញ្ជាក់។ ឯចំណែករឿងផ្សេងទៀត ខ្ញុំក្តាប់អត់បានទេ ដូចជា ឈ្មោះ យាយ ប៊ី ខិន ហើយនិងក្មេងស្រីពីរនាក់នោះ ខ្ញុំក្តាប់មិនបានទេ ថាជាកូនបងវន មែន ឬក៏មិនមែន ឬលេខ១០ ខ្ញុំក៏ក្តាប់មិនបានដែរ ថាជាលេខសម្ងាត់របស់បងវនមែន ឬមិនមែន ខ្ញុំក្តាប់អត់បានទេ។ ប៉ុន្តែជឿថា ដោយឯកសារនេះ ជាឯកសារពិតរបស់ ស-២១ សញ្ញា TSL ហ្នឹង ជាសម្គាល់ស្រាប់។ ដូច្នេះឈ្មោះនេះ ចាប់មក ចូលមកស-២១ មែន គេចាប់បញ្ជូនមកស-២១ មែន គឺសូមបញ្ជាក់តែប៉ុណ្ណឹងទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ នេះជាឧទាហរណ៍មួយច្បាស់លាស់ហើយ ដែលសាក្សីកំពុងនិយាយអំពីការដឹងរបស់គាត់<ក្រោយ>ឆ្នាំ<១៩៧៩> យកមកនិយាយពាក់ព័ន្ធទៅនឹងឯកសារ TSL នេះ។ TSLនេះគឺមិនមានមុនថ្ងៃ០៧ មករា ៧៩ទេ។ TSLហ្នឹង មានន័យថាសារមន្ទីរទួលស្លែង។ <ដូច្នេះ នៅពេលនេះ សាក្សីនិយាយថា> "ខ្ញុំដឹងថា<នេះជាឯកសារ ស-២១ ព្រោះ>គេបង់អក្សរថា TSL"។ <> ប៉ុន្តែបើនិយាយអំពីសម័យកាលនោះគឺ TSLនេះមិនមានន័យអីទេ មិនទាន់មានពាក្យនេះទេ។ ដូច្នេះ ខ្ញុំសូមឲ្យលោកប្រធានបង្គាប់ទៅសាក្សីឲ្យឆ្លើយតាមការចងចាំរបស់គាត់ កុំឲ្យយកអ្វីដែលកើតមាន ក្រោយឆ្នាំ<១៩៧៩> ដឹងក្រោយនេះហើយទើបយកមកបញ្ជាក់យ៉ាងដូច្នេះ។

[១០:៥០:៣៩]

**លោក ឌេល លីសាក់៖**

<ការលើកឡើងនេះមិនសមរម្យទេ។> សាក្សីបាននិយាយយោងថា ឯកសារនេះមានអក្សរ

TSLហើយ នេះគឺជាទម្រង់មួយ ខ្ញុំនឹងសួរទៅគាត់។ ប៉ុន្តែមេធាវីឡើងកាត់ផ្តាច់ខ្ញុំ តាមការពិតខ្ញុំបម្រុងនឹងសួរទៅគាត់ ថាទម្រង់ឯកសារនេះជាទម្រង់ដែលគេប្រើប្រាស់អ៊ីចឹង ឬក៏យ៉ាងម៉េចសម្រាប់សរសេរប្រវត្តិរូបនៅស-២១នាពេលនោះ ឬក៏យ៉ាងណា? យើងខ្ញុំមិនចង់ឲ្យសាក្សីឆ្លើយការដឹងរបស់គាត់ក្រោយឆ្នាំ៧៩ទេ។ សាក្សីបញ្ជាក់ថាឯកសារពីស-២១មែនហើយ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** អ៊ីចឹងលោកសាក្សី ខ្ញុំសូមសួរលោកថាយ៉ាងដូច្នេះ តើលោកចាំទម្រង់បែបបទរបស់ឯកសារនេះទេ? តើទម្រង់បែបបទនេះជាទម្រង់មួយដែលគេបានប្រើប្រាស់នៅស-២១ឬ នៅពេលដែលលោកជាប្រធាននៅទីនោះ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ទម្រង់នេះគឺប្រើមែននៅស-២១ ហើយអក្សរនេះ ខ្ញុំខានឃើញអក្សរ មិត្តហ៊ុយូរហើយ។ ដូច្នេះខ្ញុំគ្រាន់សូមសម្តែងការចាប់អារម្មណ៍ថាជាអក្សរ មិត្តហ៊ុ ព្រោះខ្ញុំខានឃើញអក្សរគាត់យូរហើយ ប៉ុន្មានឆ្នាំហើយតាំងពីខ្ញុំធ្វើសាក្សីពីឆ្នាំ២០១២ ៤ឆ្នាំហើយ។ ហើយខ្ញុំធ្វើសាក្សីម្តងហើយ ខ្ញុំគិតថាវាដូចលែងមាននេះ បំភ្លេចរឿងអស់ហ្នឹងចោលទៅ។ ដូច្នេះខ្ញុំជឿថាឯកសារនេះជាឯកសាររបស់ស-២១មែន ព្រោះទម្រង់នោះក៏គេធ្វើអ៊ីចឹង ហើយអក្សរនេះក៏ប្រហែលជាអាចអក្សរ មិត្តហ៊ុ លទ្ធភាព ៥០ភាគរយទេ។

[១០:៥២:៤៨]

**ស៖** ប្រវត្តិរូបចុងក្រោយ គឺក្មេងស្រីអាយុ៦ឆ្នាំ ឈ្មោះ និន ដែលគេរកឃើញថាជាកូនស្រីរបស់បងទី១០ គឺTSL3977។ លោក <និងអ្នកផ្សេងទៀត>បានឆ្លើយថា វាមិនមែនជាការអនុវត្តជាធម្មតានោះទេក្នុងការចុះបញ្ជីក្មេងៗដែលមានអាយុប៉ុណ្ណេះ។ តើលោកដឹងទេ ហេតុអ្វីបានជាក្មេងស្រីអាយុ៦ឆ្នាំម្នាក់នេះត្រូវបានគេសរសេរប្រវត្តិរូបដែរ? <តើក្នុងឱកាសអីដែរ ដែលចុះឈ្មោះ>ក្មេងអាយុប៉ុណ្ណេះ<ក្នុងបញ្ជី ស-២១>?

**ឆ៖** ជម្រាបប្រសាសន៍ ការសរសេរនេះជាខាងផ្នែករដ្ឋបាល ដូច្នេះខ្ញុំក្តាប់ការវិវត្តរបស់គេមិនបានទេ។ ដូចជាឯកសារដែលខ្ញុំឃើញកន្លងរួចមកហើយ កាលដែលខ្ញុំធ្វើសក្ខីកម្មនៅឆ្នាំមួយពាន់ -- អ៊ំសូមទោសឆ្នាំ២០១២ មានឯកសារមួយចំនួនខ្ញុំអត់ឃើញពីមុននោះទេ អត់ចាំ អត់ចងចាំទេ។ ប៉ុន្តែដល់មក ឃើញអក្សរខ្ញុំនៅនុ៎ង ឃើញអក្សរ បងចាន់ នៅនុ៎ង ដូច្នេះវាបង្ហាញបញ្ជាក់ថាឯកសារនេះគេធ្វើមែន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តែខ្ញុំមិនចាំ។ ដល់បង ម៉ម ណៃ មកទៀត គាត់ក៏មិនចាំ គាត់មានស៊ីញេបន្ថិចដែរនៅក្នុងឯកសារហ្នឹង ខ្ញុំក៏បានចារបន្តិចដែរនៅក្នុងឯកសារហ្នឹង។ ខ្ញុំចេញមុខជម្រាបអង្គជំនុំជម្រះថា ឯកសារនេះពិតជាទម្រង់បែបបទដែលគេរៀបចំថ្មី ដែល មិត្តហ៊ី គេរៀបចំថ្មី។ ខ្ញុំពិតជាបានចារត្រង់ថាឈ្មោះនេះ មិនមែនជាខ្មែរសេរីទេ គឺសេ.អ៊ី.អា។ រួចដល់ទៅបង បានបង ម៉ម ណៃ គាត់នៅស្ងៀម។ ដូច្នេះរឿងរ៉ាវនេះ ការងាររដ្ឋបាលវារិវត្ត ដើម្បីគេម្ចាស់ការ កាន់តែម្ចាស់ការលើការងាររដ្ឋបាល។ ដូច្នេះគេធ្វើ គេមិនរំខានដល់ខ្ញុំទេ។ ខ្ញុំគិតតែការងារដែលត្រូវវាយការណ៍ជូនបក្សអំពីចម្លើយរបស់ខ្មាំង។ នេះ ខ្ញុំសូមចប់។

[១០:៥៥:១៨]

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេ ថាតើសមាជិកណាម្នាក់របស់ វន វ៉េត ឬ ចេង អន ដែលគេបានបញ្ជូនទៅស-២១នោះ មានអ្នកណាម្នាក់រស់រានមានជីវិតដែរទេ?

**ឆ៖** ខ្ញុំមិនចាំ មិនដឹង។ ក្មេងបីនាក់ដែលតុលាការធ្លាប់ឃើញហើយថា មានគេសុំយកទៅចិញ្ចឹមហ្នឹង ក៏ខ្ញុំមិនដឹងអ្នកណា។ ឃើញតែឈ្មោះមួយ នង ចាន់ផល មកសម្តែងសក្ខីកម្មនៅនេះ ក្នុងឋានៈជាក្មេងកំព្រា។

**ស៖** ខ្ញុំមិនសួរក្មេងៗជាទូទៅទេ។ ខ្ញុំសួរពីប្រពន្ធរបស់ វន វ៉េត និងប្រពន្ធ ចេង អន ក៏ដូចជាសមាជិកគ្រួសាររបស់ វន វ៉េត និង ចេង អន ដែលត្រូវបានគេចាប់ខ្លួនបញ្ជូនមកស-២១។ តើមានអ្នកណាម្នាក់ដែលជាសាច់ញាតិនឹងកូនប្រពន្ធរបស់គ្រួសារទាំងពីរនេះ រស់រានមានជីវិតដែរឬទេ?

**ឆ៖** ខ្ញុំក្តាប់មិនបានទេ ខ្ញុំក្តាប់មិនបានទេ។ តាមការដែលសម្រិតសម្រាំងក្នុងកិច្ចដំណើរការហ្នឹង ខ្ញុំបញ្ជា តាមការណែនាំរបស់ ពូនួន ឲ្យកម្ទេចចោលឲ្យអស់មុនពេលដែលយួនចូល។ ហើយពេលនុ៎ងខ្ញុំសូមតែបួននាក់ទេទុក ក៏ប៉ុន្តែដល់ពេលសវនាការនេះ ស្រាប់តែលេចចេញ នង ចាន់ផល មួយមកធ្វើសក្ខីកម្ម ថាខ្លួនជាក្មេងកំព្រា។ ដូច្នេះការវិភាគរបស់ខ្ញុំ ហើយនិងការសន្និដ្ឋានរបស់ខ្ញុំ ខ្ញុំបានបញ្ជាច្បាស់ទៅឲ្យ មិត្តហ៊ី ធ្វើ។ ដូច្នេះស្រាប់តែលេចចេញក្មេងបីនាក់ដែលនៅសល់ វាមានការឆកល្បែងអីចឹង ក្នុងការអនុវត្ត គ្នាអ្នកខាងក្រោមក៏វាពិបាកនឹងអនុវត្តដែរ។ ហើយខ្ញុំសួរថា “កម្ទេចអស់ហើយនៅ?” គាត់ថា “អស់ហើយ”។ ដូច្នេះសរុបមក បើមានសាច់ញាតិបងវន វ៉េត ណាម្នាក់នៅ ខ្ញុំមិនដឹង។ បើមាននៅអាចមាននៅក្នុងចំណោមបីនាក់ហ្នឹងឯង ឬក៏មិនបានចាប់។

[១០:៥៨:១១]

**ស៖** បាទ ដើម្បីឲ្យខ្ញុំយល់ឲ្យបានច្បាស់ គឺថាលោកមិនប្រាកដទេ ថាតើក្មេងៗទាំងបីនាក់ដែល

រស់រានមានជីវិតហ្នឹង មិនដឹងថាតើក្មេងណាម្នាក់ក្នុងចំណោមក្មេងទាំងបីហ្នឹងអាចជាកូនរបស់ ចេង អន នោះទេ? លោកយល់ថា អ៊ីចឹងឬ?

**ឆ៖** មែនៗ។

**ស៖** លោកសាក្សី យើងខ្ញុំចង់សួរលោកអំពីប្រពន្ធរបស់ វន វ៉េត និង ចេង អន ដែលលោកថាត្រូវបានគេកម្ទេចចោលអស់ហើយ។ តើលោកខ្លួនឯងនេះខ្លាចទេ នៅពេលដែលគេចាប់ វន វ៉េត ណ៎ា លោកខ្លួនឯងភ័យខ្លាចទេ?

**ឆ៖** ខ្ញុំធម្មតាទេ ខ្ញុំបានរាយការណ៍ជូនតុលាការយូរហើយ។ ខ្ញុំភ័យរកធ្វើអីមិនកើត ចាប់តាំងពីគេចាប់អាណិកជនម្នាក់ឈ្មោះ បងង៉ែត យូ ហៅ ហុង។ ហើយដល់ក្រោយមកចូលដល់ បងហុកឈ្មោះដើម ឆាយ គឹមហួន – គឹមហ៊ី ខាងថាមពលនេះទៀត។ ខ្ញុំថា បន្តិចទៀតដល់អញហើយ។ ភ័យរកធ្វើអីមិនកើតទេ។ ខ្ញុំទៅអង្គុយសំកុកនៅនឹងកន្លែងគូររូប ផ្គាក់រូប ម៉្ងៃៗ។ ដល់ចុងបញ្ចប់នេះ ដែល ពូនួន គាត់ឲ្យកម្ទេចមនុស្សឲ្យអស់ចេញពីស-២១ហ្នឹង ខ្ញុំទន់ជើង ទន់ដៃលែងធ្វើការអីកើត ឈឺដេកនៅនឹងកន្លែង។ ថ្ងៃដែលយួនចូលមកដល់ហ្នឹង គឺខ្ញុំឈឺ។ ហ្នឹងគឺវាភ័យអ៊ីចឹង។ ហើយបើប្រពន្ធខ្ញុំវិញគាត់ថា ឲ្យតែឮអង្គការហៅខ្ញុំទៅធ្វើការ គាត់បុកពោះ។ ដល់ឃើញខ្ញុំជិះម៉ូតូមកវិញ បានៗគាត់ស្វាង។ គាត់ថាបុកពោះឡើងអស់ហើយព្រលឹង គាត់ថា ដល់ពេលហើយអញ។ រួចដល់ឃើញខ្ញុំជិះម៉ូតូមកវិញ គាត់ថាអ៊ូ រួចមួយគ្រា។ ដូច្នេះការសម្រិតសម្រាំងនៅទីនោះ មិនមែនប៉ះពាល់អារម្មណ៍មនុស្សតិចទេ ច្រើន រួមទាំងខ្ញុំ ហើយនិងប្រពន្ធខ្ញុំផង។

[១១:០០:៥៣]

**ស៖** ខ្ញុំសូមអានផ្នែកមួយនៃកិច្ចសម្ភាសន៍របស់សហចៅក្រមស៊ើបអង្កេត ដែលលោកបានឆ្លើយ ឯកសារ E3/1578 – E3/1578, ERN ជាភាសាខ្មែរ 00178025, អង់គ្លេស 00194550, បារាំង 00178037។ នេះគឺជាអ្វីដែលលោកបានឆ្លើយនៅក្នុងកិច្ចសម្ភាសន៍នេះ សូមដកស្រង់៖ “ម្នាក់ៗ គេត្រូវតែយល់ថា មានជនសង្ស័យពីរប្រភេទ។ ទី១ គឺជនសង្ស័យដោយសារតែគេជាសាច់ញាតិ។ ឧទាហរណ៍ សោម ម៉េង, សោម ម៉េត ឬក៏ វន វ៉េត ហើយនិងក្រុមគ្រួសាររបស់គាត់។ ទី២ គឺកូនចៅរបស់មេៗដែលគេចាប់ខ្លួន។ <ចំពោះប្រភេទទី១> ជួនកាលក្រុមគ្រួសារទាំងមូលត្រូវបានគេចាប់ខ្លួនមក ឧទាហរណ៍ដូចជា វន វ៉េត ជាដើម។ ក្នុងករណី ដទៃទៀតនេះ គឺថា ការឃ្លាំមើលនោះគឺជាការគ្រប់គ្រាន់ហើយ។ <ចំពោះប្រភេទទី២ អ្នកនៅក្រោមបង្គាប់> ត្រូវ<បានគេ>តាមដានឲ្យបានជិតដិតបំផុត។

ហេតុដូច្នេះឯង នៅពេលដែល ហ៊ុយ ស្រែ ត្រូវបានគេចាប់ខ្លួន នីរសាររបស់គាត់ក៏ត្រូវបានគេចាប់ខ្លួន។ ហើយនៅពេលគេចាប់ខ្លួន វន វ៉េត ខ្ញុំភ័យខ្លួនអំពីជោគវាសនារបស់ខ្ញុំ<>។” បញ្ចប់ការដកស្រង់។ តើលោកព្រួយបារម្ភទេ នៅពេលដែលគេចាប់ខ្លួន វន វ៉េត ដោយសារពីមុននោះ លោកធ្លាប់ធ្វើជាកូនចៅរបស់ វន វ៉េត?

**ឆ៖** ខ្ញុំបានរាយការណ៍អម្បាញ់មិញច្បាស់លាស់ហើយ។ ប៉ុន្តែឥឡូវខ្ញុំសូមបញ្ជាក់ម្តងទៀត។ ការចាប់ផ្តើមភ័យខ្លួនរបស់ខ្ញុំ ហើយពិចារណារបស់ខ្ញុំ គឺចាប់តាំងពីឆ្នាំ១៩៧៣។ ពេលត្រឡប់ពីធ្វើការនៅជាមួយមជ្ឈិមបក្សទៅវិញ ថ្ងៃនោះខ្ញុំទៅជួប បងវន យប់។ ដល់ទៅគាត់ថា មិត្តឌុច អ្ហា! មិត្តឯងឈ្មោះ កាំង ហ្គុច កាំងអីនុ៎ង! ប្រយ័ត្នខ្លួនទៅ បក្សយើងឃើញបក្សកុម្មុយនិស្តចិនហ្នឹងធំធេងណាស់ មិនទុកចិត្តទេ។ អ្នកដែលទុកចិត្តគឺ តាហុង គឺបង ង៉ែត យូ ហៅ ហុង នេះ ដែលក្រោយមកធ្វើក្នុងគណៈពាណិជ្ជកម្ម។ ខ្ញុំចេះតែប្រុងប្រយ័ត្ន។ ខ្ញុំប្រយ័ត្ន ខ្ញុំដោះស្រាយអ៊ីចេះ គឺខ្ញុំខំមើលមាគ៌ាគេ តើមាគ៌ាគេយ៉ាងម៉េច ត្រូវធ្វើម៉េចកុំឲ្យវាបាត់ខ្លួន។ រួចតែខ្ញុំបាត់ខ្លួនមួយ ក្នុងមួយផ្ទះខ្ញុំ ទាំងជីដូនខ្ញុំ ទាំងឪពុកម្តាយខ្ញុំ ទាំងប្អូនខ្ញុំអស់ហើយ ព្រោះខ្ញុំជាបង្គោល។ ក្នុងគ្រួសារខ្ញុំគឺខ្ញុំហ្នឹងជាអ្នកដឹកនាំ ជាអ្នកធំជាងគេខាងបដិវត្តន៍នៅក្នុងគ្រួសារនុ៎ង។ ហ្នឹងចេះប្រយ័ត្ន ខំបន្តិច។ ដល់ក្រោយមក មានចាប់បង ង៉ែត យូ ហៅ ហុង សុំទោស និយាយបកក្រោយបន្តិច។ នៅឆ្នាំ១៩៧៥ ខ្ញុំទៅសុំមិត្តរុំ វៀការ ខ្ញុំដណ្តឹងគាត់យូរហើយ។ ដល់វៀការគាត់មិនព្រម។ ខ្ញុំខឹង ដល់ទៅ មិត្តប៉ុន គាត់ទៅនិយាយជាមួយនឹងខ្ញុំ។ គាត់ថា បងឌុច កុំចេះតែខឹង យើងមើលបញ្ញាជនស្ងាត់ ហើយមើលពួកភូមិភាគពិសេស គេទៅអស់ហើយ នៅតែយើងទេ។ ហើយបើសិនជាបក្សចាប់ខ្លួនបងឯង គាត់មេម៉ាយ។ តើយ៉ាងម៉េច? ដូច្នេះបរិយាកាសនេះ វាមាននៅក្នុងសង្គមបក្សកុម្មុយនីស្តកម្ពុជាតាំងពីពេលណាពេលណីមក ជាពិសេសពី៧៣ ពិសេសពី៧៣។

[១១:០៥:១២]

ដល់មកចូលមកធ្វើការ បង ង៉ែត យូ ហៅ ហុង នេះដែលបក្សជឿទុកចិត្តបំផុតកាលពីមុននេះ ត្រូវបានអង្គការចាប់ខ្លួន ពេលហ្នឹងហើយដែលខ្ញុំព្រឺក្បាល។ បានដល់ថា សរុបមកគឺអ៊ីចឹង។ ឯចំណែកមេខ្ញុំនេះ បងសុន សេន ចូលចិត្តណាស់ អាលែងល្បែង លមើលទឹកមុខ មើលទឹកមុខ។ ខ្ញុំសូមជូនឧទាហរណ៍មួយ ដូចជាខ្ញុំអត់ដែលបាននិយាយទេ ក្នុងសវនាការ។ ថ្ងៃមួយនោះ ម៉ោងប្រាំ ខ្ញុំកំពុងតែដេក ប្រពន្ធខ្ញុំក៏នៅហ្នឹងដែរ។ ម៉ោងប្រាំភ្លឺស្រាប់តែឮទូរស័ព្ទរោទិ៍ ខ្ញុំភ្ញាក់ឡើង ទៅលើកទូរស័ព្ទ។ ស្រាប់តែឮច្បាស់ចែស សំឡេងបង សុន សេន។ មិត្តឌុច ចុចអាសម្ងាត់។ ខ្ញុំក៏ចុចប៊ូតុងអាសម្ងាត់។ មិត្តឌុច មក

ឥឡូវមក មកកន្លែងនីរសារ។ ខ្ញុំភ័យ! ប៉ុន្តែខ្ញុំថា អ្ហ៎! ធ្វើឲ្យវាតឹង -- អ៎ ឲ្យវាឡូយមើលទឹកមុខ កុំឲ្យមេចាប់អារម្មណ៍ ព្រោះខ្ញុំដឹងថាមេខ្ញុំ បងសុន សេន ចូលចិត្តពិតិត្យណាស់ អាទឹកមុខ។ ចូលទៅ ឃើញភ្លឺច្រើង។ គាត់មើលមុខខ្ញុំ ខ្ញុំធ្វើធម្មតា ធ្វើឡូយ។ ហើយដល់ចូលទៅ អង្គុយស្រួលបួល គាត់ថា បក្សឲ្យយើងចាប់ អាឆាន់។ អាឆាន់ ហ្នឹងកូនបង នង សួន។ ខ្ញុំថា ចុះមានអី! មនុស្សហ្នឹងទៅលេងផ្ទះខ្ញុំតែញឹកខ្ញុំហៅទៅថ្ងៃណាក៏បាន។ គាត់ថា អើ! អីចឹងមិត្តហៅទៅ ហើយមិត្តយកលេសថាម៉េច ហៅវាទៅ។ ខ្ញុំថា អាឆាន់ យករូបថតទៅផ្តិត នៅហ្នឹងផ្ទះខ្ញុំហ្នឹង ប្រហែលជា២០០សន្លឹក។ ខ្ញុំហៅទៅយករូបថតក៏បាន។ ហើយខ្ញុំមានកាំភ្លើងមួយ វាខ្ចីទៅ។ កាំភ្លើងខ្យល់ បាញ់គ្រាប់សំណរ។ ខ្ញុំហៅឲ្យវាយកអាហ្នឹងទៅឲ្យខ្ញុំក៏បាន។ បានគាត់ថា អើ! ធ្វើទៅ ហើយបើ ណាត សួរមិត្ត កុំប្រាប់។ ទុកឲ្យ ណាត មកសួរខ្ញុំ។ បានតែថារឿងមេចូលចិត្តលេងអាល្បែងហ្នឹងណាស់ សុន សេន ចូលចិត្តលេងអាល្បែងហ្នឹងមែនទែន។

[១១:០៧:៣១]

បានថាការធ្វើឲ្យភិតភ័យហ្នឹង គឺវាមាន។ ការចាប់អារម្មណ៍តាំងពីបង ង៉ែត យូ ហៅ ហុង មិនមែនទើបនឹងត្រឹម បងវន ទេ។ រួចពី បងវន មក បងហុក ក៏ត្រូវចាប់។ ធ្វើឲ្យខ្ញុំអស់កម្លាំងល្ហិតល្ហៃ ធ្វើអីលែងកើត ទៅអង្គុយសំកុកនៅកន្លែងផ្ទាក់រូប។ ពេលនោះខ្ញុំនិយាយអាកន្លែងផ្ទាក់រូប យកពួកផ្ទាក់ហ្នឹងជាៗសាក្សីជូនតុលាការ។ ហ្នឹងខ្ញុំសូមចប់ប៉ុណ្ណឹង។ ភ័យគឺភ័យ ប្រពន្ធក៏ខ្ញុំភ័យ ខ្ញុំក៏ភ័យ អាអ្នកនៅជាមួយនឹងខ្ញុំហ្នឹងក៏ភ័យដែរ។ តែអស់ខ្ញុំមួយ អាដួច មិត្តប៉ុន ដូចអីហ្នឹង ទៅហើយ។ គេចាប់តាមខ្សែ។ សូមចប់។

**ស៖** លោកទើបតែលើកឡើងអំពីការទំនាក់ទំនង ការធ្វើទំនាក់ទំនងតាមទូរស័ព្ទជាមួយនឹង សុន សេន ដែល<គាត់ប្រាប់ថា>បក្សតម្រូវឲ្យលោកចាប់ ឆាន -- ឆាង គឺកូន -- ប្អូនរបស់ សួន។ ខ្ញុំមិនដឹងថា តើខ្ញុំអានឈ្មោះត្រូវដែរឬទេ ឆាង ហ្នឹង? តើអ្នកទាំងពីរហ្នឹង ជានរណាដែរ លោកអាចជួយពន្យល់បានដែរឬទេ?

**ឆ៖** អរគុណ។ ឆាន់ ហ្នឹងជាឈ្មោះបដិវត្តន៍ទេ។ ឈ្មោះដើមរបស់វា ជ័យ ហាន។ ជ័យ ហាន ហៅ ឆាន់។ វាជាអនុលេខាកងពល១៦៤ជាមួយ បងមុត។ ដល់ក្រោយមក បក្សចាប់អារម្មណ៍សង្ស័យដកវាយកមកទុកតាមដាននៅសេនាធិការ ដូចបក្សធ្លាប់ធ្វើជាមួយនឹង ចាន់ ចក្រី ជាមួយអីហ្នឹងផ្សេងទៀតហ្នឹង។ រួចដាក់ភារកិច្ចឲ្យ ណាត តាមដាន។ នេះ សៅ ឆាន់។ រួចក្មេងហ្នឹង ហើយនិងខ្ញុំ ស្គាល់គ្នាចាប់តាំងពីឆ្នាំ១៩៦៧ ក្នុងជួរបដិវត្តន៍ជាមួយគ្នា។ ឯចំណែកឪពុក ឆាន់ – ឪពុកអាឆាន់នេះ ឪពុកអាជ័យ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហាន នេះគឺបង នង សួន។ នង សួន នេះហៅ មិត្តជ័យ ឬ ជ័យ សួន។ ជ័យ សួន ហ្នឹងអង្គការជ្រាប ហើយ លោកព្រះរាជអាជ្ញាក៏គង់ជ្រាបដែរ ជាអតីតអ្នកតស៊ូ ទៅជាប់គុកជាមួយនឹងខ្ញុំ។

[១១:១០:២៣]

**ស៖** សូមអរគុណ។ ពាក់ព័ន្ធទៅនឹង វន វេត និង ចេង អន ក្រោយពេលចាប់ខ្លួនអ្នកទាំងពីរ តើកូនចៅក្រោមគាត់ មកពីក្រសួងឧស្សាហកម្ម ត្រូវបានចាប់ខ្លួនផងដែរឬទេ?

**ឆ៖** អ្នកដែលកាន់កាប់ក្រសួងឧស្សាហកម្មក្រោយហ្នឹង មិនដឹងជាអ្នកណាទេ ប៉ុន្តែមនុស្សខាងនិរតី។ គេសម្រិតសម្រាំងទៅតាមនុ៎ងហើយ។ ដូច្នេះការសម្រិតសម្រាំងតមកទៀត ស្រេចនៅលើប្រធានឧស្សាហកម្មថ្មី។ ឯចំណែកការសម្រិតសម្រាំងបន្តបន្ទាប់ភ្លាមៗក្រោយចាប់ បងវន គឺគេមានគោលបំណងហើយស្រេច ផែនការហើយស្រេច ចាប់អ្នកណាមុន ចាប់អ្នកណាក្រោយ របស់គេ។ គេហ្នឹង គឺសំដៅអចិន្ត្រៃយ៍មជ្ឈិមបក្ស សំដៅគណៈ៨៧០ ដែលមេខ្ញុំធ្លាប់ប្រើពាក្យថា "គណៈប្រចាំការ"។

**ស៖** ការបកប្រែថា "គណៈប្រចាំការ" តើលោកសំដៅលើ គណៈប្រចាំការហ្នឹងគឺសំដៅទៅលើគណៈអចិន្ត្រៃយ៍មែនដែរឬទេ?

**ឆ៖** ខ្ញុំបានជម្រាបបញ្ជាក់ម្សិលមិញហើយ គណៈអចិន្ត្រៃយ៍ផ្សេងអំពីគណៈប្រចាំការបន្តិច។ វាមានការជាន់គ្នាអ៊ីចឹង។ គណៈអចិន្ត្រៃយ៍ ប៉ុន្តែមិនមែនគណៈប្រចាំការ ពីរនាក់គឺ បងភឹម និងបងម៉ុក។

**ស៖** ដើម្បីឲ្យខ្ញុំយល់ច្បាស់ នៅពេលដែលលោកនិយាយថា "គណៈប្រចាំការ" គឺលោកហៅថាក្រុមមកពីទីក្រុងភ្នំពេញដែលជា<មេដឹកនាំ>មជ្ឈិម<បក្សនៅភ្នំពេញ>ផងដែរ។ តើអ៊ីចឹងមែនដែរឬទេ?

[១១:១៣:០៨]

**ឆ៖** ខ្ញុំសូមបញ្ជាក់ ប្រហែលជាអ្នកបកប្រែទេ មើលទៅ។ គណៈប្រចាំការនេះ សំដៅពួកនៅក្នុងអចិន្ត្រៃយ៍មជ្ឈិម និងមិនមែននៅក្នុងអចិន្ត្រៃយ៍មជ្ឈិម ទាំងអស់មានគ្នាប្រាំមួយនាក់ ហ្នឹងគណៈប្រចាំការ។ បើនិយាយតាមឯកសារបក្សផ្សេងទៀតដែលខ្ញុំធ្លាប់អាន មុនឆ្នាំ១៩៦៧ ដែលខ្ញុំចូលព្រៃ គេហៅថា "ការិយាល័យនយោបាយមជ្ឈិមបក្ស"។ ក៏ប៉ុន្តែនៅពេលដែលខ្ញុំធ្វើការជាមួយនឹងបង សុន សេន គាត់មិនដែលនិយាយអ៊ីចឹងទេ។ គាត់និយាយតែគណៈប្រចាំការ គណៈប្រចាំការ គណៈប្រចាំការ ឬពេលខ្លះគាត់ហៅ៨៧០។ ហើយខ្ញុំនិយាយពីម្សិលមិញដែរថា ពួកអ្នកតស៊ូចាស់ គេហៅ គណៈប្រចាំការហ្នឹងថាពួកបញ្ញាជន ឬក៏ពួកអាភ្នំពេញ ពួកអ្នកភ្នំពេញ។ ហើយខ្ញុំបានជម្រាបលោកព្រះរាជអាជ្ញាអម្បាញ់មិញហើយ អចិន្ត្រៃយ៍ពីរនាក់ មិនមែននៅក្នុងគណៈប្រចាំការនុ៎ងទេ គាត់នៅធ្វើលេខាភូមិភាគ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** យើងនឹងត្រឡប់មកវិញ ហើយនឹងលើកឡើងអំពីខាងផ្នែកថ្នាក់ៗលើនៅរសៀល ចុងរសៀលនេះ ឬក៏ថ្ងៃស្អែក ខ្ញុំនឹងសួរជាក់លាក់តែម្ដងទៅលើ វន វ៉េត ការចាប់ខ្លួនគាត់ និងការសួរចម្លើយគាត់។ យើងនឹងលើកឡើងអំពីបញ្ហាគាត់នេះ នាពេលក្រោយ។ ក៏ប៉ុន្តែនៅពេលនេះ ខ្ញុំលើកឡើងអំពីការប្រព្រឹត្តចំពោះប្រពន្ធ និងកូនៗរបស់បុគ្គលដែលត្រូវបានបញ្ជូនទៅស-២១សិន។ នៅពេលដែលប្រពន្ធ និងកូនៗអ្នកទាំងនោះត្រូវបានបញ្ជូនទៅស-២១ ដែលអ្នកទាំងអស់ហ្នឹង គឺជាសាច់ញាតិអ្នកដែលត្រូវបានគេចោទថាជាខ្មាំង ឬក៏ជាជនក្បត់ តើប្រពន្ធ និងកូនៗទាំងអស់នោះ ត្រូវបានគេសួរចម្លើយដែរឬទេ ឬក៏អត់ទេ?

[១១:១៥:២៨]

**ឆ៖** ភាគច្រើនគឺអត់។ ដូច បងវិន ខ្ញុំមិនចាំថា គាត់បានឆ្លើយ ឬខ្ញុំបាន -- ឬមិត្តហ៊ី គេបានចាត់តាំងឲ្យអ្នកណាសួរគឺអត់ ប្រហែលជាអត់ទេ។ ដូច បងភ័ស ដូចអីនេះ ប្រពន្ធបងហុក អីៗ, បងហៀង អី ខ្ញុំគិតថា អត់បានសួរទេ សួរបន្តិចបន្តួច សោះតែខានណាស់ ហើយក៏ដល់ពេលក៏ដឹក ដឹកយកទៅកម្ទេចទៅ។ គេយល់ថាស្រីមិនសូវមានសារៈសំខាន់ទេ ខាងនយោបាយ។

**ស៖** ប្រពន្ធទាំងអស់នេះ ឧទាហរណ៍ថាប្រពន្ធ វន វ៉េត និង ចេង អន តើអ្នកទាំងពីរនោះ ត្រូវបានចាប់ខ្លួនដោយសារការងារដែលពួកគាត់បានធ្វើ ឬក៏ចាប់ខ្លួន ដោយសារគ្រាន់តែជាប្រពន្ធអ្នកទាំងពីរ ហើយដែលប្ដីរបស់ពួកគាត់ហ្នឹងត្រូវបានគេចោទថាជាខ្មាំង?

**ឆ៖** បញ្ហានេះញែក -- បើតាមខ្ញុំយល់ឥឡូវអ៊ីចេះ ញែកអត់ដាច់ទេ ញែកអត់ដាច់ទេ។ តែប្ដីធ្វើម៉េច ប្រពន្ធក៏គង់តាមប្ដីនុ៎ងបន្តិចបន្តួច ខានមិនខានទេ។ ប៉ុន្តែបើនិយាយសំខាន់មែនទែន បើគេចាប់ប្ដី ហើយគឺគេចាប់ប្រពន្ធហើយ។

**ស៖** លោកក៏បានបញ្ជាក់ផងដែរថា កូនៗក៏ត្រូវបានចាប់ខ្លួនផងដែរ។ តើគេចាប់កូនៗដោយសារតែគេសង្ស័យថា កូនៗហ្នឹងធ្វើខុស ឬក៏គេចាប់កូនៗទាំងអស់នោះ ដោយសារជាប់សាច់ញាតិអ្នកដែលត្រូវបានគេចោទថាជាខ្មាំង?

**ឆ៖** រឿងនេះជារឿងស្មុគស្មាញលំបាកពន្យល់ អំលំបាកវិភាគណាស់។ ដូចជារឿងអានាន់ កូនបងជ័យ កូនបងសួន កូនបង នង សួន អ៊ីចឹង។ ខ្លួនវាហ្នឹងក៏មានពិរុទ្ធភាពខ្លះ។ ខ្ញុំគិតថាមនុស្សមិនមាននិស្ស័យនឹងទៅធ្វើមេបញ្ជាការទ័ពទេ លេងសើចច្រើនណាស់ កំប្លុកកំប្លែង ខ្ញុំស្គាល់។ អ៊ីចឹងហើយបានៗគេបញ្ជូន អាហាន ចេញពីអនុលេខាកងពល១៦៤ មកនៅបញ្ឈរជើងចោលនៅជាជំនួយការសេនាធិការ

ទុកតាមដាន។ នេះមួយរឿងទៅ។ ឯចំណែកអ្នកខ្លះវិញ គេចាប់ ព្រោះគេចាប់ឪ ដូចកូន បងវន, អាផេន ជាពីឡុត ជាអ្នកបើកបរអាកាសយាន អាប្រដេញ។ អង្កាល់នោះចំណាយលុយតែបីនាក់ទេ បង្រៀនកូនកម្មាភិបាលតែបីនាក់ទេ កូនអៀង សារី មិត្តវុធ នេះមួយ, អាផេន កូនបងវន នេះពីរ ហើយនិងមិត្តមី កូនបងសុន សេន នេះពីរ -- បី សម្រាប់រៀនអាប្រដេញតែបីនាក់ទេ។ ឥឡូវស្លាប់អស់ពីរហើយ នៅសល់តែ មិត្តវុធ មួយទេ នៅធ្វើចៅហ្វាយខេត្តប៉ៃលិន។ ដូច្នេះគេចាប់កូនដោយសាររឿងឪមានរឿង ដូចមិត្តឆាន់ អ៊ីចឹង អាឆាន់ ហ្នឹង។ គេចាប់ អាឆាន់ ដូចចាប់ អាឆាន់ មុនចាប់បងសួន បងជ័យ។

[១១:១៩:៣២]

**ស៖** តើ ឆាន់ មានអាយុប៉ុន្មាន?

**ឆ៖** វាប្រហែលជាប្អូនខ្ញុំយ៉ាង អ្ហ្ន រវាង៥ឆ្នាំអីហ្នឹង ប្អូនខ្ញុំ។

**ស៖** នៅពេលដែលខ្ញុំនិយាយថា "កូនៗ" មិនមែនថាកូនៗពេញវ័យនោះទេ ខ្ញុំនិយាយអំពីកូនក្មេងៗ ១៤ឆ្នាំ ឬក៏អាយុក្រោមហ្នឹង ដែលមិនកាន់តួនាទីនៅក្នុងរបបនោះ។ កូនក្មេងៗទាំងហ្នឹង កុមារទាំងអស់ហ្នឹង តើត្រូវបានគេចាប់ខ្លួនដោយសារធ្វើខុស ឬចាប់ដោយសារតែជាកូនរបស់អ្នកដែលត្រូវបានគេចោទថាជាខ្មាំង?

**ឆ៖** អរគុណ។ ច្បាស់ហើយ កាលណាឪមកហើយ ម៉ែមកហើយ កូនក៏គេចាប់ដែរ។ នេះវាទៅជាក្រឹត្យក្រមនៃកិច្ចដំណើរការទៅហើយ។

**ស៖** ទាក់ទងទៅនឹងសមាជិកគ្រួសារ តើគេសួរ បានសួរចម្លើយឬក៏អត់នោះ ខ្ញុំចង់បង្ហាញឯក-សារមួយជូនលោក ដែលខ្ញុំបានសួរពីមុនដែរ គឺលោកចៅក្រមឯកសារ E3/2047– E3/2047។ ផ្នែកដំបូងនៃឯកសារនេះ គឺបញ្ជីមនុស្សចំនួន១៨នាក់ដែលត្រូវបានគេកំណត់អត្តសញ្ញាណថា ជាសមាជិកគ្រួសាររបស់ ម៉ែ លន់ <និងជាសមាជិកគ្រួសាររបស់ សុខ>។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ឯក-សារនេះជូនទៅសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី សូមលោកមើលទំព័រដំបូងនៅក្នុងឯកសារនេះ គឺឯកសារE3/2047 ទំព័រដំបូងនោះ តើលោកស្គាល់ទេ? ហើយលោកស្គាល់ទេ ឯកសារហ្នឹង ជាឯកសារអ្វីដែរ?

[១១:២២:៣០]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ឯកសារនេះជាឯកសារពួកស្រែ គឺមិត្តហ៊ុយ សរសេរមកខ្ញុំ នៅពេលដែលចាប់ពួកនេះ បញ្ជូនមកស-២១ភ្នំពេញ។ សូមបញ្ជាក់ថា សុខ នេះឈ្មោះដើម ស៊ិន ដារ៉ា ជាលេខាគណៈកម្មាធិការក្រុង ពេលតស៊ូសម្ងាត់នៅភ្នំពេញ មុនឆ្នាំ១៩៧៥ មុន១៧មេសា។ នេះហើយដែល ណាត សរសេរនៅក្នុងសេចក្ដីរាយការណ៍ ដែលលោកព្រះរាជអាជ្ញាបង្ហាញខ្ញុំម្សិលមិញ ថាពួកប្រុក -- បងប្អូនខាងក្រុងមិនមែនក្រុមទេ។ រាយការណ៍ថា នៅរ៉ា យ៉ាងនេះយ៉ាងនោះ។ ដូច្នេះ សុខ នេះខ្ញុំសូមបញ្ជាក់បន្ថែមប៉ុណ្ណឹង។ ឯចំណែកបង ម៉ៃ លន់ នេះគាត់ជាលីសង់ សាស្ត្រាចារ្យលីសង់ ប៉ុន្តែមិនដឹងខាងអីទេ។ ប៉ុន្តែបក្សសម្គាល់ថា មនុស្សនេះជាមនុស្សប្រជាចលនា បានន័យថា មាននិន្នាការទៅខាងខ្មែរសេរី។ ដល់ពេលនេះ ក៏ទៅបក្សបញ្ជូនឲ្យទៅនៅខាងផែនទី នេះបងម៉ៃ លន់។ ដល់ក្រោយមកមានរឿងរ៉ាវ ចាប់មិត្តសុខ ចាប់អីទៅ ក៏យកបងម៉ៃ លន់ ទៅដាក់នៅឯស្រែ ឬក៏ចាប់ ខ្ញុំវង្វេងអស់ហើយ។ ប៉ុន្តែរឿងនេះ គឺច្បាស់លាស់ណាស់អ៊ីចឹង។ ឯចំណែកអ្នកដែលត្រូវចាប់ ដោយសារត្រូវជាបងប្អូនបង្កើតរបស់ មិត្តសុខ ហើយនិងកូនរបស់បងម៉ៃ លន់ មិត្តហ៊ុយ សរសេរមក។ ឪពុកបង្កើតរបស់អាសុខ ម្ដាយបង្កើតរបស់អាសុខ ប្អូនបង្កើតរបស់អាសុខ កូនអាម៉ៃ លន់ អី កូនអីៗហ្នឹង។ ទាំងអស់នេះ គឺគេចាប់ដោយសារ មិត្តហ៊ុយ គាត់ចាប់បញ្ជូនមកស-២១ភ្នំពេញ ដោយសារជាប់សែស្រឡាយរបស់ មិត្តសុខ ហើយនិងបងម៉ៃ លន់។ រួចខ្ញុំក៏សរសេរស្នើសួរប្អូននាក់ ក្រៅពីនេះវ៉ៃចោល។ នេះជាសេចក្ដីសម្រេចចិត្តរបស់ខ្ញុំក្នុងការងារជាក់ស្ដែងមួយហ្នឹង។

**ស៖** ដើម្បីខ្ញុំយល់ឲ្យបានច្បាស់ ចំណារដែលនៅខាងលើថា “ស្នើសួរចម្លើយប្អូន ហើយសម្លាប់អ្នកដែលនៅសេសសល់” នេះជាចំណាររបស់លោក។ តើអ៊ីចឹងដែរឬទេ?

[១១:២៥:១៧]

**ឆ៖** អរគុណ។ ប្រាកដ គឺជាចំណាររបស់ខ្ញុំ។ នេះជាសេចក្ដីសម្រេចចិត្តរបស់ខ្ញុំក្នុងករណីមួយនេះ។

**ស៖** តើមានការសម្រេចយ៉ាងម៉េច នៅពេលដែលចុចយកតែប្អូនយកមកសួរចម្លើយនោះ? តើសម្រេចដោយផ្អែកលើអ្វី?

**ឆ៖** ការដែលសម្រេចនេះ វាយូរឆ្នាំហើយ។ ដូច្នេះការនិយាយឆ្លើយពេលនេះ វាមានតែការ

សន្និដ្ឋានច្រើនជាងការច្បាស់លាស់ជាវិចារណញ្ញាណ។ ខ្ញុំឲ្យគេសួរឪពុក ហើយនិងម្តាយរបស់ មិត្តសុខ ហើយទី២ សួររឿងប្រាក់ដុល្លារក្លែងក្លាយនេះ ឃើញចំណាររបស់ មិត្តហ៊ុយ មកនោះ រាយការណ៍ឲ្យខ្ញុំថា "មានប្រាប់ដុល្លារ និងបម្រុងរត់ទៅបាត់ដំបង ដេរយើងតាំងពីមកដល់"។ ហ្នឹងខ្ញុំឈរលើបញ្ហានេះ ដើម្បីសម្រេច។

**ស៖** ខ្ញុំសួរអំពីតាមដំណើរការនៃការសម្រេចយកអ្នកទាំងបួននោះមកសួរចម្លើយ។ នៅពេលនេះ ខ្ញុំសូមអានអ្វីដែលលោកឆ្លើយប្រហែលជាប៉ុន្មានឆ្នាំកន្លងមកហើយ នៅក្នុងកិច្ចសម្ភាសន៍របស់សហចៅក្រមស៊ើបអង្កេត ឯកសារ E3/1576, ខ្មែរគឺ <00159564> ដល់65, អង់គ្លេសគឺ 00160723, បារាំង 00159585។ គេសួរលោក ហើយបានសរសេរនៅក្នុងឯកសារនេះ លោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ "ខ្ញុំទទួលស្គាល់ ថាខ្ញុំបានសរសេរនៅខាងលើផ្នែកខាងឆ្វេង ជ្រុងខាងឆ្វេង គឺសួរចម្លើយបួននាក់ សម្លាប់អ្នកទាំងអស់ដែលនៅសេសសល់។ បញ្ជីនេះត្រូវបាន ហ៊ុយ បញ្ជូនមក ដែលគាត់ទទួលខុសត្រូវអ្នកទោសនៅស្រែ នៅឯព្រៃស។ គាត់បានស្នើសុំថាឲ្យសួរបុគ្គលបីនាក់ក្នុងចំណោមបុគ្គលទាំងអស់នោះ គឺលេខទី១៣, ១៤ និង១៥។ ខ្ញុំបានរាយការណ៍បញ្ហានេះទៅ សុន សេន តាមទូរស័ព្ទ ហើយ សុន សេន ណែនាំខ្ញុំឲ្យសួរចម្លើយបុគ្គលបួនរូបដែលមាននៅក្នុងជួរលេខ១, លេខ២, លេខ១៣ និង១៤ ហើយអ្នកដែលនៅសេសសល់ទៀតយកទៅសម្លាប់ចោល។" បញ្ចប់ការដកស្រង់។

[១១:២៨:៣៣]

តើវាជួយឲ្យលោកនឹកឃើញដែរឬទេ? តើលោកចាំថាបាននិយាយជាមួយនឹង សុន សេន អំពីបុគ្គលណាដែលត្រូវយកមកសួរចម្លើយ ហើយអ្នកណាខ្លះដែលបញ្ជូនទៅសម្លាប់ចោល? តើលោកនៅចាំថាបាននិយាយជជែកជាមួយនឹង សុន សេន លើករណីនេះដែរឬទេ? ហើយតើលោកបានបញ្ជូនឯកសារនេះមួយច្បាប់ទៅ សុន សេន ដែរឬទេ?

**ឆ៖** អរគុណ។ ការដែលលោកអានឡើងវិញនូវចម្លើយរបស់ខ្ញុំជូនសហចៅក្រមស៊ើបអង្កេត ធ្វើឲ្យខ្ញុំជឿថា ការចងចាំរបស់ខ្ញុំនៅពេលនោះ វាច្បាស់លាស់ជាងការចងចាំរបស់ខ្ញុំនៅពេលនេះ។ ក៏ប៉ុន្តែពេលនេះ ខ្ញុំគ្រាន់បន្ថែមអំពីប្រវត្តិរូប មិត្តសុខ ហើយនិងបង ម៉ៃ លន់។ អារឿងបង ម៉ៃ លន់ នេះ សុន សេន ទេគាត់ច្បាស់ជាងខ្ញុំ។ ហើយ មិត្តសុខ នេះក៏នៅក្រោមការគ្រប់គ្រងផ្ទាល់របស់គាត់ ចាប់តាំងពីឆ្នាំ១៩៧៣មក គាត់គ្រប់គ្រងក្រុងភ្នំពេញនេះដែរ ការងារនៅក្រុងភ្នំពេញ គាត់ក្តាប់។ ដូច្នេះឯកសារនេះបានបញ្ជូន ឬមិនបានបញ្ជូន គឺខ្ញុំគ្រាន់តែអានជូនគាត់ គាត់សម្រេចមក ក៏មិនដឹង។ ខ្ញុំអត់ច្បាស់ទេ ប៉ុន្តែ

បើពេលនោះខ្ញុំនិយាយអ៊ីចឹង គឺពេលនោះខ្ញុំនៅចាំរឿងច្បាស់ជាងពេលនេះ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** មុនពេលយើងសម្រាក មនុស្សពីរនាក់នៅក្នុងបញ្ជីនេះ ដែលលោកបាននិយាយរាយការណ៍ទៅកាន់ សុន សេន គឺជួរទី៧ លេខ៧ និង៨ ដែលជាកុមារី៤ឆ្នាំ និង៦ឆ្នាំ ដែលមិនស្ថិតនៅក្នុងចំណោមអ្នកទាំងបួនត្រូវយកទៅសួរចម្លើយទេ ក៏ប៉ុន្តែស្ថិតនៅក្នុងក្រុមដែលត្រូវយកទៅសម្លាប់ចោល។ តើ សុន សេន បានអនុញ្ញាតឱ្យសម្លាប់កុមារីដែលមានអាយុ៤ និង៦ឆ្នាំមាននៅក្នុងបញ្ជីនោះដែរឬទេ?

[១១:៣១:២៦]

**ឆ៖** ខ្ញុំជម្រាបប្រសាសន៍ដោយត្រង់ចុះ។ មកដល់ថ្ងៃនេះខ្ញុំភ្លេចភ្លាំងអស់ហើយ សូម្បីតែសំណូមពរដែលខ្ញុំស្នើសុំយោបល់បង សុន សេន អំពីបញ្ហានេះ ក៏ខ្ញុំភ្លេចដែរ។ ដូច្នេះអារឿងក្មេង១ប៉ុន្មាននាក់នេះ បើសិនជាខ្ញុំបានរាប់ ហើយគាត់ថា ឱ្យសួរតែបួននាក់ហ្នឹង ឯចំណែកអ្នកផ្សេងទៀត គាត់មិនមានមតិ បានន័យថា ខ្ញុំត្រូវតែកម្ទេច។

**លោក ឌេល លីសាក់៖**

លោកចៅក្រម មុនពេលដែលយើងសម្រាក ខ្ញុំសូមកត់ត្រាទុកជាប្រតិចារឹក។ ក្រុមដែលត្រូវបានគេសម្រេចសម្លាប់ចោលនៅក្នុងឯកសារនេះ ឈ្មោះនេះគឺត្រូវបានចុះនៅក្នុងបញ្ជី ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៧។ គឺមាននៅក្នុងបញ្ជីអ្នកទោសបានត្រូវសម្លាប់នៅក្នុងបញ្ជីរបស់ចៅក្រមស៊ើបអង្កេត ៣៣៣៨, ៣៣៤២, ៣៣៤៥, <៣៣៤៧, ៣៣៥៣> ទៅដល់៥៧ និង៣៣៦០ ដែលបញ្ជីនោះឱ្យសម្លាប់អ្នកទាំងអស់នេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឱ្យបានមុនម៉ោងមួយកន្លះ និងឱ្យនាំខ្លួនលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ទៅកាន់បន្ទប់រង់ចាំ សម្រាប់សាក្សី ដែលត្រូវបានរៀបចំទុកនៅពីក្រោមសាលសវនាការនេះ និងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ

នៅវេលាម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:២៨ នាទី)*

[១៣:២៨:០៦]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោករ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញា តំណាងសហព្រះរាជអាជ្ញាដើម្បីតសួរដេញដោលចំពោះសាក្សី។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន សហភាតារបស់ខ្ញុំនឹងមកដល់បន្តិចទៀតលោកប្រធាន។ អ៊ីចឹងខ្ញុំសូមអភ័យទោស សូមអង្គជំនុំជម្រះមេត្តារង់ចាំបន្តិចបន្តួចលោកប្រធាន។

**លោក ឌេល លីសាក់៖**

សូមអភ័យទោសលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** <តើលោកនៅមាន>មានឯកសារដែលយើង<>បានពិនិត្យមើល<មុនពេលអាហារថ្ងៃត្រង់ទេ> ឯកសារ E3/2047? ខ្ញុំនឹងផ្ដល់អត្ថបទឯកសារនេះទៅឲ្យលោកពិនិត្យមើល។ លោកសាក្សីសូមលោកមើលទំព័រទី២នៃសម្រង់នេះ។ <ទំព័រ>ទី១ គឺនិយាយអំពីសមាជិកគ្រួសារចំនួន១៨នាក់ គឺបុគ្គលក្នុងនោះមានបុគ្គលពីរនាក់ដែលយើងបានពិភាក្សាគ្នាហើយ<គឺ សុខ និង ម៉ែ លន់>។ ទំព័រទី២ គឺជារឿងរបាយការណ៍មួយទៀតដែលជាបញ្ជីដែលចេញដោយ ហ៊ុយ ចុះថ្ងៃទី០៧ មេសា ៧៧ គឺកាលបរិច្ឆេទតែមួយទេ។ បញ្ជីនេះ មានស្ត្រីមានផ្ទៃពោះចំនួន១១នាក់។ តើលោកអាចជម្រាបជូនតុលាការបានទេ ហេតុអ្វីបានជា ហ៊ុយ បញ្ជូនបញ្ជីឈ្មោះស្ត្រីដែលមានផ្ទៃពោះ ១១នាក់នេះមក?

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៣:៣១:៤៨]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** រឿងនេះ ខ្ញុំនៅចាំបានថា មានសួរខ្ញុំម្តងហើយ មិនដឹងជានៅក្នុងសម័យស៊ើបអង្កេត ឬនៅក្នុងសវនាការសំណុំរឿងលេខ០១ទេ។ ហើយក៏ខ្ញុំមិនចាំថា ពេលនោះខ្ញុំបាននឹកឃើញរឿងចាស់នេះយ៉ាងម៉េច ខ្ញុំភ្លេចអស់ហើយ។ ដូច្នេះសុំលោកព្រះរាជអាជ្ញាមើលអាសេចក្តីពន្យល់ចាស់របស់ខ្ញុំ។

**ស៖** ខ្ញុំអាចធ្វើដូច្នេះបាន ក៏ប៉ុន្តែលោកនៅចាំទេថា មានអ្វីកើតឡើងទៅដល់ស្ត្រីដែលមានផ្ទៃពោះនៅក្នុងបញ្ជីនេះទេ? ហើយសំណួរមួយទៀតថា ហេតុអ្វីបានជា ហ៊ុយ បញ្ជូន<បញ្ជី>ស្ត្រីដែលមានផ្ទៃពោះ ១១នាក់នេះ មកពីព្រៃសនោះ?

**ឆ៖** ខ្ញុំមិនចាំទេ រឿងរ៉ាវអស់ហ្នឹងខ្ញុំអត់ចាំទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

គ្រាន់តែជាការសួរបញ្ជាក់ទេ។ តើកន្លែងណាដែលមានបញ្ជាក់ថា ហ៊ុយ បញ្ជូនបញ្ជីនេះមក ស-២១?

[១៣:៣៣:១៨]

**លោក ឌេល លីសាក់៖**

គឺជាឧបសម្ព័ន្ធទៅនឹងឯកសារមួយ<ទៀត ហើយខ្ញុំគិតថា លោកនឹងរកឃើញនៅក្នុងចម្លើយបន្ទាប់ នៅក្នុងឯកសារបន្ទាប់ដែលខ្ញុំប្រុងនឹងប្រើវាទៅហើយ លោកមេធាវី>។

**លោក វ៉ិចទ័រ កូប៉េ៖**

វាភ្ជាប់មកជាមួយនឹងឯកសារនេះ ក៏ប៉ុន្តែតើវាភ្ជាប់មកនៅពេលនោះ ឬក៏យ៉ាងណា?

**លោក ឌេល លីសាក់៖**

ដើម្បីឆ្លើយតបទៅនឹងសំណួររបស់មេធាវីការពារក្តី ខ្ញុំចូលដល់ឯកសារមួយទៀតគឺ E3/10506 –E3/10506។ ជាពិសេសទំព័រជាភាសាខ្មែរ ដោយសារថានេះគឺជាបញ្ជីថ្មីមានតែជាភាសាខ្មែរទេ ERN ជាភាសាខ្មែរ 01019382 ដល់83។ ខ្ញុំសូមជូនបញ្ជីថ្មីមួយនេះ ជូនទៅសាក្សីពិនិត្យមើលលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ខេល លីសាក់៖**

**ស៖** សូមលោកមើលទំព័រដែលខ្ញុំមានបិទ*ប៉ូស្ទ័រ* នៅទំព័របន្ទាប់នោះ។ លោកនឹងឃើញថា នៅលើបញ្ជីនេះ គឺជាបញ្ជីអ្នកទោសដែលគេយកទៅសម្លាប់ គឺស្ត្រី១០នាក់ដែល ហ៊ុយ បានរាយការណ៍មកថា សុទ្ធតែជាស្ត្រីដែលមានផ្ទៃពោះ។ សំណួរ<ទី១>របស់ខ្ញុំ <ចំពោះស្ត្រី>នីមួយៗ <ដែលមាន>លេខរៀង<នៅក្នុងបញ្ជី>ដែលខ្ញុំបានដាក់ជាលេខពណ៌ ដើម្បីប្រតិចារឹក គឺយើងនឹងអាចរកឃើញឈ្មោះស្ត្រីទាំងអស់នេះ នៅលេខរៀង១៤៧ ដល់១៤៩, ១៥១, ១៥៦ ដល់១៥៧, ១៥៩ និង១៦៧ និង១៦៩ ដល់១៧០ គឺនៅលើបញ្ជី<>អ្នកទោសដែលគេយកទៅសម្លាប់ចោលនេះឯង គឺឯកសារ E3/10506។

[១៣:៣៥:៤៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ លោកប្រធាន ទៅនឹងអ្វីដែលនឹងកំពុងតែធ្វើនៅពេលនេះ។ ខ្ញុំយល់ឃើញថា ជាឯកសារដែលមិនទាន់បានបកប្រែនៅឡើយ។ ហើយយើងខ្ញុំក៏ធ្លាប់បានប្រើប្រាស់ឯកសារមិនទាន់បកប្រែពីមុននោះដែរ។ ក៏ប៉ុន្តែយ៉ាងហោចណាស់ ក៏ដើម្បីបង្កលក្ខណៈឲ្យខ្ញុំតាមដានឯកសារនេះបានដែរ។ <គាត់និយាយ>ថា<មានការ>ជាប់ទាក់ទងគ្នា រវាងបញ្ជី<>មុន <និងបញ្ជីនេះ>។ ខ្ញុំមិនអាចនៅអង្គុយស្ងៀមនៅទីនេះ ដោយមិនអាច<និយាយអ្វីទាំងអស់បាននោះទេ។ យើងទាំងអស់គ្នាគួរតែអាចបញ្ជាក់នូវអ្វីដែលសហព្រះរាជអាជ្ញានិយាយ ហើយពេលនេះ ខ្ញុំមិនអាចធ្វើបានទេ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងហើយ គឺថាត្រូវស្នើសុំដាក់ឯកសារនេះ<បញ្ចាំង> ដើម្បីឲ្យធនធានរបស់តុលាការយើងផ្នែកអាយ.ធី.យូ អាចជួយបកប្រែបាន។

**លោក ខេល លីសាក់៖**

យើងខ្ញុំអាចដាក់ ស្នើសុំដាក់បញ្ចាំងនៅលើអេក្រង់។ ដោយសារដូច្នេះឯង បានជាយើងខ្ញុំស្នើសុំឲ្យ ស្នើសុំពេលវេលាដើម្បីធ្វើការបកប្រែ។ <ខ្ញុំបានចំណាយពេលធ្វើការលើអ្វីដែលមេធាវីការពារក្ដីបានសួរនោះហើយលោកប្រធាន> ឥឡូវនេះយើងពិនិត្យមើលទាំងអស់គ្នាសិន ហើយថាតើបញ្ជីនេះ វាជាប់ទាក់ទងទៅនឹងបញ្ជីមុនដែរឬក៏អត់។ <ជាការពិតណាស់> យើងគឺថាឥឡូវនេះ រំពឹងទៅលើ<អ្នកនិយាយភាសាខ្មែរនៅក្នុងក្រុមយើង ដើម្បីឲ្យជួយយើងកំណត់អត្តសញ្ញាណមនុស្សទាំងអស់នេះ។ ចំណែកឯខាងមេធាវីការពារក្ដី ក៏មានអ្នកនិយាយភាសាខ្មែរផងដែរ>។ ខ្ញុំក៏មិនមានជំហរអ្វីខុសគ្នាពីមេធាវី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ការពារក្តីដែរ។

[១៣:៣៧:១៦]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<អត់ទេ> យើងត្រូវ<ការស្តាប់ការតវ៉ារបស់លោក>--

**លោក ខេល លីសាក់៖**

<បាទ។>

**<ចៅក្រម ក្លូឌា ហ្វេនស៍៖>**

<ផ្អែកលើមូលដ្ឋានអ្វី? លើមូលដ្ឋានឯកសារទាំងអស់នេះឬ?>--

**<លោក ខេល លីសាក់៖>**

<បាទ។>

**<ចៅក្រម ក្លូឌា ហ្វេនស៍៖>**

<-- ការតវ៉ាដែលលោកធ្វើនៅថ្ងៃនេះ។>

**<លោក ខេល លីសាក់៖>**

<បាទ។> យ៉ាងដូច្នេះឯង បានជាខ្ញុំបញ្ជាក់លេខឯកសារនេះជូន។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ដូច្នេះលោក កាំង ហ្កេកអ៊ាវ ខ្ញុំបានដាក់*ហាយឡាយ*លេខរៀងដែលខ្ញុំទើបតែអានឲ្យលោកស្តាប់អម្បាញ់មិញនេះ នៅលើបញ្ជីនេះ។ ខ្ញុំចង់សួរការកត់ត្រានៅត្រង់កូឡោនខាងស្តាំ<សម្រាប់ឈ្មោះស្ត្រីទាំងអស់នោះ>។ តើលោកអាចអានឲ្យអង្គជំនុំជម្រះស្តាប់បានទេ? ដោយចាប់ផ្តើមពីលេខរៀង ១៤៧ <នៅក្នុងបញ្ជីនេះ?> គឺថាសូមលោកអានកំណត់ត្រាដែលគេសរសេរនៅកូឡោនខាងស្តាំហ្នឹង ហើយនិងព្រមទាំងចំណារផងដែរ។

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ដំបូងខ្ញុំសូមជូនអានជូន កាលបរិច្ឆេទដែល មិត្តហ៊ុយ សរសេរសំបុត្រមកខ្ញុំ។ កាលបរិច្ឆេទដែល មិត្តហ៊ុយ សរសេរមកខ្ញុំ គឺថ្ងៃ០៧ ខែមេសា ១៩៧៧។ ហើយតទៅទៀត ខ្ញុំសូមអាននូវកាលបរិច្ឆេទនៅក្នុងទំព័រ៧២, ៧២ទំព័រមុន ទំព័ររបស់ខ្ញុំ។ ដំបូងខ្ញុំអានជូន ឈ្មោះ ឃាវ សៀត(ស្រី) អតីតដឹកជញ្ជូនជើងទឹក កម្ទេចថ្ងៃ០៧ ខែ៤ ៧៧។ ដូច្នេះបញ្ជូនមកកម្ទេចតែម្តង។ មនុស្សទាំងអស់នេះ

គឺត្រូវកម្ទេច នៅថ្ងៃ០៧ ខែ៤ ៧៧។ សរុបមកបញ្ជូនមកដល់ស-២១ ភ្នំពេញយកទៅកម្ទេច ឬក៏អាចនិយាយបានថា គេ មិត្តហ៊ា ចាត់ចែងដឹកចេញពី ដឹកចេញពីស្រែ ដឹកចេញពីនេះមកយកមកកម្ទេចនៅជើងឯកតែម្តង អត់ឆ្លងកាត់មកដល់ភ្នំពេញទេ ប្រសិនបើថាបាន។ ដូច្នេះតើមានព្រឹត្តិការណ៍ស្អី ខ្ញុំអត់ចាំទេ អត់ចាំទេ។

**លោក វ៉ិចទ័រ កូប៉េះ**

ដើម្បីប្រតិចារឹកគឺថាខ្ញុំមិនអាចតាមនូវអ្វីដែលសាក្សីនិយាយនេះបានទេ។ ខ្ញុំឃើញនៅលើអេក្រង់ <នូវកំណត់ត្រាមួយ ដែលមិនអាចអានបាននៅលើទំព័រ>៧២។ <មិនដឹងថាពិត ឬមិនពិតនោះទេ> ខ្ញុំមិនអាចផ្ទៀតផ្ទាត់បានទេ។ ប៉ុន្តែខ្ញុំសូមជំទាស់ទៅនឹងរបៀបដែលយើងកំពុងតែដាក់បង្ហាញឯកសារ។

[១៣:៤១:៣៣]

**ចៅក្រម ក្លូឌា ហ្វេនស៍**

ប៉ុន្តែលោកមេធាវី លោកមានមេធាវីជាតិដើម្បីជួយដល់លោកបានតើ។

**លោក វ៉ិចទ័រ កូប៉េះ**

<បាទ ប៉ុន្តែខ្ញុំត្រូវការតាមដានដោយខ្លួនឯងផងដែរ។> ខ្ញុំជាមេធាវីអន្តរជាតិ អ៊ីចឹងក៏ខ្ញុំចង់តាមដានដែរ។

**ចៅក្រម ក្លូឌា ហ្វេនស៍**

ចុះលោកមិនសហការគ្នាទៅ ជួយប្រាប់គ្នាទៅ។

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំមានការកត់សម្គាល់ឃើញថា មិនមានការនិយាយដូច្នេះទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍**

អ៊ីចឹងលោកសហព្រះរាជអាជ្ញារងអន្តរជាតិ លោកដោះស្រាយបញ្ហានេះទៅ។

**លោក ឌេល លីសាក់**

<ទុកឱ្យខ្ញុំជួយ។ មូលហេតុដែល>ខ្ញុំរកឃើញបញ្ជីនេះ គឺ<ដោយសារតែដំបូងឡើយ>យើង<ផ្ទូឈ្មោះទាំងនេះទៅនឹងការបកប្រែ>នៅក្នុងបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត។ អ៊ីចឹង<ដើម្បីជាការ>ឆ្លើយតបទៅនឹងមេធាវីការពារក្តី <ខ្ញុំសូមផ្តល់ឱ្យលោកនូវ>លេខរៀងដែល<>ស៊ីចង្វាក់គ្នា<សម្រាប់ស្ត្រីទាំងអស់នេះ>ជាមួយនឹងបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត។ ទី១ គឺឈ្មោះដែលមាននៅលើបញ្ជី

របស់ ហ៊ុយ <គឺបញ្ជី>ស្ត្រីដែលមានផ្ទៃពោះ<១២នាក់> ដែលមានលេខ៣៣៣៩ នៅលើបញ្ជីរបស់ ក.ស.ច.ស។ លេខ២ នៅលើបញ្ជីរបស់ ហ៊ុយ <មាន>លេខរៀង៣៣៤៣ <នៅក្នុងបញ្ជី>របស់ ក.ស .ច.ស។ លេខ៣ ស្ត្រីដែលមានផ្ទៃពោះនៅលើបញ្ជីរបស់ ហ៊ុយ គឺនៅលើបញ្ជីរបស់ ក.ស.ច.ស មាន លេខរៀង៣៣៥១។ លេខ៤ <នៅក្នុងបញ្ជីឈ្មោះ>ស្ត្រីដែលមានផ្ទៃពោះគឺថា មានលេខរៀងនៅលើ បញ្ជីរបស់ ក.ស.ច.ស ៣៣៥៩។ ហើយលេខ៥ នៅលើបញ្ជីរបស់ ហ៊ុយ <ដែលនិយាយអំពីស្ត្រីមាន ផ្ទៃពោះ> មានលេខរៀង៣៣៦២ <ក្នុងបញ្ជីរបស់>ក.ស.ច.ស។ លេខ៦ ស្ត្រីដែលមានផ្ទៃពោះនៅលើ បញ្ជីរបស់ ហ៊ុយ នៅលើបញ្ជីរបស់ ក.ស.ច.ស មានលេខ៣៣៤០។ លេខ៧ នៅលើបញ្ជីស្ត្រីមានផ្ទៃ ពោះរបស់ ហ៊ុយ មានលេខរៀង៣៣៦១ <ក្នុងបញ្ជី>របស់ ក.ស.ច.ស។ លេខ៨ គឺមានលេខរៀងនៅ លើបញ្ជី ក.ស.ច.ស ៣៣៤៩។ លេខ១០ មានលេខរៀង៣៣៤៨ ក.ស.ច.ស។ លេខ១១ បញ្ជីស្ត្រី ដែលមានផ្ទៃពោះពី ហ៊ុយ នោះគឺមានលេខរៀង៣៣៤១ ក.ស.ច.ស។ <ខ្ញុំនឹងកត់សម្គាល់ដែរថា មាន> ស្ត្រីដែលមានផ្ទៃពោះ<តែម្នាក់គត់ ដែលយើងមិនបានរកឃើញ>នៅ<ក្នុង>បញ្ជីរបស់ ស-២១នោះគឺ លេខ៩ <ឈ្មោះ សៅ សុវណ្ណារី ដែល>បើយើងមើលបញ្ជីរបស់ ហ៊ុយ យើងឃើញមានចំណារបន្ទាប់ ទៅនឹងឈ្មោះរបស់គាត់ថា "អត់ឃើញ"។ លេខ៩ គឺជាស្ត្រីតែម្នាក់គត់ដែល<បញ្ជាក់>ថា អត់បាន ឃើញទេ <គឺជាមនុស្សតែម្នាក់គត់ដែលមិនមាន>នៅ<ក្នុង>បញ្ជីរបស់ ក.ស.ច.ស <និងមូលដ្ឋាននៃ បញ្ជី>សម្លាប់<ដែលសាក្សីបានកំណត់អត្តសញ្ញាណរួចហើយ>។

[១៣:៤៤:៤៣]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក កាំង ហ្គេកអ៊ាវ ចំណារយោងនៅ*កូឡឹម* ខាងស្តាំសម្រាប់ស្ត្រីទាំងអស់នេះថា "បាន សម្លាប់ចោលអស់ហើយ"។ តើចំណារ ឬក៏ការសរសេរដោយដៃថា បាន "*ស្មាស*" នេះ – "កម្ទេច" នេះ មានន័យថា សម្លាប់ហ្នឹងអស់ហើយ ឬក៏យ៉ាងណា?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ចំណារជាអក្សរខ្មែរ ពាក្យ "កម្ទេច" នេះបានន័យថា សម្លាប់រួចហើយ។ ដូច្នេះគេសម្លាប់ ហើយ។ ហើយអក្សរនេះ គឺជាអក្សរ មិត្តហ៊ី បើតាមខ្ញុំចាំ តាមខ្ញុំចំណាំ។ ឥឡូវខ្ញុំឃ្លាត ភ្នែក ពីភ្នែកខ្ញុំ អក្សរ មិត្តហ៊ី ប៉ុន្មានឆ្នាំហើយតាំងពី២០១២មក។

**ស៖** សំណួររបស់ខ្ញុំសួរថាអ៊ីចេះ តើគេប្រើពាក្យ "កម្ទេច"ហ្នឹង សរសេរពេញតែម្តង ឬក៏គ្រាន់

តែសរសេរដាក់ថា "កំ" អ៊ីចឹង "កំ"អ៊ីចឹង? តើពាក្យនេះឈរ ឬក៏ពាក្យនេះ សំដៅមានន័យថាម៉េច?

**ឆ៖** អរគុណ។ ពាក្យ "កំ" នេះសរសេរជំនួសពាក្យ "កម្មេច"។ បើសរសេរឲ្យពេញ វាវែងពេក វាយូរពេក ម្ល៉ោះហើយគេសរសេរ "កំៗ" ចប់។

[១៣:៤៦:៥៦]

**ស៖** ខ្ញុំបានកត់សម្គាល់ឃើញនៅក្នុងរបាយការណ៍ដែល ហ៊ុយ ផ្ញើមកចុះថ្ងៃទី០៧ មេសា ១៩៧៧។ យ៉ាងហោចណាស់ក៏ស្ត្រីដំបូងបំផុតនៅកូឡោន<ខាងស្តាំ>នេះ គឺថាគេបានរៀបរាប់ថា មានផ្ទៃពោះហ្នឹងជិតគ្រប់ខែទៅហើយ។ ហ្នឹងបើសិនណាជាមើលទៅលើ<កូឡោនខាងស្តាំនៃ>ឯកសារ E3/2047 គឺមានប្រើពាក្យថា "មានផ្ទៃពោះស្ទើរតែជិតគ្រប់ខែទៅហើយ"។ តើលោកដឹងទេ ឈ្មោះនៅខាងក្រោមឈ្មោះស្ត្រីម្នាក់នេះ ដែល ហ៊ុយ រាយការណ៍ថា ស្ត្រីម្នាក់ទៀតក៏មានផ្ទៃពោះជិតនឹងគ្រប់ខែទៅហើយ?

**ឆ៖** ស្ត្រីដែលមានផ្ទៃពោះជិតគ្រប់ខែ ហើយដែលមានក្នុងបញ្ជីយកទៅកម្មេចនេះ ទាំងអស់ប្រាំបីនាក់។ ឈ្មោះខាងលើនេះ គេសរសេរពេញ ហើយខាងក្រោមមកគ្រាន់តែសរសេរដូចៗៗ។ ដូច្នេះបានន័យថា ប្រាំបីនាក់ទាំងអស់ មិនមែនម្នាក់តែខាងលើហ្នឹងទេ។

**ស៖** លោកសាក្សី តើមានហេតុផលអ្វីដែលស្ត្រីប្រាំបីនាក់ មានផ្ទៃពោះជិតគ្រប់ខែទៅហើយ ត្រូវបានបញ្ជូនចេញពីព្រៃសមក យកទៅសម្លាប់ចោលនៅឯជើងឯក? គេមានមូលហេតុអីដែរ បានជាយកស្ត្រីមានផ្ទៃពោះជិតគ្រប់ខែទៅហើយទាំងនេះ យកទៅសម្លាប់ចោល?

**ឆ៖** រឿងនេះ ខ្ញុំមិនចាំទេ។ រឿងនេះ ខ្ញុំអត់ចាំទេ។

**ស៖** តើនេះគឺជាការអនុវត្តនៅឯគុកព្រៃសឬ នៅពេលដែលអ្នកទោសឈឺធ្ងន់មិនអាចធ្វើការបាន ហើយក្នុងករណីនេះ ស្ត្រីដែលមានផ្ទៃពោះស្ទើរតែគ្រប់ខែទៅហើយ ហើយមិនអាចធ្វើការបាន ទើបសម្រេចយកទៅសម្លាប់ចោលដូចអ្នកដែលបាត់បង់កម្លាំងពលកម្មអ៊ីចឹងដែរ?

**ឆ៖** គោលការណ៍អស់នេះ ខ្ញុំជម្រាបដោយត្រង់ចុះ។ ភ្លេចអស់ហើយ វង្វេងអស់ហើយ។

[១៣:៥០:១៥]

**ស៖** តើលោកនៅនឹកឃើញទេ ហ៊ុយ នេះបានបញ្ជូនរបាយការណ៍ដែលបញ្ជាក់អំពីស្ត្រីដែលមានផ្ទៃពោះ ឬស្ត្រីមានផ្ទៃពោះស្ទើរគ្រប់ខែហ្នឹង ញឹកញាប់ប៉ុន្មានដងដែរ?

**ឆ៖** ខ្ញុំអត់ចាំទេ ប៉ុន្តែទន្ទឹមនេះ ខ្ញុំសូមលើកបញ្ហាមួយ គឺសក្ខីកម្មនៅទីនេះ ពេលដែល ក្នុងពេល

ដែលសវនាការដេញដោលសំណុំរឿងលេខ០០១។ មានសាក្សីម្នាក់ឈ្មោះ ប៊ូ ថុន ស្រីមេម៉ាយ គាត់និយាយពីរឿងពេលដែលគាត់រៀបឆ្លងទន្លេគេដឹកឡាន យកមកសម្រាលកូននៅភ្នំពេញ។ ដូច្នេះនេះជារឿងដែលខ្ញុំនៅចាំ។ ហើយក៏ខ្ញុំគិតថា ខ្ញុំចាំបានតែរឿង មួយរឿងហ្នឹងឯង។ ឯចំណែករឿងនេះ វាពិតជាមានកើតមែន ប៉ុនជាគោលការណ៍យ៉ាងម៉េចស្អីយ៉ាងម៉េច ខ្ញុំវង្វេងអស់ហើយ វាយូរពេក។

**ស៖** នៅផ្នែកខាងក្រោមបំផុតនៃបញ្ជីនេះ គឺបញ្ជីរបស់ ហ៊ុយ ស្ដីពីស្ត្រីមានផ្ទៃពោះ មានអក្សរសរសេរដោយដៃថា "ក្នុងចំណោមអ្នកទាំងអស់នេះ ក៏<អាច>មានក្មេងតូចៗផងដែរ"។ តើលោកនៅចាំអក្សរ សរសេរដោយដៃនេះទេ ជាអក្សររបស់អ្នកណា? អ្នកណាជាអ្នកសរសេរអក្សរនេះ ថាក្នុងចំណោមស្ត្រីទាំងនេះក៏មានកូនក្មេងផងដែរ?

**ឆ៖** សូមបញ្ជាក់ជូនលោកព្រះរាជអាជ្ញាថា អក្សរមិត្តហ៊ុយ ខ្ញុំអត់មានចាំទេ ទម្រង់អក្សរមិត្តហ៊ុយ។ បើជាម្ចាស់នៃរាយការណ៍នេះ ឯកសារនេះទាំងមូលគឺ ហ៊ុត -- ហ៊ុយ។

**ស៖** លោកសាក្សី លោកដឹងទេ ថាមានអ្វីកើតឡើងទៅដល់កូនក្មេងតូចៗ <របស់>ស្ត្រី<ទាំងនោះ នៅពេលដែលស្ត្រីទាំងនោះត្រូវបាន>គេយកទៅសម្លាប់ចោលហ្នឹង <តើមានអ្វីកើតឡើងចំពោះ> កូនតូចៗ<>ហ្នឹង<>?

[១៣:៥៣:០១]

**ឆ៖** រឿងនេះ វាចូលក្នុងរឿងដែលខ្ញុំបានបញ្ជាក់ ពីរឿងកុមារដែលជាកូនរបស់ជនក្បត់។ ជាគោលការណ៍ គឺកូនក្មេងរបស់ជនក្បត់ដែលមិនទាន់ពេញវ័យ គឺគេយកទៅកម្ទេច បើសិនជាម៉ែឪក្បត់ម៉ែឪក្បត់។ នេះវាជាគោលការណ៍រួមដែលយើងខ្ញុំអនុវត្តនៅពេលនោះ តាមការណែនាំរបស់បក្ស។ ហើយដូចជាពេលណាមួយ ខ្ញុំបានឆ្លើយចំពោះតុលាការ ថាបើបញ្ហានេះ មិនមែនជាគោលការណ៍របស់បក្សទេ អ្នកឯងរកមើលទៅ តើនៅសម័យ ប៉ុល ពត សម័យខ្មែរក្រហម មានមន្ទីរចិញ្ចឹមកុមារកំព្រាប៉ុន្មាននាក់? ដូច្នេះរឿងនេះ វាបញ្ជាក់ថាពេលនោះទ្រឹស្ដីដែលឪពុកម្ដាយក្បត់ កូនគេត្រូវយកទៅកម្ទេច។ រួចក្រោយមកក្នុងពេលសវនាការដេញដោលនេះផង ឬក៏នៅក្នុងសម័យនែ៎ ស៊ើបអង្កេតក៏មិនដឹង គេសួរខ្ញុំ តុលាការសួរខ្ញុំ។ អេ្ហ! ចុះម៉េចក៏កូននេះនែ៎ មិនអី? ខ្ញុំថា កូនបង ម៉ម ណៃ ម៉ែឪវាជាកម្មាភិបាល ដូច្នេះវាត្រូវគេរក្សាចិញ្ចឹមបីបាច់ ជាកូនរបស់កម្មាភិបាល អត់បានទៅរៀន គិតតែទៅចាប់កណ្ដុរនៅស្រែស្អី១១១ហ្នឹង ជារឿងកូនកម្មាភិបាល ក៏ប៉ុន្តែបើបង ម៉ម ណៃ ក្បត់អាហ្នឹងកូនហ្នឹងក៏យកទៅដែរ។ ដូច្នេះគោលការណ៍ឲ្យតែម៉ែឪក្បត់ គឺកូនក៏គេយកទៅ។ និយាយឲ្យចំ ឲ្យតែមេគ្រួសារគឺមនុស្សប្រុស

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក្បត់ហើយ គេចាប់ហើយ ប្រពន្ធក៏គេយកទៅ កូនក៏គេយកទៅ។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំសូមចូលទៅគ្រួសារមួយទៀតដែលមាននៅក្នុងបញ្ជីស-២១ផងដែរ។ លោកប្រធានសូមជូនឯកសារនេះទៅឲ្យសាក្សីពិនិត្យមើល គឺឯកសារ E3/3187– E3/3187។ ជាពិសេសទំព័រនៅត្រង់បញ្ជីនេះជាERN ជាខ្មែរ 00008758 ដល់ 59 ហើយអង់គ្លេស 00874194 ដល់ 96។ បាទ សូមការអនុញ្ញាតបង្ហាញបញ្ជីមួយនេះទៅឲ្យសាក្សីពិនិត្យមើលលោកប្រធាន។

[១៣:៥៦:២៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ឯកសារទី១ ដែលឲ្យលោកពិនិត្យមើលនោះ គឺថាបញ្ជីអ្នកទោសដែលត្រូវបានសម្លាប់នៅខែធ្នូ ១៩៧៦។ ឥឡូវនេះខ្ញុំនឹងសួរលោកពីមនុស្សមួយចំនួននៅលើបញ្ជីនេះ ដែលត្រូវបានគេរកឃើញថាគឺជាសមាជិកគ្រួសាររបស់ ទូច សេងអេង ដែលជាប្រធានអ្នកកសាងផ្លូវ គឺ តឹក សេងអេង ប្រធានអ្នកថែទាំកសាងផ្លូវ <ដែលបញ្ជាក់ថា មកពីអង្គភាពផ្លូវដែក>។ បើលោកមើលបញ្ជីនេះ មើលលេខ៧៧គឺឈ្មោះ តឹក សេង -- ប្រពន្ធរបស់ តឹក សេងអេង ឈ្មោះ ណៃ ស៊ីម ដែលបានចូលមកស-២១ នៅថ្ងៃទី ១៩ ធ្នូ ៧៦ នៅឆ្នាំ១៩៧៦ ដែលត្រូវបានសម្លាប់ចោលនៅថ្ងៃទី២៨ ខែធ្នូ ៧៦។ <នៅក្នុងបញ្ជីដដែលនេះបើលោកមើលនៅលើទំព័រជាមួយគ្នានោះ> គឺខ្ញុំបាន*ហាយឡាយ*ឈ្មោះទាំងនេះរួចហើយ។ ក្នុងនោះមានកូនប្រាំមួយនាក់នៃប្តីប្រពន្ធនេះ មានលេខពី៦៥ដល់៦៩ នៅលើបញ្ជីនេះគឺថាមានកូនស្រីប្រាំនាក់របស់ តឹក សេងអេង ដែលបានចូលមកស-២១ជាមួយម្តាយរបស់គេនៅថ្ងៃទី១៩ ខែធ្នូ។ តឹក គាំវាសី <>លេខរៀងទី៦៦។ អេង វុទ្ធី លេខ៦៧។ អេង រស្មី <> លេខ៦៨ និងលេខ៦៩ ឈ្មោះ អេង វុត្ថា <អ្នកទាំងអស់នេះ>ត្រូវបានសម្លាប់<នៅ៦ថ្ងៃក្រោយពីពួកគេបានទៅដល់ គឺ>នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៦ គឺថាទាំងអស់នេះតែម្តង។

<កូនស្រីម្នាក់>ក្នុងចំណោម<កូនស្រី>ទាំងនេះ<មាននៅក្នុងរូបថត ស-២១> គឺឯកសារ E3/8639.1064 ខ្ញុំសូមអាចឡើងវិញ E3/8639.1064 បាទ E3/8639.1064 គឺជារូបថតមកពីស-២១ របស់កុមារ អេង រស្មី ដែលជាកូនស្រីរបស់ តឹក សេងអេង ម្នាក់ក្នុងចំណោមកូនគាត់ទាំងប៉ុន្មាននាក់នេះ។ បាទសូមការអនុញ្ញាតបង្ហាញរូបថតនេះ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៣:៥៩:៥១]

ហើយឈ្មោះចុងក្រោយដែលខ្ញុំចង់សួរ គឺលេខ៦១ នៅបញ្ជីដែលខ្ញុំឲ្យលោកដដែលនេះ។ ឈ្មោះ អេង សារដ្ឋ ក៏ត្រូវបានគេរកឃើញថា ជាកូនរបស់ តឹក សេងអេង ដែរ ហើយចូលមកស-២១ នៅថ្ងៃទី ១៩ ធ្នូ ៧៦ និងសម្លាប់ចោល២ថ្ងៃក្រោយមក គឺនៅថ្ងៃទី២១ ខែធ្នូ ១៩៧៦។ ក្នុងនេះ ក៏យើងមានរូបថត នៅស-២១ របស់កុមារម្នាក់នេះដែរ។ ហើយរូបថតថ្មីៗដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបាន គឺ ឯកសារ <E394.1> នៅត្រង់ទំព័រ <P01223708> ដល់09។ ហ្នឹងក៏មានដាក់ទៅឲ្យលោកនៅក្នុង កញ្ចប់ ឯកសារដែលជូនទៅលោកនេះដែរ គឺជារូបថតរបស់ក្មេងប្រុសម្នាក់។ ឥឡូវសូមបង្ហាញរូបថត ក្មេងប្រុសម្នាក់នេះផង។ រូបថតរបស់គាត់ គឺមានលេខរៀងទី១២០ នៅលើបញ្ជី<រូបថត>ថ្មីរបស់ មជ្ឈមណ្ឌលឯកសារកម្ពុជា។ ដើម្បីជាប្រតិចារឹក គឺថាគេ<សរសេរ>នៅខាងខ្នងរូបថតនេះ របស់ អេង សារដ្ឋ ជាកូនប្រុសរបស់ តឹក សេងអេង ដោយមានកាលបរិច្ឆេទ គឺ១៩ ធ្នូ ៧៦។ នេះ ថ្ងៃខែនេះគឺ ស៊ីសង្វាក់គ្នាទៅនឹងថ្ងៃខែពី ស-២១ហើយ។ ហើយរូបថតដូចគ្នាដែរគឺ E3/8639 – E3/8639 និង E3/8639.283។

សំណួររបស់ខ្ញុំមុនពេលយើងឃើញរូបថតនៅលើអេក្រង់ គឺអ៊ីចេះ លោកសាក្សី។ នៅក្នុងបញ្ជី នេះ <និងក្នុងបញ្ជីផ្សេងទៀត> គឺមានឈ្មោះមនុស្ស<សំខាន់ៗមួយចំនួន>មកពីខាងផ្លូវរថភ្លើង គឺ បញ្ជូនមក<ស-២១>នៅចុងឆ្នាំ១៩៧៦ រួមទាំងក្រុមគ្រួសារ នេះគឺថាមកទាំងគ្រួសារតែម្តង។ បាទ ដូច្នេះសូមការអនុញ្ញាត យើងឃើញគឺលេខរៀង១២០។ ឃើញហើយ នេះគឺជារូបថតរបស់កុមារា អេង សារដ្ឋ ដែលមានឈ្មោះនៅលើបញ្ជីនេះ។ តើលោកនៅចាំទេថា ហេតុអ្វីបានជាសមាជិកគ្រួសារទាំងមូល តែម្តងត្រូវបានគេបញ្ជូនមកពីខាងផ្នែកផ្លូវរថភ្លើងមកស-២១ នៅចុងឆ្នាំ១៩៧៦នោះ?

[១៤:០៣:១២]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ខ្ញុំមិនចាំទេ។

**ស៖** ចំណុចចម្បងដែលខ្ញុំចង់សួរអំពីក្រុមគ្រួសារនេះ លោក កាំង ហ្កេកអ៊ាវ ដូចដែលខ្ញុំទើបតែ បានបញ្ជាក់អម្បាញ់មិញ ក្មេងៗទាំងអស់នោះ ត្រូវបានសម្លាប់ចោលទាំងអស់។ បានន័យថា ក្នុងរយៈ ពេលមួយអាទិត្យក្រោយពីគាត់ចូលមកដល់ស-២១។ ក្នុងលេខ<៦៥>នោះ <បញ្ជីស-២១បញ្ជាក់ថា នៅថ្ងៃជាមួយគ្នា ដែលបងប្អូនស្រីរបស់នាងត្រូវបានគេសម្លាប់ចោល នាងបាន>ធ្វើអត្តឃាតដោយចងក

សម្លាប់ខ្លួន។ <បើយើងមើលទៅលើលេខរៀង៦៥ គឺ អេង ម៉ាគារីន> ហើយបុគ្គលម្នាក់នោះ គឺត្រូវបានបង្ហាញថា គាត់ចងកសម្លាប់ខ្លួន នៅក្នុងថ្ងៃទី<២៥> ខែធ្នូ ឆ្នាំ៧៦។ ថាអ្វីដែលខ្ញុំចង់សួរ ឪពុកឈ្មោះ តឹក សេងអេង គាត់បានចូលស-២១ <មុនកូនៗរបស់គាត់ គឺ>នៅថ្ងៃ១៦ ខែធ្នូ ឆ្នាំ៧៦ ក៏ប៉ុន្តែ <គាត់មិនត្រូវបានសម្លាប់ទេ រហូតដល់>ជាង៩ខែក្រោយមក គឺនៅថ្ងៃ១៩ ខែកញ្ញា ឆ្នាំ៧៧។ លោក លោកស្រីចៅក្រម <ដើម្បីប្រតិចារឹក> នៅក្នុងកំណត់ហេតុនោះ គឺបានបង្ហាញថា តឹក សេងអេង ឃើញនៅក្នុងឯកសារ E3/2285។ ខ្មែរគឺបញ្ជីអ្នកទោសសម្លាប់ចោលនៅថ្ងៃទី១៩ ខែ<កញ្ញា> ឆ្នាំ<៧៧>។ ខ្មែរគឺ 00009083 ដល់85, ហើយអង់គ្លេស គឺ 00873172 នៅក្នុងជួរលេខ៧៩ នៅក្នុងបញ្ជីនោះ ខ្មែរគឺ 00009083 ដល់85។ <ដូច្នេះសំណួររបស់ខ្ញុំគឺ> កូននិងម្ដាយត្រូវបានសម្លាប់ភ្លាមៗក្រោយចូលស-២១ ក៏ប៉ុន្តែឪពុកគឺមិនទាន់ត្រូវបានសម្លាប់ចោលទេ រហូតជាង៩ខែក្រោយមក ទើបគេយកឪពុកនោះទៅសម្លាប់ចោល។ ហេតុអ្វីបានជាដូច្នេះ?

**ឆ៖** ខ្ញុំក្លាប់មិនបានទេ រឿងអស់នេះ។ ចូលសាច់ការជាក់ស្តែង ខ្ញុំក្លាប់មិនបាន។

[១៤:០៦:១០]

**ស៖** ខ្ញុំសួរលោករបៀបនេះវិញ លោកសាក្សី លោកបានផ្ដល់សក្ខីកម្មថា ជាធម្មតាកូននិងម្ដាយមិនត្រូវបានគេសួរចម្លើយនោះទេ។ នៅពេលដែលគេយកប្រពន្ធនិងកូនចូលមកស-២១ ហើយមិនត្រូវបានសួរចម្លើយនោះ តើគេទុកឲ្យគាត់រស់សិនក្នុងអំឡុងពេលគេសួរឪពុក ឬក៏គេបញ្ជូនគាត់ទៅណា ទៅទីកន្លែងផ្សេងមុនពេលដែលគេបញ្ចប់សួរចម្លើយឪពុក?

**ឆ៖** គ្មានក្រឹត្យក្រមមួយជាទៀងទាត់ទេបញ្ហានេះ។ ឯចំណែកអារម្មណ៍ខ្ញុំ ជម្រាបលោកប្រធាន នៃលោកព្រះរាជអាជ្ញាដោយត្រង់ អំពីរូបថតនេះ ខ្ញុំដូចជាមិនច្បាស់សោះថា ក្រោយខ្នងរូបថតនេះមានចារតាំងពីសម័យមុន០៧ មករា ខ្ញុំដូចមិនច្បាស់លាស់ក្នុងចិត្តសោះ។ តើការសរសេរខ្នងរូបថតនេះ គេចារក្រោយ០៧ មករា ឬមុន ០៧ មករា? ខ្ញុំអត់ទាន់ជ្រះស្រឡះក្នុងចិត្តទេ កំពុងតែចាប់អារម្មណ៍ក្នុងមួយរឿងនេះមួយ ព្រោះខ្ញុំអត់បានមើលរូបថតស្អីៗទេ។ ក៏ប៉ុន្តែដល់ឃើញអ៊ីចឹង អាលេខចាស់ហើយមាន ស្រាប់តែមានលេខថ្មីមួយមកទៀត។ តើវាយ៉ាងម៉េចអាហ្នឹង?

រួចលេខនេះយ៉ាងម៉េច? ស-២១ធ្វើ ឬក៏អ្នកផ្សេងទៀតគេធ្វើ អាលេខថ្មីនេះ ដែលបិទនេះ? រួចគេម៉េចបានគេធ្វើ? នេះជាបញ្ហាមួយ។ រួចឈ្មោះមនុស្សទាំងប៉ុន្មាននេះ ខ្ញុំនៅតែគិត តើមានក្នុងបញ្ជីអ្នកទោសស-២១ ដែលការិយាល័យសហព្រះរាជអាជ្ញាធ្វើឡើង ទាំងអស់មានចំនួនអ្នកទោស១២.០០០នាក់

ជាង ឬក៏ជាឈ្មោះថ្មី? ខ្ញុំអត់ទាន់ជ្រះស្រឡះបញ្ហាហ្នឹង។ នេះអារម្មណ៍ខ្ញុំកំពុងតែគិតរឿងហ្នឹង។ ឯចំណែកគោលការណ៍យ៉ាងម៉េច យ៉ាងម៉ា ខ្ញុំអាចនិយាយបានថា អ្នកណាសំខាន់គេកម្ទេច -- គេសួរចម្លើយអ្នកនុ៎ង។ ឯចំណែកប្រពន្ធកូនគេទុកក្រោយ ចាំមើល តើអ្នកណាសំខាន់អាចយកមកសួរ តើអ្នកមិនសំខាន់ គេអាចបញ្ចេញចេញ។ អាហ្នឹងយើងអាចនិយាយប៉ុន្មាននុ៎ង។ ក៏ប៉ុន្តែរឿងដែលខ្ញុំចាប់អារម្មណ៍ ហើយកំពុងតែគិត រកគិតអីមិនទាន់ចេញផ្សេងទៀត គឺអារឿងហ្នឹង។ តើបញ្ជីនេះដកស្រង់ពីណា? ដកស្រង់ពីបញ្ជីអ្នកទោស ស-២១ ដែលការិយាល័យសហព្រះរាជអាជ្ញាធ្វើឲ្យខ្ញុំ ហើយយើងផ្ទៀងកាត់សម័យដេញដោលសំណុំរឿងលេខស-២១ទាំងមូល ឬយ៉ាងម៉េច ឬផ្សេង ឬថ្មី។ ហើយបញ្ជីនុ៎ង ហ្នឹងខ្ញុំនិយាយឲ្យត្រង់ទៅ ព្រះរាជអាជ្ញា វាំងសង់ លោកដឹងដែរ ការពេលដែលរៀបចំបញ្ជីនុ៎ង។

[១៤:០៩:៤៤]

**ស៖** លោកសាក្សី ខ្ញុំនឹងបង្ហាញកម្រងបញ្ជី<ថ្មី>ទាំងមូលតែម្តង កម្រងរូបថតដែលរកឃើញដោយមជ្ឈមណ្ឌលឯកសារកម្ពុជា <គឺបណ្តុំរូបថតថ្មី ក្រោយពីដំណើរការនីតិវិធីប្រឆាំងនឹងរូបលោក>។ មានរូបថតប្រហែលជា១.០០០ទៀតថ្មី ដែលថតក្នុងអំឡុង៧៦។ ប៉ុន្តែអត់មានស្លាក<ឈ្មោះ>ទេ មានសរសេរនៅខាងខ្នង។ ហើយមួយក្រុមទៀតនោះ គឺមានស្លាកដាក់ពីមុខ។ ខ្ញុំសូមបញ្ជាក់ថា សាក្សី<មក>ពី<ផ្នែក>រូបថត<បាន>និយាយថា អក្សរនៅខាងខ្នងនោះ គឺជាអក្សររបស់ខាងប្រធានថតរូបនៅពេលនោះ។ ខ្ញុំនឹងផ្តល់សៀវភៅទាំងមូល កម្រងសៀវភៅទាំងមូលដែលលោក<អាចមើលវាបាន។ ខ្ញុំអាចប្រាប់លោកផងដែរថា -- សូមទោសលោកចៅក្រម>។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំលើកឡើងចំណុចខ្លីមួយ។ មានបញ្ជីថ្មីមួយ លោកសាក្សី បញ្ជីអ្នកទោសថ្មីមួយដែលលោកមិនទាន់ ដែលបានឃើញកន្លងមកនេះ។ ហើយមានឯកសារមូលដ្ឋានមួយចំនួនផ្សេងដែលគាំទ្រទៅលើបញ្ជីហ្នឹង ហើយលោកនៅមិនទាន់ឃើញនៅឡើយនោះទេ។ បញ្ជីក្រោយនេះ គឺចងក្រងដោយចៅក្រមស៊ើបអង្កេតនាពេលថ្មីៗ ហើយដាក់ជូនអង្គជំនុំជម្រះសាលាដំបូងប៉ុន្មានខែមុននោះ។ ជាការពិតណាស់ គឺលោកបានកំពុងតែតទល់ជាមួយនឹងបញ្ជីថ្មី និងឯកសារគាំទ្រផ្សេងទៀត ដែលលោកមិនទាន់ដែលធ្លាប់បានឃើញកន្លងមក។

**លោក ខេល លីសាក់៖**

ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ដើម្បីជាប្រតិចារឹករបស់យើង។ រូបថតដែលមាននៅក្នុងនេះ គឺមាន

លេខនៅខាងមុខ ដែលបានបន្ថែមដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ដូច្នេះប្រសិនបើយើងមើលលេខតាមលំដាប់លំដោយនៅលើរូបថតនេះ គឺលេខលំដាប់លំដោយនោះគឺ ឌី.ស៊ី.ខេម ជាអ្នកដាក់តែប៉ុណ្ណោះ ហើយដែលបញ្ចូលនូវចំណុចហ្នឹងថ្មីសម្រាប់យើង។ ក៏ប៉ុន្តែនៅខ្នងរូបថត គឺជាចំណារ ឬក៏សរសេរអក្សរដើមតាំងពីសម័យនោះ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីយើងបានជជែកគ្នាអំពីកូនៗដែលមកជាមួយ ជាប់នឹងជាមួយឪពុកម្ដាយ។ កាលពីម្សិលមិញ ខ្ញុំបានបង្ហាញបញ្ជីប្រចាំថ្ងៃនៅស-២១ ហើយខ្ញុំនិងលើកឡើងសង្ខេបម្ដងទៀតលើឯកសារនេះជាមួយនឹងលោកសាជាថ្មី។ លោកប្រហែលជាអត់មានទេ បញ្ជីប្រចាំថ្ងៃហ្នឹង។ ខ្ញុំសូមផ្ដល់សាជាថ្មីជូនលោក ឯកសារ E3/8493 លោក លោកស្រីចៅក្រម គឺជាបញ្ជីគ្រប់គ្រងអ្នកទោសប្រចាំថ្ងៃចុះថ្ងៃទី១១ ខែមេសា ឆ្នាំ៧៦។ សូមអនុញ្ញាតពីលោកប្រធានផ្ដល់ជូនសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៤:១៣:១៥]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ផ្អែកនៅក្នុងបញ្ជីដែលខ្ញុំចង់សួរលោកនៅក្នុងថ្ងៃនេះ ប្រសិនបើលោកមើលទំព័រទី១ ក្នុងតារាងនុ៎ងដែលមានបង្ហាញចំនួនសរុប ដែលក្នុងនោះបានដាក់ថា អ្នកមកថ្មីគឺ៥៨នាក់។ ហើយក៏លោកឃើញចំនួនសរុបនៅក្នុងតារាងនោះផងដែរ។ យើងបង្ហាញអំពីក្មេងៗដែលមិនស្ថិតនៅក្នុងការឃុំខ្លួន។ ប្រសិនបើលោកបើកទៅទំព័រទី២ ចុះថ្ងៃ១១ ខែមេសា ៧៦ដូចគ្នា លោកនឹងឃើញបញ្ជីឈ្មោះ<មនុស្ស> ៣៣<នាក់>។ ហើយក្នុងនោះបានបញ្ជាក់ថា មកពី<ព្រែកដាច់> តំបន់<២៥ ដែលគេបញ្ជាក់ថា> ជា<អារ៉ាប់ ឬ>ប៉ាគីស្ថាន ឬក៏ជាជនជាតិឥណ្ឌា។ ហើយ<នៅចុងបញ្ចប់នៃបញ្ជីនេះ> លោកនឹងឃើញផងដែរ មានឃើញក្មេងៗប្រុស២០នាក់ ហើយនិងក្មេងស្រីប្រាំនាក់។ ហើយប្រសិនបើបូកនឹង បូកលេខ ៣៣, ២០ និង៥ សរុបទៅគឺ៥៨ ចំនួនសរុបអ្នកដែលមកចូលថ្មីនៅទីនោះ ដែលលោកឃើញចំនួនសរុបនៅក្នុងតារាងនោះឯង។ ខ្ញុំសូមសួរលោក ឲ្យលោកពន្យល់ជូនយើងខ្ញុំ។ ហេតុអ្វីបានជាក្មេង២៥នាក់នោះមិនបានបញ្ចូលឈ្មោះនៅក្នុងបញ្ជី ហើយដាក់ចំនួនសរុបទៅវិញ? ហេតុអ្វីបានមិនបញ្ចូលឈ្មោះក្មេងទាំង២៥នាក់នោះ? តើការអនុវត្តនោះ វាយ៉ាងម៉េចដែរ?

[១៤:១៥:២០]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា បញ្ជីពួកប៉ាគីស្ថាននេះ ខ្ញុំបានអធិប្បាយម្ដង នៅសម័យស៊ើបអង្កេត ហើយនិងសម័យ ជាពិសេសដូចជាសម័យសវនាការដេញដោលសំណុំរឿងលេខ ០០១។ ខ្ញុំបានសន្និដ្ឋានពីរឿង ណាត គាត់យកប្រជាជនកម្ពុជាដែលជាពួកមូស្លីម ចុងបញ្ចប់យកមកនៅតាខ្មៅ ហើយបានយកបញ្ចេញទៅ ទាំងអស់នេះ។ ដូច្នេះសរុបមក បើខ្ញុំមិនយល់ច្រឡំទេ មូស្លីមទាំងប៉ុន្មានដែលពីដើមរកស៊ីនៅភូមិអារ៉ាប់ ត្រូវគេយកមកកម្ទេច ម្ដងជម្លៀសទៅណោះ ម្ដងជម្លៀសទៅណោះ ម្ដងជម្លៀសទៅណោះ ត្រូវគេយកមកកម្ទេចនៅស-២១។ អង្កាល់នោះខែ២នេះ ខ្ញុំមិនទាន់ឡើងជាប្រធានទេ ប្រហែលជាទុកនៅតាខ្មៅ ហើយយកទៅកម្ទេច។ នេះខ្ញុំបានសន្និដ្ឋានរួចហើយ។ ដូច្នេះវាចូលទៅក្នុងគោលការណ៍ដដែល។ ម៉ែឪមានបញ្ហាហើយ ជាជនក្បត់ហើយ គេកម្ទេច។ ដូច្នេះបើប្រៀបធៀបរឿងមូស្លីមទាំងអស់នេះ ទៅនឹងសារទូរលេខមួយដែល បងភឹម ផ្ញើមក បងប៉ុល ក្រោយសារទូរលេខហ្នឹង។ ដូច្នេះវិធានការរបស់បក្សចំពោះពួកមូស្លីម គឺក្រោយពេលដែលចង់ដកពួកមូស្លីមចេញពីព្រំដែន ហើយនិងពីដងទន្លេ ត្រូវទៅពាយ័ព្យ ហើយនិងទៅឧត្តរ។ ដូច្នេះវារឿង រឿងមូស្លីម ហើយនិងបក្សកុម្មុយនីស្តកម្ពុជា។ សរុបមកវិញ ខ្ញុំនិយាយដដែល បើម៉ែឪគេដកហើយ ប្រពន្ធកូនក៏គេដកដែរ។ ដូច្នេះ ឬសួរ ឬក៏មិនបានសួរ ឬស៊ី១ អាហ្នឹងផ្សេង។ នេះជាវិធានការទាំងឈុត។ ខ្ញុំនិយាយទាំងឈុតរបស់បក្សកុម្មុយនីស្តកម្ពុជាទៅលើមូស្លីមកម្ពុជា។

**ស៖** នៅក្នុងការផ្ដល់សក្ខីកម្មលើកមុន ដែលលោកឆ្លើយថា អ្នកដែលមកពីភូមិមូស្លីម គឺអ្នកទាំងអស់ហ្នឹង មាននៅក្នុងបញ្ជីនេះឯង។ អ៊ីចឹងមែនដែរឬទេ? អ្វីដែលខ្ញុំយល់ហ្នឹង ត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំឆ្លើយសំដៅពួកមូស្លីមនៅភូមិអារ៉ាប់។ ភូមិនោះគេហៅ ភូមិអារ៉ាប់។ ឥឡូវមិនដឹងជាទៅស៊ីទៅវិញហើយទេ។ ពួកនោះរកស៊ីចិញ្ចឹមគោ។ នៅស្រុកខ្មែរអង្កាល់នោះ អាភូមិអារ៉ាប់ហ្នឹងនៅជាយៗក្រុងភ្នំពេញ។ ឥឡូវនេះមិនដឹងជាទៅជាស៊ីទៅហើយទេ។ ហើយដល់ពេលហ្នឹង ពេលជម្លៀសប្រជាជនចេញពីភូមិ គេដេញប្រជាជនទៅ ម្ដងជម្លៀសទៅដាក់ឯណោះ ម្ដងជម្លៀសទៅដាក់ឯណោះ ដល់ចុងបញ្ចប់បក្សឱ្យ ណាត ទៅប្រមូលយកមក។ ដូច្នេះនៅក្នុងរវាងខែ២ ៧៦ ហ្នឹង។ សរុបមក ខែ២ ៧៦ ហ្នឹង វាក្រោយថ្ងៃដែល បងភឹម សរសេរសំបុត្រ ទូរលេខមក បងប៉ុល ពីរឿងប្រជាជនមូស្លីម និងប៉ុន្មាន ៥០០.០០០នាក់នៅបូព៌ា។ ដូច្នេះជាវិធានការរបស់បក្សកុម្មុយនីស្តកម្ពុជាទៅលើពួកមូស្លីម ក្រោយ

ព្រឹត្តិការណ៍បូព៌ា។

[១៤:១៩:០៣]

**ស៖** ដើម្បីឲ្យខ្ញុំ -- ឲ្យយើងយល់ច្បាស់ទាំងអស់គ្នា នៅទំព័រទី២ ផ្នែកខាងលើ គឺសរសេរថា “<មនុស្សទាំងអស់នេះត្រូវបាននាំ>យកមកពីព្រែកដាច់”។ តើស្គាល់ទេ កន្លែងហ្នឹង <ព្រែកដាច់ហ្នឹងនៅឯណា>? គឺទីតាំងភូមិដែលលោកហៅអម្បាញ់មិញហ្នឹង ឬក៏ជាទីតាំងមួយផ្សេង?

**ឆ៖** អរគុណ។ ទីតាំងភូមិដែលខ្ញុំនិយាយមុននោះ គឺនៅជាយក្រុងភ្នំពេញ។ ឯចំណែកព្រែកដាច់ហ្នឹង ខ្ញុំបានបញ្ជាក់ហើយ ក្រោយ១៧មេសា ជម្លៀសប្រជាជនទូទៅចេញពីភ្នំពេញ។ ដូច្នេះវាត្រូវជម្លៀសទាំងពួកឥណ្ឌាពួកអីដែលនៅចិញ្ចឹមគោនៅភូមិអារ៉ាប់ យកទៅព្រែកដាច់។ ព្រែកដាច់ហ្នឹង មិនដឹងនៅម្តុំត្រង់ណាទេ។ ហើយចេញពីនេះទៅនោះ ចេញពីនោះទៅនោះ ប៉ុន្មានដំណាក់ហ្នឹង បានក្រោយមកបក្សឲ្យ ណាត ទៅប្រមូលយកមកទុកនៅតាខ្មៅ។ អានេះខ្ញុំសន្និដ្ឋានទេ មិនដឹងព្រឹត្តិការណ៍ហ្នឹងជាក់ស្តែងទេ។ ប៉ុន្តែគ្រាន់បើប្រៀបធៀបកាលបរិច្ឆេទ ខ្ញុំឃើញថា កាលបរិច្ឆេទហ្នឹងវាក្រោយព្រឹត្តិការណ៍ដែល បងភឹម ផ្ញើសារទូរលេខមួយទៅ បងប៉ុល ពីរឿងពួកមូស្លីម ប៉ុន្តែគាត់ហៅប្រជាជនអ៊ីស្លាម។ ក្រោយព្រឹត្តិការណ៍ហ្នឹងទេ។ សារហ្នឹងបើតាមខ្ញុំចាំ ដូចជាថ្ងៃ០២ វិច្ឆិកា ១៩៧៥។

[១៤:២០:៣៧]

**ស៖** សូមអរគុណលោកសាក្សីដែលបានលើកឡើង ដែលបានផ្តល់ព័ត៌មាននេះ។ ខ្ញុំសូមនិយាយជារួមអំពីក្មេងៗ ដែលបានយកមកចូលស-២១ ជាមួយនឹងឪពុកម្តាយ។ ក្រៅពីក្មេងបី ឬបួននាក់ដែលលោកបានបញ្ជាក់ថានៅរស់រានមានជីវិតនៅពេលដែលវៀតណាមចូលមកនោះ។ តើក្មេងផ្សេងទៀតដែលយកមកជាមួយឪពុកម្តាយ នៅពេលនោះត្រូវបានសម្លាប់ចោលតែម្តង ឬក៏យ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ទាំងក្មេង ទាំងចាស់ ដូចជារវាងថ្ងៃ០១ ពេលថ្ងៃ០៣ មកវានេះ ខ្ញុំចាំមិនច្បាស់ទេ ពូនួន ហៅខ្ញុំទៅបញ្ជាក់ឲ្យដកទាំងអស់ចេញ។ ដូច្នេះដែលហៅថាដកទាំងអស់ហ្នឹង គឺទាំងក្មេង ទាំងចាស់។ ឯចំណែកក្មេងៗហ្នឹងមក ហើយបញ្ជេញយកទៅទាំង មួយយូរៗម្តង យូរៗម្តង ចេញ។

**ស៖** បាទ ខ្ញុំសួរព័ត៌មានទូទៅក្នុងពេលដែលលោកជាអនុប្រធាន ឬក៏ជាប្រធានស-២១ គឺក្នុងពេលនោះទាំងស្រុងតែម្តង។ អំឡុងពេលហ្នឹង ពេលលោកជាអនុប្រធាន រហូតទៅដល់ជាប្រធាននោះ តើមានអ្វីកើតឡើង ចំពោះក្មេងទាំងអស់នោះដែលមកជាមួយឪពុកម្តាយ? តើមានសល់ទេ មានសល់រស់

រានមានជីវិតទេ ក្រោយរបបនោះ ក្រៅពីបីបួននាក់ហ្នឹង?

**ឆ៖** ខ្ញុំគិតថា ក្មេងបីនាក់ដែលរស់រានមានជីវិតហ្នឹង ជាក្មេងដែលចូលមកនៅក្នុងចុងឆ្នាំ ១៩៧៨។ ឯចំណែកក្មេងពីនោះមករហូត ពី៧៥មករហូតគ្នាស្លាប់អស់ហើយ ត្រូវកម្ទេចអស់ហើយ។

**ស៖** នៅពេលដែលកម្ទេចក្មេងៗ គេយកគាត់ទាំងអស់ទៅកន្លែងណា ដើម្បីសម្លាប់ចោល?

[១៤:២៣:១៩]

**ឆ៖** ការឆ្លើយរបស់ខ្ញុំ វាមិនចូលច្បាស់លាស់ទេ គឺគ្រាន់សន្និដ្ឋានជារួម ក្នុងឋានៈខ្ញុំជាអ្នកដឹកនាំ រួមនៅស-២១ គឺយកជើងឯក។ ថាឲ្យប្រាកដ ខ្ញុំអត់ចូលជ្រៅដល់បញ្ហាហ្នឹងទេ។ សូមជម្រាបលោកព្រះរាជអាជ្ញា ថាខ្ញុំមួយថ្ងៃៗងើបពីដេកម៉ោងប្រាំមួយ រហូតដល់ម៉ោងពីរដណ្តប់យប់ គិតតែមើលឯកសារ ដើម្បីម្ចាស់ការរាយការណ៍ជូនមេ។ មេឲ្យខ្ញុំគិតអារឿងហ្នឹងជាសំខាន់។

**ស៖** តើក្មេងៗទាំងអស់ហ្នឹង ទុកនៅស-២១យូរទេ មុនពេលដែលបញ្ជូនចេញទៅសម្លាប់ចោល? ហើយប្រសិនបើទុកពួកគាត់ឲ្យនៅទីនោះយូរដែរ ទុកនៅកន្លែងណាដែរនៅក្នុងស-២១?

**ឆ៖** ខ្ញុំអត់បានចូលៗជ្រៅទៅដល់បញ្ហាជាក់ស្តែងបែបនេះទេ។ អត់ដឹង មិនដឹងគេ គេទុកត្រង់ណា អីត្រង់ណាទេ។

**ស៖** លោកបានជម្រាបថា <មិន>មានមន្ទីរ <ថែរក្សា>ក្មេងដែលគ្មានឪពុកម្តាយ<ទេ> ថា តើ<>មានកន្លែងដែលរក្សាទុកក្មេងៗ <ឬសាលារៀននៅ ស-២១ ទេ ពេលដែលមានក្មេងៗរាប់រយនាក់កំពុង>រង់ចាំឪពុកម្តាយពួកគាត់<ពេលសួរចម្លើយនោះ>?

**ឆ៖** បានបញ្ជាក់ហើយ។ សូមទោស ខ្ញុំបានបញ្ជាក់ហើយថា បើសិនជា ប៉ុល ពត សម័យប៉ុល ពត សម័យបក្សកុម្មុយនីស្តកម្ពុជា បក្សកុម្មុយនីស្តកម្ពុជា មិនបញ្ជាឲ្យគេសម្លាប់កុមារកំព្រាទេ វាទាល់តែមានមន្ទីរកុមារកំព្រា។ តែជាក់ស្តែងគ្មានអ្នកណាមួយឃើញថា មានមន្ទីរកុមារកំព្រានៅសម័យនោះទេ។ ដូច្នេះបានន័យថា នេះជាភស្តុតាងមួយដែលបក្សកុម្មុយនីស្តកម្ពុជាឲ្យគេកម្ទេចទាំងម៉ែ ទាំងឪ ទាំងម៉ែ ទាំងកូន នៅពេលដែលឪក្បត់។ ដូច្នេះខ្ញុំយកពាក្យ "មន្ទីរកុមារកំព្រា" នេះធ្វើជាភស្តុតាងមួយបញ្ជាក់ជូនតុលាការថា សម័យប៉ុល ពត តែម៉ែឪគេកម្ទេចហើយ កូនក៏គេកម្ទេចដែរ។ ដូច្នេះមិនមាននិយាយអំពីកុមារ -- មន្ទីរកុមារកំព្រាមានជាក់ស្តែងនៅលើដីខ្មែរក្នុងជំនាន់នុ៎ងទេ អត់មាន។

[១៤:២៦:២៤]

**ស៖** លោកសាក្សី ខ្ញុំចង់អានជូនលោកនូវអត្ថបទដកស្រង់មួយ ចេញពីសៀវភៅ និពន្ធដោយ

ថេត សម្បត្តិ ដែលបានធ្វើកិច្ចសម្ភាសន៍លម្អិតជាមួយនឹង នួន ជា។ ហើយសៀវភៅនេះ គឺឯកសារ E3/4202– E3/4202, អង់គ្លេសត្រង់ ERN លេខ <00757337>, ខ្មែរ 00858358 ដល់ 59, បារាំងគឺ00849448។ នៅក្នុងផ្នែកមួយនៃសៀវភៅដែលលើកឡើងអំពីស-២១ ថេត សម្បត្តិ បានដកស្រង់នូវការអះអាងរបស់ នួន ជា ដូចខាងក្រោម៖ "ជាធម្មតា ពួកគេសារភាពនៅពេលដែលពួកគេត្រូវបានវាយដំយ៉ាងឈឺចាប់ ហើយនិង<>រងទារុណកម្ម<>ធ្ងន់ធ្ងរផងដែរ។ ចម្លើយសារភាពនោះ មិនអាចមានសុពលភាព និងប្រើប្រាស់បាននោះទេ ដូច្នេះហើយពួកគេត្រូវបានដោះលែង។ ជន<ជាប់ចោទ>មួយចំនួននោះគឺជាក្មេងៗ។"

<យើងនឹង>និយាយអំពីការធ្វើទារុណកម្ម និងចម្លើយសារភាព<នៅពេលក្រោយ>។ ហើយនៅពេលនេះ ខ្ញុំសូមសួរលោកសង្កត់ធ្ងន់ទៅលើផ្នែកចុងក្រោយនៃចំណុចដកស្រង់នេះ ដែល នួន ជា បាននិយាយ<អំពី ស-២១>ថា "អ្នកដែលជាប់ទោសនៅទីនោះមួយចំនួននោះ មានខ្លះនោះជាក្មេងៗ មានវ័យក្មេង"។ តើលោក<ចាំថា>ធ្លាប់បានជជែកជាមួយនឹង នួន ជា <អំពីកូនក្មេងនៅស-២១>ដែរឬទេ? <តើលោកមានបានផ្ញើរបាយការណ៍ណាមួយឲ្យគាត់ទេ?> ហើយតើលោកបានដឹងដែរឬទេ ថាតើ នួន ជា គាត់ដឹងមកពីណាដែលថាអ្នកជាប់ទោសនៅទីនោះមួយចំនួននោះ គឺមានវ័យក្មេងៗ?

[១៤:២៨:៥២]

**ឆ៖** ខ្ញុំគិតថា ពូនួន គាត់មានប្រសាសន៍នេះ មិនជាក់ស្តែងទេ មិនជាក់ស្តែងសោះ។ អត់មានដោះលែងអីទេ ឲ្យតែចូលស-២១ហើយ គឺដាច់ខាតកម្ទេច។ ខ្ញុំយក ពូនួន ខ្លួនឯងហ្នឹងធ្វើជាសាក្សីខ្ញុំម្តង។ មានពេទ្យធ្មេញម្នាក់ ៨៧០អនុញ្ញាតឲ្យគេចាប់បញ្ជូនមកស-២១ហើយ ពេទ្យធ្មេញនោះឈ្មោះ ឌី ផុន។ រីកចម្រើននៅស្រុកបារាំងជាមួយពួកបងប៉ុល ពួកអីហ្នឹង ជាមួយ ប៉ុល ពត ហ្នឹង។ ដល់ក្រោយមកត្រូវចាប់។ ស្រាប់តែមួយសន្ទុះ ពូនួន ហ្នឹងហៅខ្ញុំទៅធ្វើការ "ថាឥឡូវបក្សឲ្យមិត្តដោះលែង មិត្តធ្លុក -- មិត្តធុក" ពេទ្យធ្មេញទុំង ឌី ផុន នុំង។ ខ្ញុំមិនទាន់នឹងឆ្លើយស្អីផង គាត់ថា មិត្តដោះលេងទៅណា។ កុំសម្លាប់ ទុកធ្វើធ្មេញមាត់។" ខ្ញុំអត់ប្រកែកទេ ឲ្យតែឮថាបានដោះ ប៉ុន្តែមិនមែនដោះឲ្យទៅផ្ទះទេ គឺដោះឲ្យនៅក្នុងស-២១ហ្នឹង ឲ្យរស់ជីវិតនៅក្នុងមន្ទីរស-២១ហ្នឹង ដូចជាឲ្យដេកជាមួយអ្នកទោសផងមិនដឹង។ ហ្នឹងតែមួយគត់ ដែលបក្សកុម្មុយនីស្តកម្ពុជាគឺ បងប៉ុល ឲ្យខ្ញុំដោះលែង ក្រៅពីនោះគ្មានទេ។ ដូច្នេះ បង នួន –ពូនួន– គាត់មានប្រសាសន៍ហ្នឹង មិនជាក់ស្តែង។

**ស៖** ខ្ញុំយល់។ ខ្ញុំនឹងនិយាយអំពីបញ្ហាហ្នឹងឡើងវិញ។ នួន ជា និយាយច្រើនណាស់អំពីការដែល

គាត់បានពិនិត្យមើលនូវចម្លើយសារភាពហ្នឹង ហើយខ្ញុំនឹងសួរលោក លម្អិតបន្ថែមទៀតទៅលើចំណុចហ្នឹង។ ក៏ប៉ុន្តែខ្ញុំចង់សុំសួរលោកត្រង់ឃ្លាដែលលើកឡើងថា ជនជាប់ទោសមួយចំនួនខ្លះនៅទីនោះនោះគឺមានវ័យក្មេងៗ ឬក៏ជាក្មេងៗ។ <ហើយសំណួររបស់ខ្ញុំគឺថា> តើលោក<ចាំថា>ធ្លាប់ដែលបានជួបជជែកជាមួយនឹង នួន ជា <អំពីកូនក្មេង>នៅស-២១<ទេ>? ហើយថាតើ<លោក>ធ្លាប់បានទទួលរបាយការណ៍អំពី<កូនក្មេង>ដែរឬទេ? ឬក៏ថាតើលោកដឹងទេ ហេតុអ្វីបានជាលោក នួន ជា នោះ គាត់ដឹងថាអ្នកជាប់ទោសមួយចំនួននៅស-២១ នោះមានអ្នកខ្លះនោះ គឺមានវ័យក្មេងៗ ឬជាកុមារ?

**ឆ៖** អត់ឮការបកប្រែថាម៉េចផង។

[១៤:៣១:៥៥]

**ប្រធានអង្គជំនុំ៖**

មើលៗ ឧបករណ៍ ៗស្តាប់សំឡេង។ មើលថ្ម មើលថ្មឧបករណ៍ណ៎ា។

សហព្រះរាជអាជ្ញារងអន្តរជាតិ ចូរតាំងសំណួរចុងក្រោយរបស់លោក ចំពោះសាក្សីសាជាថ្មី ព្រោះអំមិញនេះ សាក្សីមិនស្តាប់សំឡេងនៃការបកប្រែភាសាហ្នឹង មិនបានទេ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំសួរអំពីចម្លើយនិងការអះអាងរបស់ នួន ជា ដែលថាមនុស្សមួយចំនួននៅក្នុងស-២១ ជាប់ទោសនៅទីនោះ គឺជាកុមារ ឬមានវ័យក្មេងៗ។ <តើលោកចាំថាធ្លាប់សន្ទនាជាមួយ នួន ជា អំពីកូនក្មេងនៅស-២១ទេ? តើ>លោកបានបញ្ជូនរបាយការណ៍ទៅគាត់ ឬក៏យ៉ាងម៉េច? តើលោកដឹងទេ តើលោក នួន ជា ដឹងថាអ្នកជាប់ទោសនៅស-២១ខ្លះនោះ ជាកុមារ ឬមានវ័យក្មេងៗ ធ្វើម៉េចគាត់ដឹងទៅ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំមិនដែលបានបញ្ជូនបញ្ជីអ្នកទោសទៅដល់ ពូនួន ទេ។ របស់ដែលខ្ញុំបញ្ជូនទៅគាត់ ក៏ដូចជាបញ្ជូនទៅបងសុន សេន ដែរ គឺចម្លើយអ្នកទោសដែលចាំបាច់ ដែលបក្សតាមដាន។ ខ្ញុំធ្វើម៉េចឲ្យតែបានការងារហ្នឹងឆាប់ ហើយសុក្រឹត ជាអតិបរមា។ ហើយខ្ញុំចារលើចំណុចណាដែលគួរឲ្យចាប់អារម្មណ៍តែប៉ុននុ៎ងឯង។ ខ្ញុំអត់ដែលបានសន្និដ្ឋានពិតប៉ុន្មានភាគរយ ពាក្យអីទេ។ ចារខ្លីៗៗ ដូចឯកសារសល់មក ជាឧទាហរណ៍ស្រាប់។ ការងារខ្ញុំគិតតែប៉ុននុ៎ង។ ឯចំណែកខ្ញុំរាយការណ៍ពីកុមារមានប៉ុន្មានអីប៉ុន្មានអត់ទេ។ អ៊ីចឹងហើយបានជាខ្ញុំជម្រាបព្រះរាជអាជ្ញាថា ពូនួន មានប្រសាសន៍ហ្នឹងមិនជាក់ស្តែងទេ គ្មានក្មេងៗនៅសល់ទេ នៅស-២១។ នេះគឺខ្ញុំជម្រាបប៉ុណ្ណឹង ត្រង់គាត់មានគំនិតយ៉ាងម៉េច

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បានគាត់មានប្រសាសន៍អ៊ីចឹង គាត់អត់ប៉ានថាទេ។

**ស៖** ការប្រាស្រ័យទាក់ទងគ្នារបស់លោក ជាមួយ សុន សេន និង នួន ជា តើមានអ្នកណាម្នាក់ក្នុងចំណោម សុន សេន និង នួន ជា ធ្លាប់ដែលបង្គាប់បញ្ជាមកលោកទេ ថាឈប់ឃុំក្មេងៗនៅស-២១តទៅទៀត ឬក៏កុំសម្លាប់ក្មេងៗដែលបានឃុំខ្លួននៅស-២១ចោល? ធ្លាប់ៗដែលមានការបង្គាប់បញ្ជាបែបនេះពី នួន ជា ឬក៏ពី សុន សេន មកដល់លោកទេ <គឺកុំឲ្យចាប់ខ្លួន កុំឲ្យឃុំខ្លួន និងកុំឲ្យសម្លាប់កុមារ>?

**ប្រធានអង្គជំនុំ៖**

ឌុចៗ ស្ដាប់ឮទេ ឌុច?

[១៤:៣៥:៥២]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំសូមឆ្លើយយ៉ាងខ្លី គ្មានទេ។ គ្មានដែលបញ្ជាក់ បង្គាប់បញ្ជាមិនឲ្យសម្លាប់កុមារ មិនឲ្យសម្លាប់មនុស្សចាស់ មិនឲ្យសម្លាប់ស្រីមានផ្ទៃពោះ គ្មាន។ ហើយខ្ញុំចាំច្បាស់ថា ពេលរៀបចាប់អ្នកថ្មី សុន សេន បងសុន សេន តែងតែបញ្ជាឲ្យខ្ញុំបញ្ជូនអ្នកទោសឲ្យឆាប់ចេញទៅ នឹងអាលទទួលអ្នកថ្មី។ ឧទាហរណ៍នៅពេលរៀបចាប់ កុយ ធួន អ៉ន់ែ!ហ្នឹងហើយ រៀបចាប់ខ្សែឧត្តរ។ ដោយតាមចម្លើយ កុយ ធួន គាត់ឲ្យខ្ញុំបញ្ចេញមនុស្សឲ្យស្រាលគុកជាអតិបរិមាដើម្បីទទួលអ្នកថ្មី ហើយចាត់ចែងការងារសួរចម្លើយឲ្យទាន់ពេលវេលាឲ្យគាត់ មាន។ ត្រង់បញ្ជាឲ្យកុំសម្លាប់មនុស្សចាស់ កុំសម្លាប់ស្ត្រីមានផ្ទៃពោះ កុំសម្លាប់កុមារ គ្មាន។ ដូចខ្ញុំជូនឧទាហរណ៍អ៊ីចឹង ប៉ុល ពត ឲ្យ ពូនួន ប្រាប់មកខ្ញុំថាកុំសម្លាប់ បងឌី ផុន ខ្ញុំអត់សម្លាប់ មានតែមួយហ្នឹងឯង។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងៗបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៧ នាទី ដល់ម៉ោង ១៤:៥៨ នាទី)*

[១៤:៥៨:៤៩]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ មុនពេលដែលខ្ញុំចាប់ផ្តើមការសួរសំណួរឡើងវិញ ខ្ញុំសូមជម្រាបអំពីការចែកម៉ោងរវាងខ្ញុំ និងសហមេធាវីនាំមុខ។ ខាងសហមេធាវីនាំមុខ គឺសុំបីវគ្គ។ ហើយប្រហែល <ពួកគេនឹងចាប់ផ្តើម>ធ្វើ<នៅ>ថ្ងៃស្អែក<ពេល>រសៀល <ប្រហែលជាក្រោយពីចូលវគ្គមួយបានពាក់កណ្តាលហើយ ហើយនឹងធ្វើមួយវគ្គកន្លះទៀតនៅថ្ងៃព្រហស្បតិ៍ ហើយមួយវគ្គកន្លះទៀតនៅព្រឹកថ្ងៃចន្ទ> បន្ទាប់មកខ្ញុំបន្ត<សួរលើម៉ោងដែលនៅសេសសល់ពីពួកគេ>។ <នេះជាផែនការរបស់>យើង<តើ>អង្គជំនុំជម្រះ<ទទួលយកបានទេ?>

លោកប្រធាន ខ្ញុំសូមសួរសាក្សីអំពីឯកសារ E3/2133។ ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារភស្តុតាងនេះ ជូនសាក្សី លោកប្រធាន E3/2133។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ឯកសារដែលលោកទើបតែទទួលអម្បាញ់មិញនោះ គឺមានមួយទំព័រ <មានចំណងជើងថា "ឈ្មោះអ្នកទោសនៅក្រោមបង> ហ៊ុយ ស្រែ <ដែលត្រូវកម្ទេច>។ បញ្ជីនេះមានឈ្មោះ១៨នាក់។ ឯកសារនេះចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៧៧។ បន្ទាប់មកមានកំណត់សម្គាល់សរសេរដោយដៃនៅខាង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក្រោម ដែលលើកឡើងថា "ចំនួនសរុបគឺ១៧៨" ចំនួនអ្នកទោសសរុបរួមទាំង ក្មេងដែលត្រូវបានកម្ទេចចោល<រួមទាំង១៦០>--

[១៥:០២:០៨]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាល់ទាន់!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

កាលពីសប្តាហ៍មុន គឺយើងបានជូនដំណឹងរួចមកហើយ ពាក្យថា "កម្ទេច" នេះ គឺដូចជាយើងបានលើកឡើងហើយ ដោយវាមិនមាននៅក្នុងឯកសារខ្មែរនោះទេ។ ហេតុដូច្នេះសហព្រះរាជអាជ្ញាគួរតែប្រើប្រាស់ឯកសារឲ្យបានត្រឹមត្រូវ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ដូច្នេះខ្ញុំសូមបញ្ជាក់ពីលោក តើលោកស្គាល់ទេ អក្សរសរសេរដោយដៃ? តើនរណាគេដែរ ជាអ្នកចុះហត្ថលេខានៅលើរបាយការណ៍នេះ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អក្សរនេះ ជាពិសេសឯកសារតែម្តង ខ្ញុំបានអធិប្បាយរួចហើយ ប្រហែលជាតាំងពីសម័យស៊ើបអង្កេតមកម្ល៉េះ។ ដូច្នេះអក្សរនេះ វាអត់អីលំបាកនឹងខ្ញុំទទួលស្គាល់ទេ។ ឯកសារនេះ ក៏មិនលំបាកអីនឹងខ្ញុំទទួលស្គាល់ដែរ។ អក្សរនេះគឺអក្សរ មិត្តហ៊ី។ ឯកសារនេះ គឺពិតជាឯកសារស-២១ហើយ។

[១៥:០៣:៣២]

**ស៖** ដូច្នេះហត្ថលេខានោះជារបស់ ហ៊ី ហើយចំពោះចំណាររនៅខាងក្រោមបន្តិចហ្នឹង តើជាអក្សរ ហ៊ី ដែរឬទេ?

**ឆ៖** ច្បាស់លាស់ គឺជាអក្សរ ហ៊ី។

**ស៖** ដើម្បីជាប្រតិចារឹក សូមឲ្យលោកអានថា ហ៊ី នុំងបានសរសេរអ្វីខ្លះនៅខាងផ្នែកខាងក្រោមបន្តិចនុំង?

**ឆ៖** ខ្ញុំសូមអានពីលើនោះបន្តិចមក "ធ្វើនៅថ្ងៃទី២៣ ខែកក្កដា ១៩៧៧ រួមនឹងកុមារ១៦០នាក់ ទាំងអស់ផ្នែកស្រែ ១៧៨នាក់"។

**ស៖** ដូច្នេះមាន១៨នាក់ដែលមានចុះឈ្មោះប្រាកដនៅក្នុងនោះ ក៏ប៉ុន្តែសរសេរសរុបចំនួនអ្នកទោសគឺ១៧៨ ដោយក្នុងនោះ១៦០នាក់គឺជាកុមារ។ តើមានអ្វីកើតឡើងចំពោះកុមារចំនួន១៦០នាក់នោះ?

**ឆ៖** យើង បញ្ហានេះសូមក្រឡេកមើលទាំងអស់គ្នាទៅលើចំណងជើងឯកសារនេះ។ ចំណងជើងឯកសារនេះ "ឈ្មោះអ្នកទោសកម្ទេចផ្នែក បងហ៊ុយ ស្រែ"។ ដូច្នេះវាបញ្ជាក់ថា ថ្ងៃនុំងមានការកម្ទេចមនុស្ស១៧៨នាក់ ក្នុងនោះមានកុមារ១៦០ និងមនុស្សពេញវ័យ១៨នាក់។ ហ្នឹងខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ។

**ស៖** នៅក្នុងស្ថានភាពដែលខាងអង្គភាព ហ៊ុយ ស្រែ ពីព្រៃសបញ្ជូនមនុស្សមកសម្លាប់ចោលថាតើគេបញ្ជូនផ្ទាល់ទៅជើងឯកតែម្តង ដើម្បីសម្លាប់ចោល ឬក៏មុនដំបូងបញ្ជូនមកស-២១ជាមុន មុនពេលបន្តជូនទៅជើងឯក?

[១៥:០៦:១៧]

**ឆ៖** ជាកិច្ចដំណើរការច្បាស់លាស់ ខ្ញុំអត់បានដឹកនាំ ហើយគ្រប់គ្រងបញ្ហានេះទេ។ ក៏ប៉ុន្តែខ្ញុំសូមនិយាយជាគោលការណ៍រួម គេមិនដែលដឹកមនុស្សពីព្រៃសមកភ្នំពេញ ហើយចេញពីភ្នំពេញទៅជើងឯកទេ។ កាលណាសម្រេចអ៊ីចឹងហើយ គឺគេដឹកពីព្រៃសមកជើងឯកត្រង់តែម្តង។

**ស៖** ឯកសារនេះ<និយាយពីអ្នកទោសមកពីខាងបង> ហ៊ុយ ស្រែ ក៏ប៉ុន្តែមានហត្ថលេខាពី ហ៊ីវិញ។ អ៊ីចឹងតើលោកអាចបញ្ជាក់ទេ តើហេតុអ្វីបានជា ហ៊ី ជាអ្នកចុះហត្ថលេខាទៅវិញ?

**ឆ៖** អ្នកសរសេរ មិនមែនខាងពួកស្រែសរសេរទេ។ ខ្លឹមសាររបស់វា លោកឃើញហើយ "ពួកអ្នកទោសកម្ទេចផ្នែកបងហ៊ុយ ស្រែ" ដូច្នេះអាចអ្នកសរសេរផ្សេង នៅភ្នំពេញហ្នឹងគេអ្នកសរសេរប្រហែលជាមិត្តធី ផងមិនដឹង។ ខ្ញុំមិនដឹងច្បាស់ទេ ប៉ុន្តែឯកសារនេះគឺភ្នំពេញចងក្រង។ ផ្នែកបង ហ៊ុយ ស្រែ ដូច្នេះបានន័យថា ម្ចាស់ឯកសារនេះមិនមែន បងហ៊ុយ ទេ។ រួចបាន១ចុះហត្ថលេខា មិត្តហ៊ី។

**ស៖** លោកសាក្សី ភស្តុតាងនេះបានបង្ហាញថា មានថ្ងៃមួយនោះ ក្មេងចំនួន១៦០នាក់ត្រូវបានសម្លាប់ចោល។ កុមារ១៦០នាក់ត្រូវបានសម្លាប់ចោលក្នុងមួយថ្ងៃនោះ។ តើលោកអាចស្មានទៅមើលថាតើក្នុងអំឡុងពេលប្រតិបត្តិការស-២១ទាំងមូល តើមានក្មេងប៉ុន្មាននាក់ដែរ ដែលត្រូវបានគេសម្លាប់ចោល តាមការស្មានលើតួលេខរបស់លោក?

[១៥:០៨:៤៩]

**ឆ៖** ពិបាកណាស់ឲ្យខ្ញុំស្មាន។ ដូចជាលើកដំបូង គេសួរថា អង្គភាពលោក អង្គភាពស-២១

មានយុទ្ធជនប៉ុន្មាន? ខ្ញុំថាប្រហែលជា៦០០ ដល់ឃើញបញ្ជីមែនទែន ពាន់! ប៉ុន្មានពាន់។ ដូច្នេះរឿងបញ្ជីរឿងអី ដូចខ្ញុំជម្រាបលោកព្រះរាជអាជ្ញាអ៊ីចឹង ខ្ញុំមានភារកិច្ចមួយដោយឡែក គឺមើលតែឯកសារចម្លើយខ្លាំង ហើយសម្រួលដល់ការយល់ដឹងរបស់ខាងលើ ហើយជៀសវាងធ្វើម៉េចកុំឱ្យការឆ្លើយហ្នឹងវាច្របូកច្របល់។ សម្ពហាភាពដឹកនាំគឺអ៊ីចឹង។ ខ្ញុំជាសម្ពហាភាព តំណាងឱ្យខាងលើ ដូច្នេះគេទទួលភារកិច្ចដោយឡែក។ កុំឱ្យបាត់មនុស្ស បើថាគេឱ្យកម្ទេចហើយ កុំឱ្យ -- កម្ទេចឱ្យបាន ឱ្យអស់ កុំឱ្យបាត់មនុស្ស។ ផ្តោះផ្តោយលើកក្រោយគឺសល់បីនាក់ហ្នឹង សល់ក្មេងៗបីនាក់ហ្នឹង។ ដូច្នេះគេកម្ទេចហើយ។ ដូច្នេះតាមគោលការណ៍ ប្រហែលជាគេចេះសម្រួលការងារគេហើយ គេមិនដឹកពីព្រៃសយកមកភ្នំពេញហើយចេញពីភ្នំពេញទៅជើងឯកទេ។ គឺគេដឹកពីព្រៃស ចូលជើងឯក។ មធ្យោបាយដឹកយ៉ាងម៉េច អីយ៉ាងម៉េចជាជំនាញរបស់គេ។ អានេះជំនាញ។

**ស៖** សំណួរចុងក្រោយមួយពាក់ព័ន្ធទៅនឹងកុមារ។ នៅក្នុងសក្ខីកម្មដែលលោកផ្តល់នៅថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ E3/5802 នៅម៉ោង០៩:៣៥នាពេលព្រឹក។ លោកបាននិយាយដូចតទៅ៖ “ក្មេងទាំងអស់ត្រូវបំបែកចេញពីឪពុកម្តាយ ហើយកុមារភាគច្រើនត្រូវបានបញ្ជូនទៅស្រែនៅព្រៃស បន្ទាប់មកកម្ទេចចោល។ ហើយក្មេង កុមារដែលនៅសល់ នឹងសម្លាប់ចោលនៅជុំវិញទីតាំងវិទ្យាល័យពញាយ៉ាត។” បញ្ចប់ការដកស្រង់។ តើកុមារដែលមកស-២១ ចូលមកស-២១នេះ ត្រូវបានគេសម្លាប់ចោលនៅជុំវិញទួលស្លែងដែរឬទេ? ប្រសិនដូច្នោះមែន តើនរណាជាអ្នកទទួលខុសត្រូវលើការកម្ទេចក្មេងទាំងអស់នោះ នៅជុំវិញវិទ្យាល័យពញាយ៉ាត ឬក៏ទួលស្លែងនោះ?

[១៥:១១:៣៨]

**ឆ៖** ខ្ញុំទទួលស្គាល់ថា ការកម្ទេចនៅជុំវិញវិទ្យាល័យពញាយ៉ាតនេះ គឺនៅពេលដែលទល់ច្រកនៅពេលដែលអ្នកទោសមកខ្លាំង ហើយត្រូវការប្រញាប់ បញ្ចូលមកថ្មី។ ដូច្នេះ សុទ្ធតែមនុស្សចាស់ទេ។ កុមារគឺជើងឯក កុមារគឺជើងឯក។

**ស៖** មិនថ្វីទេ។ ខ្ញុំសូមប្តូរចូលប្រធានបទមួយទៀត ដែលលើកឡើងពាក់ព័ន្ធទៅនឹងការសួរចម្លើយលើអ្នកទោសនៅស-២១។ ខ្ញុំសូមចាប់ផ្តើមសួរសំណួរទូទៅ ពាក់ព័ន្ធនឹងនីតិវិធីរបៀបដែលទូទៅគេប្រើប្រាស់នៅពេលសួរចម្លើយអ្នកទោសស-២១។ សំណួរដំបូងរបស់ខ្ញុំ គឺនៅពេលអ្នកទោសថ្មីចូលមកដល់ស-២១ ថាតើគេកំណត់យ៉ាងដូចម្តេចថា អ្នកទោសណាដែលត្រូវយកទៅសួរចម្លើយ ហើយឱ្យក្រុមណាជាអ្នកសួរចម្លើយ? តើការសម្រេចនីតិវិធីកំណត់យកអ្នកទោសទៅសួរចម្លើយសម្រាប់ដោយ

ក្រុមណាមួយជាក់លាក់នោះ គេធ្វើយ៉ាងម៉េច?

**ឆ៖** អរគុណ។ អ្នកទោសដែលខ្ញុំចាត់ឲ្យ មិត្តប៉ុន ធ្វើ គឺអ្នកទោសដែលខាងលើចាប់អារម្មណ៍តាមដានខ្សែនុំងសំខាន់។ ប៉ុន្តែសំខាន់មែនទែនទៅទៀត មានអ្នកទោសម្នាក់ដែលខាងលើផ្តាំផ្តាច់ ឲ្យខ្ញុំសួរដោយផ្ទាល់គឺ កុយ ធួន។ ហើយមានអ្នកទោសម្នាក់ទៀតដែរគឺ យឹម សម្បត្តិ អនុសេនាធំកងពល ១៧០ បូព៌ា ដែលបោកគ្រាប់បែកក្រោយវាំង។ ហ្នឹងខាងលើបញ្ជាក់ឲ្យ មិត្តហ៊ី សួរ។ មិនបាច់មិត្តសួរទេ ហើយមិនបាច់ មិត្តប៉ុន សួរទេ ឲ្យមិត្តហ៊ី សួរ ហើយកុំឲ្យវ៉ៃ។ ហ្នឹងកំណត់មកអ៊ីចឹង។ ដូច្នេះក្រៅពីមនុស្សពិសេសពីរនាក់នេះ កាលណាខាងលើផ្តាំ ខ្ញុំតែងចាត់តាំងឲ្យ មិត្តប៉ុន ឬមិត្តទុយ សួរ ហើយក្រៅពីនោះ មិត្តហ៊ី គេជាអ្នកចាត់ចែង ជួយចាត់ចែងការងារនេះខ្ញុំ។ តាមពិតការងារនេះជារបស់ខ្ញុំទេ ប៉ុន្តែដល់ខ្ញុំរវល់កុនអ៊ីចឹងទៅ មិត្តហ៊ី គេជាអ្នកចាត់ចែង ជួយចាត់ចែងកិច្ចការហ្នឹង។ ដូច្នេះ សរុបមកមួយជីវិត ស-២១ ចាប់តាំងខ្ញុំឡើងធ្វើប្រធាន ខ្ញុំសួរបានតែម្នាក់ហ្នឹងឯងគឺ កុយ ធួន។ ក្រៅពីនោះ មិត្តប៉ុនទាំងអស់ មនុស្សសំខាន់ៗ។

[១៥:១៥:០៣]

**ស៖** ចំពោះសមាជិកផ្សេងទៀតនៅក្នុងក្រុមសួរចម្លើយ តើគេសម្រេចចាត់តាំងឲ្យអ្នកទោសឲ្យក្រុមណាមួយសួរចម្លើយនោះ តើគេធ្វើយ៉ាងដូចម្តេច? តើលោកអាចជួយពន្យល់បានដែរឬទេ អំពីរបៀបដែលគេសម្រេចហ្នឹង?

**ឆ៖** សារៈសំខាន់របស់អ្នកទោសដែលប្រគល់ឲ្យអ្នកណាសួរហ្នឹងគឺមាន មិត្តប៉ុន ហើយនិង មិត្តហ៊ី ដែលគេតាមដានជាប់របស់គេ។ អ្នកទោសណាឆ្លើយយ៉ាងម៉េច អ្នកណាទោសណាសំខាន់ អ្នកទោសណាមិនសំខាន់ គេក្តាប់របស់គេ។ ដល់អ្នកទោសដែលខ្លាំងឆ្លើយដាក់ មកដល់ គេប្រគល់ភ្លាមអាហ្នឹងគេមុខសញ្ញារបស់គេហើយស្រេច ទៅតាមនុំង។ ប៉ុន្តែអ្នកទោសខ្លះ ខ្ញុំប្រគល់ឲ្យគេ ដូចយ៉ាងពួកបស្ចិមប្រទេសប៉ុន្មាននាក់នុំង បួននាក់។ មានតាមឯកសារដែលខ្ញុំឃើញនៅសល់នេះ គឺមានមួយចំនួនពីរនាក់អ៊ីចេះមិនដឹង ខ្ញុំប្រគល់ឲ្យ បងម៉ម ណៃ សួរ ឯពីរអ្នកទៀត មិត្តប៉ុន សួរ។ ដោយឡែក ទាហានយួនហើយនិងមនុស្សដែលចាប់បានមកពីស្រុកយួន ផ្តាច់មុខទៅលើ បងម៉ម ណៃ។ បងម៉ម ណៃ ហ្នឹងខ្ញុំចាត់តាំងឲ្យរៀនភាសាវៀតណាមផង។ គាត់ចេះនិយាយ ចេះសួរវៀតណាមបានជាមួយនឹង ផា ថាចាន់។ គាត់រៀនវៀតណាមពី ផា ថាចាន់ ហើយអ្នកទោស ហើយនិងអ្នកទោសម្នាក់ទៀតឈ្មោះ វ៉ូឌីងង៉ (យួន)។ ដូច្នេះគឺគេបែងចែកអ៊ីចឹង។ ហើយសូមសរុបមកវិញ ខ្ញុំសួរបានតែម្នាក់គត់ មិត្តហ៊ី សួរ

បានម្នាក់គត់ មិត្តប៉ុន ស្នួរជាទូទៅមនុស្សសំខាន់ បងម៉ម ណៃ ស្នួរបានពួកបស្ចិមប្រទេសប្រហែលពីរនាក់ ក្រៅពីនោះពួកខាងយួនទាំងអស់។ ដូច្នេះកម្មាភិបាលតិច តែអ្នកទោសច្រើន ស្នួរអត់ទាន់ទេ។

[១៥:១៧:៣៩]

**លោក ខេល លីសាក់៖**

សូមការអនុញ្ញាតពីលោកប្រធាន។ ពេលខ្លះទៅខ្ញុំមានសំណួរមួយចំនួនសួរទៅកាន់សាក្សី ហើយខ្ញុំចង់យោងទៅលើសៀវភៅកំណត់ហេតុចំនួនបី របស់អ្នកស្នួរចម្លើយនៅស-២១។ ហើយខ្ញុំបានបញ្ចូលឯកសារសៀវភៅហ្នឹងចូលគ្នានៅក្នុង*បាញ់ឌ័រ* ដើម្បីកុំឲ្យខ្ញុំនេះ ហុចឯកសារនេះទៅវិញទៅមក ទៅឲ្យសាក្សី។ <ដើម្បីប្រតិចារឹក> សៀវភៅកំណត់ត្រាទាំងបីនេះ <ដែលត្រូវបានបញ្ជាក់ថា>គឺជាកំណត់សៀវភៅកត់ត្រារបស់អ្នកស្នួរចម្លើយនៅស-២១ ឯកសារ E3/8368។ សៀវភៅនេះនៅគ្របទំព័រ គឺបានន័យថា បានសរសេរចំណងជើងថា "ស្ថិតិរបស់សាខាពិសេស"។ សៀវភៅទី២ គឺE3/834 សៀវភៅនេះគឺសៀវភៅរបស់កំណត់ត្រារបស់ ផន ទុយ។ ហើយសៀវភៅមួយទៀតគឺ E3/833 ជាសៀវភៅកត់ត្រារបស់ ម៉ម ណៃ។ សូមអនុញ្ញាតលោកប្រធានផ្តល់កម្រង*បាញ់ឌ័រ* នេះជូនទៅលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៥:១៩:២៧]

**ស្នួរដោយលោក ខេល លីសាក់៖**

**ស៖** អ្វីដែលខ្ញុំចង់ស្នួរចេញពីសៀវភៅ ម៉ម ណៃ ចំណុចយោងនៅក្នុងនោះគឺ ត្រង់កូឡោនក្នុងទំព័រ00077895។ ប្រសិនបើលោកចង់ឲ្យខ្ញុំជួយបង្ហាញទំព័រហ្នឹងគឺសូមប្រាប់ខ្ញុំ។ ទំព័រនៅក្នុងសៀវភៅរបស់ ម៉ម ណៃ គឺE3/833 ខ្មែរ 00077895, អង់គ្លេសបានបកប្រែត្រង់ទំព័រ 00184607។ នៅក្នុងទំព័រនេះ សៀវភៅរបស់ ម៉ម ណៃ ចំណុចដូចខាងក្រោមនេះសរសេរថា៖ "តាំងពីខែមេសា ឆ្នាំ១៩៧៧ យើងមានក្រុមដូចខាងក្រោម៖ ក្រុមត្រជាក់ ក្តៅ ក្រុមធ្វើឯកសារ ហើយនិងក្រុម(ក)។" ខ្ញុំសូមស្នួរលោក តើក្រុម"ក"នេះជាក្រុមអ្វី? យើងបានស្តាប់ហើយ បានទទួលនូវសក្ខីកម្មហើយអំពីក្រុមទាំងបីផ្សេងទៀតដែលខ្ញុំលើកឡើង ចុះក្រុម"ក"នេះជាក្រុមអ្វីដែរ?

**ឆ៖** សូមទោស ខ្ញុំរកទំព័រនោះមិនឃើញទេ។ ខ្ញុំរកទំព័រនោះមិនឃើញទេ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ អាចជួយគាត់។

**លោក ឌេល លីសាក់៖**

00077895 គឺឯកសារចុងក្រោយត្រង់ ERN លេខ 77895 -- 00077895។

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ--

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើលោកឃើញទេ ដែលកន្លែងដែលគេសរសេររៀបរាប់អំពីក្រុមសួរចម្លើយ ហើយក្នុងហ្នឹងរៀបរាប់រួមមានក្រុម “ក” តើក្រុម “ក” ជាក្រុមអ្វី?

[១៥:២២:៥០]

**ឆ៖** ខ្ញុំឆ្លើយ សុំទោស ខ្ញុំឆ្លើយមិនទាន់ទេ ព្រោះការងារនេះ វាច្រើនឆ្នាំហើយ។ ប៉ុន្តែបើតាមខ្ញុំស្មាន ក្រុម“ក”ហ្នឹងអាច ក្រុមដែលសួរអ្នកទោសពិសេស។ អាចទេ គ្រាន់តែអាចទេ ព្រោះបើសិនជាអាចបានមើលឯកសារនេះហូរហែ ខ្ញុំអាចឆ្លើយបាន។ ប៉ុន្តែដល់មកវគ្គមួយភ្លែតហ្នឹង ឆ្លើយមិនទាន់ទេ។ គ្រាន់តែសូមជូនថា អាចក្រុមពិសេស។

**ស៖** ខ្ញុំសូមអានសក្ខីកម្មមុនៗដែលលោកបានឆ្លើយ ដើម្បីសាកមើលថាតើលោកអាចនឹកឃើញទេ។ ថ្ងៃ១៦ ខែមិថុនា ឆ្នាំ២០០៩ ត្រង់ឯកសារ E3/5800 ចន្លោះម៉ោង០៩:៥៦ ដល់០៩:៥៩ នាពេលព្រឹក។ លោកបានឆ្លើយដូចតទៅ៖ “ការសួរចម្លើយនៅស-២១ គឺធ្វើឡើងដោយក្រុម មុនដំបូងក្រុមបឋម។ ក្រុមនេះ សួរយកចម្លើយខ្លឹមសារសំខាន់ៗ ចេញពីចម្លើយសារភាព។ ហើយបន្ទាប់មក ហ៊ី ធ្វើការសម្រេចពិភាក្សាជាមួយខ្ញុំ ឬក៏ម្នាក់ឯង ថាតើអ្នកដែលសួរចម្លើយនុ៎ង ត្រូវបញ្ជូនទៅក្រុមពិសេសបន្តទៀត ឬក៏យ៉ាងណា ដូចជាក្រុមត្រជាក់ ក្តៅ ក្រុមអង្កៀមជាដើម។” តើលោកនៅចាំក្រុមសួរបឋមដែរឬទេ? តើក្រុមសួរបឋមនេះ គឺដូចទៅនឹងក្រុម “ក”នេះដែរឬទេ?

**ឆ៖** ក្រុមសួរបឋមហ្នឹងអាចមានមែន ប៉ុន្តែដល់ក្រោយមក ក៏ដូចជាមិនបានបំពេញភារកិច្ចអីទេ។ ក្រុមសួរបឋមហ្នឹង បើតាមខ្ញុំគិត គឺមិត្តហ៊ី ខ្លួនឯងហ្នឹងតែម្តង ដែលគាត់ម្ចាស់ការសួរ។ មកដល់ភ្លាមគាត់ចាត់តាំងកម្លាំងសួរ ឬក៏សួរខ្លួនឯង ដើម្បីយល់បញ្ហា។ ឯចំណែកពីនោះ មានពួកពិសេសពិសេសហ្នឹងកន្លងមកខ្ញុំចាត់តាំង មិត្តទុយ ហើយនិង មិត្តប៉ុន។ កម្មាភិបាលសំខាន់ៗរុញលើ មិត្តប៉ុន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មិត្តទុយ នេះពេក ប្រហើនពេក មើលសភាពការណ៍ខ្មៅពេក ហើយស្រួលមិនស្រួលធ្វើទារុណកម្មលើស សេចក្ដីណែនាំ។ ខ្ញុំមិនសូវទុកចិត្ត បើ មិត្តប៉ុន គេម្ចាស់ការ ព្រោះខ្ញុំបង្ហាត់បង្រៀនយូរហើយ។ ដូច្នេះ ក្រុម "ក"ហ្នឹង ក្រុមពិសេសហ្នឹងអាច ក្រុម"ក"ហ្នឹងអាចក្រុមហ្នឹងមួយទៀតផង។ អាហ្នឹងអត់ឆ្លងនេះ ទេ ឬក៏អាចឆ្លង មិត្តហ៊ី ដែរ ក៏ថាមិនដឹង ប៉ុន្តែត្រង់អាចូលក្រុមពិសេសហ្នឹងគឺខ្ញុំ តាមបញ្ហាមេពីលើមក។ មនុស្សណាដែលមេចាប់អារម្មណ៍ជាងគេ ខ្ញុំឱ្យទៅ មិត្តប៉ុន ភ្លាម ឬ មិត្តទុយ។ បើ មិត្តប៉ុន នៅជាប់ រវល់ខ្លាំងពេក មិត្តទុយ។ រួចអាចែកជាត្រជាក់ ក្ដៅអីហ្នឹងដំបូងទេ ព្រោះយុទ្ធវិធីសួររបស់ខ្ញុំមាន។ យុទ្ធវិធីទី១ត្រជាក់ យុទ្ធវិធីទី២ក្ដៅ យុទ្ធវិធីទី៣អង្កៀម។ នេះមានកត់នៅក្នុងកំណត់ហេតុដែល មិត្តផល្លី គេយកបទឧទ្ទេសនាមឯកសាររបស់ខ្ញុំទៅចងក្រង។ ហើយខ្ញុំសុំមិនអធិប្បាយទេ ថាម៉េចត្រជាក់ អាម៉េចក្ដៅ អាម៉េចអី។

[១៥:២៧:១២]

**ស៖** សូមអរគុណ។ អ្វីដែលខ្ញុំចង់ផ្ដោត និងចង់ស្វែងយល់ នោះគឺនៅពេលដែលអ្នកទោសត្រូវ បានចាត់ឱ្យទៅក្រុមណាសួរ។ តើអ្នកសួរនោះទទួលព័ត៌មានអំពីបទល្មើស ឬការចោទប្រកាន់អ្នកទោស ហ្នឹងដោយរបៀបណា? មានឯកសារជាប់បញ្ជូនអមទៅជាមួយដែរឬទេ? មានចម្លើយសារភាពដែល ដាក់ ឆ្លើយដាក់អ្នកទោសដែលបញ្ជូនទៅឱ្យអ្នកសួរចម្លើយនោះដែរឬទេ? តើអ្នកសួរចម្លើយនោះធ្វើយ៉ាង ម៉េច ទើបដឹងថាត្រូវសួរចំណុចខ្លឹមណាមួយពីអ្នកទោសនោះទៅ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា សំណួរនេះសំខាន់ណាស់។ ខ្ញុំសូមនិយាយថា ដោយហេតុនេះហើយបានជានៅ ស-២១ មានការអធិប្បាយអំពីប្រវត្តិរូបពីខាងដើមវែងឆ្ងាយមក។ ខ្ញុំ បានណែនាំ ធ្វើត្រជាក់ ស្វែងយល់ចំណុចខ្សោយ ចំណុចខ្លាំងរបស់ខ្មាំង ខ្ញុំប្រើពាក្យនេះទៅចុះ ព្រោះខ្ញុំ ធ្លាប់ប្រើពីពេលនោះមកហើយ។ ដោយឱ្យគេនិយាយឱ្យស្រួលអំពីប្រវត្តិរូប ឱ្យគេសុខចិត្តនិយាយឱ្យ ស្រួលអំពីប្រវត្តិរូបរបស់គេ ហើយយើងយកមកគិត។ ហើយដល់គិតហើយ សឹមយើងយកចំណុច ខ្សោយទៅសួរ។ ហើយខ្ញុំហាមមួយទៀត ដាច់ខាតកុំឱ្យខ្មាំងចាប់អារម្មណ៍ថាយើងចង់ឱ្យគេនិយាយពី រឿងអី។ តែខ្មាំងក្ដាប់បានយើង អ្នកសួររបស់យើងអត់ន័យទេ ត្រូវឱ្យគេនិយាយមក ហើយយើងចាំ ស្ដាប់ចំណុចខ្សោយ ហើយយើងផ្ចញ់យ៉ាងម៉េច អីយ៉ាងម៉េច។ នេះជាវិធីដែលខ្ញុំណែនាំ ដើម្បីឱ្យអ្នកនុ៎ង ចាប់អារម្មណ៍សួរខ្មាំង សួរអ្នកទោសត្រង់ណា។ សួរថាម៉េច អីយ៉ាងម៉េច ហើយគេប្រតិកម្មតបយ៉ាង ម៉េច នេះជាការណែនាំរបស់ខ្ញុំ។

ដូច្នេះហើយបានជាឯកសារនៅ ស-២១ ហូរហែពីរឿងប្រវត្តិដើម។ ហើយ ពួនួន នោះណែនាំខ្ញុំមិនដឹងប៉ុន្មានដងទេ អ្ហេ!មិត្តចូលចិត្តឲ្យវាសរសេរវែងម្ល៉េះ ប្រវត្តិរូបហ្នឹង។ និយាយអាបច្ចុប្បន្នហ្នឹងបានវាឆាប់។ ខ្ញុំអត់ហ៊ានតទេ ជាមួយនឹងខាងលើខ្ញុំអត់ហ៊ានតទេ ប៉ុន្តែគោលគំនិតខ្ញុំធ្វើការយ៉ាងម៉េច ខ្ញុំរក្សាទុកអាហ្នឹង។ ដូច្នេះឯកសារដែលចម្លើយខ្មាំងនៅស-២១ឃើញហើយ និយាយពីប្រវត្តិរូបដើមហ្នឹងហូរហែ ហ្នឹងជម្រាបឲ្យត្រង់ថាយុទ្ធវិធីហ្នឹងខ្ញុំប្រើ។

[១៥:៣០:៥៤]

**ស៖** នៅក្នុងករណីទាំងឡាយ ដែលអ្នកដែលត្រូវយកទៅសួរហ្នឹង ត្រូវបានអ្នកមុនឆ្លើយដាក់អ្នកទោសមុនឆ្លើយដាក់ តើអ្នកសួរចម្លើយហ្នឹងមានទទួលបានចម្លើយសារភាពអ្នកទោសមុនដែលឆ្លើយដាក់អ្នកទោសដែលត្រូវយកទៅសួរនាពេលក្រោយដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលបានសោះ។ ខ្ញុំមិនដែលបានឲ្យចម្លើយអ្នកមុនទៅឲ្យអ្នកក្រោយសួរទេ អត់ អត់សោះ។ គឺមកដល់គេក្តាប់ពីប្រវត្តិរូប អើប្រហែលជាអាច មិត្តហ៊ា អីគេដឹងបន្តិចបន្តួច គេប្រាប់ថានែ អានេះវាអីចេះ សំខាន់អីចេះ អាច អាហ្នឹងអាចមែន ក៏ប៉ុន្តែថាឲ្យៗចម្លើយទាំងដុល គេឆ្លើយដាក់ អត់។

**ស៖** ប្រហែលជាសំណួរខ្ញុំសួរ គឺមិនច្បាស់។ ខ្ញុំមិនមែនសួរលោកថាតើលោកបង្ហាញចម្លើយសារភាពនោះទៅអ្នកទោសនោះទេ ខ្ញុំគ្រាន់តែចង់សួរថាតើចម្លើយសារភាព<>អ្នកមុននោះមានផ្តល់ជូនទៅឲ្យអ្នកសួរចម្លើយដែរឬទេ?

**ឆ៖** ខ្ញុំនិយាយខ្ញុំហ្នឹងក្នុងន័យជាស-២១ អ្នកប្រតិបត្តិការការងារទាំងអស់នៅស-២១ហ្នឹង គឺអត់ផ្តល់ចម្លើយអ្នកមុនឲ្យអ្នកក្រោយដឹងទេ គេឆ្លើយដាក់ក៏ដោយ។ ខ្ញុំនិយាយពាក្យ “ខ្ញុំ” មួយម៉ាត់ហ្នឹងគឺសំដៅឯនុ៎ង។ ខ្ញុំអត់មានបញ្ហា ហើយក៏មិនៗដែលឲ្យគេឲ្យ។ ទុកឲ្យគេស្វែងរកការពិតខ្លួនឯង សមត្ថភាពរបស់ខ្លួនឯងដែលគេកសាងដើម្បីឈ្នះឧបាយកលអ្នកឆ្លើយ។

[១៥:៣៣:៣៩]

**ស៖** ខ្ញុំនឹងសួរលោកត្រង់ចំណុចនេះនាពេលក្រោយ<> ដោយផ្អែកទៅលើឯកសារមួយចំនួនជាក់លាក់តែម្តង។ មុនពេលដែលខ្ញុំអានជូនលោកស្តាប់ តើចម្លើយសារភាពហ្នឹងនៅឯណា? តើមានបញ្ជូនមួយច្បាប់ទៅថ្នាក់លើរបស់លោក ឬក៏សំណៅចម្លើយសារភាពរបស់អ្នកទោសដែលបានសួរចម្លើយមុនៗនោះ ទុកនៅកន្លែងណាដែរនៅក្នុងស-២១នោះ?

**ឆ៖** អរគុណ។ ចម្លើយអ្នកទោស ខ្ញុំជូនទៅថ្នាក់លើច្រើន ចំនួនមិនទៀងទេ។ បើចម្លើយអ្នក

ទោសនោះប៉ះពាល់ភូមិភាគច្រើន ខ្ញុំជូនទៅតាមចំនួនភូមិភាគ។ ឧទាហរណ៍ មនុស្សម្នាក់ឆ្លើយប៉ះភូមិភាគបស្ចិមផង ប៉ះភូមិភាគឧត្តរផងខ្ញុំជូនពីរ និងបី មួយទុកឲ្យខាងលើទុកនៅក្នុងមន្ទីរមជ្ឈិមទៅ ហើយពីរទៀតទៅឧត្តរមួយ ទៅបស្ចិមមួយ ហើយខ្ញុំតម្កល់ជាឯកសារនៅ អាឯកសារផ្ដិតសរសេរកាបូននៅចុងក្រោយគេបំផុត តម្កល់នៅស-២១។ ហើយអាឯកសារតម្កល់នៅ ស-២១ ភាគច្រើន គឺទុកនៅផ្ទះខ្ញុំ។ រោងឡានផ្ទះខ្ញុំ អាផ្ទះផ្លូវមុនីវង្ស មាត់ផ្លូវមុនីវង្ស។

[១៥:៣៥:៣១]

**ស៖** តើលោកជាអ្នកចាត់ចែងទុកដាក់ឯកសារទាំងអស់នេះ ឬក៏លោកមានបុគ្គលិកណាម្នាក់ ស-២១ហ្នឹង ជាអ្នករៀបចំចាត់ចែងទុកដាក់ចម្លើយសារភាពនេះ?

**ឆ៖** ចម្លើយសារភាពនេះ នីរសារខ្ញុំ មិត្តឆេន ទុកដាក់ ហ្នឹងចំពោះចម្លើយខ្លាំងដែលសំខាន់។ ឯចំណែកផ្សេងទៀតនៅ មិត្តហ៊ី ទេ គេទុកដាក់។

**ស៖** បញ្ហាពីការចាត់ចែងអ្នកទោស<ទៅអង្គភាពណាមួយ>នោះ ខ្ញុំចង់យកសក្ខីកម្មរបស់ប្រាក់ ខន ដែលបានឆ្លើយនៅថ្ងៃទី២៧ មេសា ឆ្នាំ២០១៦ នៅក្នុងប្រតិចារឹកម៉ោងប្រហែលជា១០:៤១ព្រឹក គាត់បានឆ្លើយថា គាត់ស្ថិតនៅក្នុងក្រុមអង្កៀម និង ក្រុមឯកសារ។ គាត់បានឆ្លើយដូចតទៅទាក់ទងទៅនឹងដំណាក់កាលនៃការសួរចម្លើយ ដែលគេបានយកអ្នកទោសមកឲ្យក្រុមរបស់គាត់សួរចម្លើយ សូមដកស្រង់៖ "ក្រៅពីក្រុមអង្កៀម នៅមានក្រុមពីរទៀត គឺហៅថា ក្រុមត្រជាក់ និងក្រុមក្ដៅ។ <>អ្នកទោសដែល<ខ្ញុំ>សួរនៅពេលនោះ គឺភាគច្រើនគឺអ្នកដែលគេត្រូវបានធ្វើទារុណកម្មរួចមកហើយ។ អ៊ីចឹងគេបញ្ជូនមកឲ្យក្រុមខ្ញុំ ក្រុមអង្កៀម ដើម្បីឲ្យយើងអង្កៀមរកព័ត៌មាន។ <មានតែពីរបីករណីប៉ុណ្ណោះ ដែលអ្នកទោសមកដល់ថ្មីៗត្រូវបានគេបញ្ជូនទៅក្រុមខ្ញុំ។>" បញ្ចប់ការដកស្រង់។ តើហេតុផលអ្វីបានជាអ្នកទោសនោះ ដំបូងគឺថា ត្រូវបានសួរដោយក្រុមត្រជាក់ ឬក៏ក្រុមក្ដៅមុននឹងបញ្ជូនទៅឲ្យក្រុមអង្កៀម? តើមូលហេតុអីដែរ?

[១៥:៣៨:១៣]

**ឆ៖** នេះគ្រាន់តែជាគោលការណ៍ទេ។ ឯចំណែកការអនុវត្តជាក់ស្ដែង ក្រុមត្រជាក់គេដំណើរការ។ ក្រុមត្រជាក់ដូចខ្ញុំនិយាយអ៊ីចឹង មកដល់គេនាំឲ្យអ្នកទោសនិយាយអំពីប្រវត្តិរូប ហើយគេយកទៅគិតចំណុចខ្លាំង ចំណុចខ្សោយ ហើយគេទៅពិចារណា ឬក៏គេយកអ្នកទោសម្នាក់ទៀតមកសួរ។ ឯចំណែកអ្នកទោសមុនហ្នឹង គេយកទៅទុកសិន។ ឯចំណែក្រុមក្ដៅ ដល់កាលណាមនុស្សទ្រុំងសួរចម្លើយ

ទៅមិនបានផលនៅនេះ គេប្ដូរទៅក្រុមក្ដៅ។ ឧទាហរណ៍ ជូនអ៊ីខ្ញុំអ្នកប្ដូរ ដូចអ្នកទោសម្នាក់គាត់ជាសមាជិកសេធិការយោធា បុគ្គលទី៣នៅក្នុងសេនាធិការយោធាហ្នឹងឈ្មោះ សៀត ឆែ ហៅ ទុំ។ គាត់ជាសមាជិកមជ្ឈិមត្រៀមរបស់បក្សកុម្មុយនីស្ដកម្ពុជា។ ដល់ទៅមុនដំបូងឲ្យមិត្តប៉ុន សួរ សួរមិនចេញ សុនសេន ក៏នាំយុទ្ធវិធីណែនាំ ណែនាំយុទ្ធវិធីពីចម្ងាយមកតាមទូរស័ព្ទ ក៏នៅតែមិនចេញ ខ្ញុំឲ្យទៅមិត្តទុយសួរ។ ដល់មិត្តទុយ សួរប្រើយុទ្ធវិធីក្ដៅផ្ដេសផ្ដាស រហូតដល់និយាយថា សៀត ឆែ ហៅ ទុំ និយាយ ខ្ញុំអ៊ំ! មិត្តៗ រហូតដល់ បងទុំ គាត់ឆ្លើយថា គាត់បានខូចនឹងកូនគាត់។ ហើយដល់អ្នកបរទេសគេថា អ្នើស! បងទុំ ត្រូវបក្សកុម្មុយនីស្ដកម្ពុជាចាប់ ដោយសារគាត់ខូចជាមួយនឹងកូនគាត់ អត់ទេ! រឿងនេះគឺ បងទុំដោះសារ ដោយសារត្រូវឈឺខ្លាំងពេកជាមួយ មិត្តទុយ។ ដូច្នេះ ទុយ គេពិបាកបន្តិច។ ខ្ញុំលើកឡើងបញ្ហានេះ បន្តអំពីការអំមិញដែលលោកព្រះរាជអាជ្ញាសួរថា ត្រជាក់ ក្ដៅយ៉ាងម៉េច? បញ្ជូនទៅពេលណាអីពេលណា? ខ្ញុំសូមលើកឧទាហរណ៍ជាក់ស្ដែងហ្នឹងមួយ ជាចំពោះ។

[១៥:៤០:៤៤]

ឯចំណែកនេះ ពួកនេះគេទៅខ្លួនគេតែម្ដង ដូចយឹម សម្បត្តិ ហ្នឹង។ មិត្តហ៊ី គាត់សួរ យឹម សម្បត្តិទទួលស្គាល់ថា គាត់ជាអ្នកបោកគ្រាប់បែក ហើយគោលបំណងយ៉ាងម៉េច ខ្ញុំថតតាមខ្សែអាត់ ឲ្យមិត្តហ៊ី ថតតាមខ្សែអាត់ ចម្លងខ្សែអាត់នោះភ្លាមៗ បញ្ជូនទៅខាងលើ ព្រោះខាងលើត្រូវការប្រញាប់ដែរ។ រួចបានប្រគល់ទៅឲ្យគេអ្នកសួរផ្សេងទៀត។ ដូច្នេះវាបត់បែនទៅតាមសភាពជាក់ស្ដែង កុំឲ្យវាស្លាប់ក្រឡា។ ដូច្នេះតាម ខន នោះគាត់និយាយ អាហ្នឹងវាម៉្យាងហើយ ខន។ រឿងអង្កៀម រឿងអីមិនងាយទេមនុស្សច្រើនណាស់ កម្មាភិបាលសួរតិច រឿងអង្កៀមមិនងាយទេ។ ប៉ុន្ដែខ្ញុំសូមជូនឧទាហរណ៍មួយចុះអ្នកឆ្លើយខ្លះ សមត្ថភាពអ្នកសួរទាបជាងអ្នកឆ្លើយឆ្ងាយណាស់។ កុយ ធួន គាត់ជាសមាជិកមជ្ឈិមពេញសិទ្ធិ បុគ្គលទី៩ ក្នុងបក្សកុម្មុយនីស្ដកម្ពុជា។ ខាងលើណែនាំខ្ញុំ មិត្តឌុច ប្រយ័ត្នណាស់ មិត្តធ្លាប់គោរពវាមិត្តធ្លាប់គោរពគេ ឥឡូវមិត្តប្រយ័ត្ន។ ខ្ញុំគិតសព្វគិតគ្រប់ទាំងអស់។ ដល់គេនាំ បងកុយ ធួន មកឲ្យខាងស-២១ចាប់ ខ្ញុំពួននៅក្រោយវាំងននៗ គេចាប់គាត់ដាក់ខ្នោះគ្រឹប ខ្ញុំចេញមកបង្ហាញគាត់ បង្ហាញមុខខ្ញុំឲ្យគាត់ឃើញ គាត់ដាក់មុខ។ ខ្ញុំសួរ វ៉ៃគាត់ខាងសតិអារម្មណ៍ ខ្ញុំសួរថា បងម៉េចអ៊ីចឹង? ម៉េចដល់ថ្នាក់ហ្នឹង? គាត់ថា គ្មានអីទេ រឿងស្រីញីបន្តិចបន្តួច។ សមមិត្តមិនបាច់សួរខ្ញុំទេ គាត់ថាឲ្យខ្ញុំអ៊ីចឹង សមមិត្តមិនបាច់សួរខ្ញុំទេ ចាំខ្ញុំរាយការណ៍ជូនអង្គការ។ ខ្ញុំសើច ខ្ញុំទះគូទម៉ុាងអ៊ីចេះ។ ខ្ញុំថា បង! ប៉ុណ្ណេះហើយណ៎ា បងអត់មានសិទ្ធិទៅរាយការណ៍ផ្ទាល់ជូនអង្គការទេ មានតែបងរាយការណ៍ជូនអង្គការតាមរយៈ

ឯណេះ។ ដល់ទៅខ្ញុំឲ្យគេយកគាត់ទៅទុកក្នុងបន្ទប់ពិសេសមួយ ឲ្យអ្នកទៅយាមពិសេស។ អ្នកយាមពេលនុំង ប្រហែលជាមាន ប្រាក់ ខន ម្នាក់ បើតាមខ្ញុំចាំ។ ចាំតែមើលគាត់ កុំឲ្យគាត់ធ្វើអត្តឃាតកើត។

[១៥:៤៣:៣២]

ពេលដែលបង កុយ ធួន ទៅទុកនុំងហើយ ខ្ញុំទៅ ក្រោយកន្លះម៉ោងដែល ឬក៏មួយម៉ោង ខ្ញុំទៅ ខ្ញុំនិយាយថា បង! ខ្ញុំជាប្អូនរបស់បងណ៎ា។ បងថា ចង់រាយការណ៍ជូនអង្គការ ឥឡូវបងសរសេរទៅ រាយការណ៍ថាម៉េច អីយ៉ាងម៉េច ខ្ញុំជានីរសារនាំសំបុត្រទៅអង្គការ។ បងសរសេរហើយប៉ុន្មានសន្លឹក ខ្ញុំហៅនីរសារអង្គការមកទទួលយកទៅភ្លាម។ និយាយគ្នាសុខចិត្ត គាត់សរសេរ។ សរសេរបានប្រហែលមួយទំព័រ គាត់ហែកចោល កាច់ស្ទីឡូ កាច់វ៉ែនតា បោះកូនតុដែលខ្ញុំដាក់ឲ្យសរសេរហ្នឹង។ ខាងកងពិសេសគេនៅយាមនុំង គេតេមកខ្ញុំ គេថាបងទៀតហើយ ប្រតិកម្ម គាត់ប្រតិកម្ម ខ្ញុំថាទប់ឲ្យជាប់ណ៎ា កុំឲ្យគាត់ធ្វើអត្តឃាត។ ដល់បី -- ដល់ធ្វើប្រតិកម្មហើយ ប្រហែលកន្លះម៉ោង ឬមួយម៉ោងបានខ្ញុំទៅជួប ទៅជួបខ្ញុំអត់ប៉ានធ្វើអី ខ្ញុំញញឹមដាក់ ម៉េចបង? បងកុំលេងជាមួយនឹងខ្ញុំ បងធ្វើហ្នឹង ឲ្យខ្ញុំវ៉ៃឲ្យទាល់តែងាប់ ខ្ញុំអត់ឆោតទេណ៎ាបងណ៎ា។ ខ្ញុំអត់វ៉ៃបងឲ្យងាប់ដាច់ចម្លើយទេ ខ្ញុំទុកអ៊ីចឹង។ ឥឡូវបងសរសេរទៅ ប្អូនធានានាំសេចក្ដីសារភាពរបស់បងទៅជូនអង្គការ ប្អូនអត់មើល។ មែន! បើខ្ញុំមើល ខ្ញុំអត់ដឹងវិនិច្ឆ័យថាម៉េចទេរឿងនោះ ហួសៗការយល់ដឹងរបស់ខ្ញុំ។ ប្រហែលជាគាត់ប្រតិកម្មបីលើក។ ដល់ចុងក្រោយមកគាត់សុខចិត្តសរសេរ។ រួចទូរសព្ទ័ចេះតែមកហើយ ពីបង សុន សេន ម៉េចមិត្តឌុច? ម៉េចមិត្តឌុច? ខ្ញុំថានៅទេបង។ ដល់ចុងក្រោយ គាត់ថា ម៉េច? ខ្ញុំថាប្រហែលជាបានការហើយបង។ គាត់ អើស! ថតទៅថតអានេះ ចម្លើយសារភាពរបស់វាទៅ ហើយចាំខ្ញុំឲ្យ ផន ទៅយក។ ថតចង់តែមិនទាន់ហើយផង គេមកយក។ ដូច្នេះចម្លើយ កុយ ធួន ទាំងមូល ខ្ញុំអត់មានបានអានមួយគ្រាប់ទេ។

[១៥:៤៥:៤៥]

នេះជារបៀបសួរដែលយើងចេះដាក់ខ្លួនយើងឲ្យទាបជាងខ្មាំង នៅពេលណាដែលយើងទាប។ យកចំណុចខ្លាំងណាដែលយើងទៅគាបខ្មាំង នេះរបៀបសួរត្រជាក់ ហើយវាបានផលអ៊ីចឹង។ កុយ ធួន សរសេរចម្លើយសារភាពប្រហែលជាប្អូនដង។ សុន សេន ប្រាប់មកខ្ញុំថា មិត្តឌុចអ្នំា! ចម្លើយ អាឃួនពិតត្រឹមចម្លើយទី៣ទេ ក្រៅពីនោះលែងពិតហើយ។ ដូច្នេះនេះ ជាការសួរចម្លើយដែលខ្ញុំយល់ថា មានប្រយោជន៍ ត្រូវវាយតម្លៃរវាងយើង និងខ្មាំង និងអ្នកទោស ឲ្យបានច្បាស់លាស់។ ប៉ុន្តែអ្នកណាទៅរឿងរបៀបនុំងបានដូចខ្ញុំ។ ហ្នឹងខ្ញុំសូមជម្រាបអ៊ីចឹង។ ដូច្នេះហើយការសួរនោះ វាមានភ្លាត់ វាមានភ្លាំង

ហើយយុទ្ធវិធីគេចេះតែប្តូរហើយ ប្តូរទៅអ៊ីចេះ ប្តូរទៅអ៊ីចុះ ចម្លើយមិត្តខន ជូនអង្គការ ជូនតុលាការប្រហែលជាពិតកម្រិតណាទេ។ ហ្នឹងខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹងវិញ។

**ស៖** អ្នកទោសដំបូងដែលលោកបានលើកឈ្មោះយកមកនិយាយ ដែល ទុយ បានសួរចម្លើយដោយសារតែអ្នកទោសនេះមិនសហការ។ អ្នកទោសម្នាក់ដែលលោកថា មានឋានៈលេខ៣ នៅឯសេនាធិការហ្នឹង តើបុគ្គលម្នាក់នេះឈ្មោះ សៀត ឆែ ហៅ ទុំ ហ្នឹង ឬក៏យ៉ាងម៉េច? តើអ្នកទោសម្នាក់នេះ មែនឬ?

**ឆ៖** អរគុណ។ គឺហ្នឹងហើយ។

**ស៖** ខ្ញុំនឹងត្រឡប់មកសួរលោកអំពីបុគ្គលម្នាក់នេះ ពាក់ព័ន្ធទៅនឹងការសួរ ហើយនិងសួរនៅពេលក្រោយការដែលលោកសួរចម្លើយ កុយ ធួន។ ឥឡូវនេះ ខ្ញុំគ្រាន់តែសួរសំណួរជាទូទៅ ទាក់ទងទៅនឹងដំណើរការសួរចម្លើយរបស់ក្រុមសួរចម្លើយ។ នៅពេលដែលលោកនៅធ្វើជាប្រធានស-២១ តើអ្នកសួរចម្លើយនៅស-២១ ហ្នឹងមានទាំងអស់ប៉ុន្មាននាក់ដែរ?

[១៥:៤៨:០៧]

**ឆ៖** ខ្ញុំអត់ចាំទេ ខ្ញុំអត់ចាំទេ។ ហើយចម្លើយហ្នឹងគឺ -- ក្រុមសួរចម្លើយហ្នឹងមានវិវត្តន៍។ អ្នកដែលវ៉ៃអ្នកទោសងាប់ដាច់រឿង ក៏ត្រូវទទួលទោសខ្លួនឯងដែរ។ តាមខ្ញុំចាំ មានឈ្មោះម្នាក់ឈ្មោះ មិត្តហាក់ មិនដឹងស្អី ហាក់ ទេ។ ហើយក្រោយមក មានម្នាក់ទៀតឈ្មោះ មិត្តធូ វ៉ៃដាច់ចម្លើយ ហើយម្នាក់ទៀត ដែលខ្ញុំដកចេញមិនឲ្យសួរនោះ ដោយសារប្រព្រឹត្តបទឧក្រិដ្ឋទៅលើអ្នកគ្រូ។ ហើយក្រៅពីនោះ ខ្ញុំមិនចាំទេ។ ហើយដល់ក្រោយមកបានខ្ញុំពង្រីកជួរកម្មាភិបាលសួរចម្លើយនារី។ ដូច្នេះវិធីសួរ ហើយនិងក្រុមអ្នកសួរ វាវិវត្តន៍អ៊ីចឹង តាមសភាពការណ៍។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសុំការអនុញ្ញាតផ្តល់ឯកសារ E3/1170។ ជាពិសេសទំព័រដែលខ្ញុំត្រូវសួរសាក្សីហ្នឹងគឺខ្មែរ 00443015 – ខ្មែរ 00443015, អង់គ្លេស 00602543, បារាំង 00544894។ ខ្ញុំយល់ឃើញថា ការបកប្រែជាភាសាអង់គ្លេស និងខ្មែរគឺទំព័រទី១ <ឬនៅជាប់ទំព័រទី១>។ សុំការអនុញ្ញាតបង្ហាញឯកសារនេះទៅសាក្សី លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៥:៥០:១៨]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំបានផ្ដល់ទំព័រខ្លះចេញពីសៀវភៅកំណត់ត្រាទៅឲ្យលោកពិនិត្យមើល ជាពិសេសត្រង់ទំព័រទី១ ដែលជាបញ្ជីរបស់អ្នកសួរចម្លើយនៅស-២១ ដែលបែងចែកទៅជាបួនក្រុម និងបញ្ជីមួយទៀតដែលមានបញ្ជីអ្នកសួរចម្លើយសរុប៣១នាក់។ សំណួរដំបូង តើលោកនៅចាំអក្សរសរសេរដោយដៃ ដែលសរសេរនៅលើទំព័រផ្សេងៗក្នុងឯកសារដែលខ្ញុំផ្ដល់ទៅឲ្យលោកនេះ ជាសៀវភៅកត់ត្រាដោយដៃនេះ លោកចាំអក្សរនេះទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ លើកលែងតែទំព័រទី១ចេញ ដែលមានលេខ ERN 00443016។ ក្រៅពីនោះគឺអក្សរបង ម៉ម ណៃ ទាំងអស់។

**ស៖** នៅត្រង់ទំព័រទី១ លោកមើលមកចុងខាងស្ដាំ គែមទំព័រខាងស្ដាំដែលជាបញ្ជីអ្នកសួរចម្លើយ តើអក្សរនេះជាអក្សររបស់ ម៉ម ណៃ ឬក៏អក្សររបស់អ្នកផ្សេង?

**ឆ៖** អក្សរទំព័រដែលលេខ E3/1170 ខ្ញុំថាអក្សរនេះមិនមែនអក្សរបង ម៉ម ណៃ ទេ។ អក្សរបង ម៉ម ណៃ ចាប់ពីទំព័រ ខ្ញុំមើល និយាយពីទំព័រERNវិញស្រួល។ អក្សរបង ម៉ម ណៃ ចាប់តាំងពី 0443016។

**ស៖** គឺទំព័រពាក់ព័ន្ធទៅនឹងអង្គការលេខ ហ្នឹងតាមលោកចាំនោះគឺថាជាអក្សរ ម៉ម ណៃ ហើយមែនទេ?

[១៥:៥៣:២៨]

**ឆ៖** ទំព័រ 00443016 អក្សរបង ម៉ម ណៃ។ ហ្នឹងហើយសុទ្ធតែអង្គការលេខទាំងអស់។

**ស៖** យើងខ្ញុំនឹងសួរមកលោកនៅ<ពេលក្រោយ។> សូមលោកមើលទំព័រ<ទី១>ដែលមានឈ្មោះ អ្នកសួរចម្លើយមកពីក្រុមសួរចម្លើយផ្សេងៗ។ នៅទីនេះគឺមានបញ្ជីមួយ ដែលបញ្ជីនេះថាមានអ្នកសួរចម្លើយសរុបទាំងអស់៣១នាក់ ក្នុងនោះពី២៧ទៅ៣១នាក់។ តើវាជួយរំឭកដល់ការចងចាំរបស់លោកទេ ដែលថានៅពេលមួយនោះ មានអ្នកសួរចម្លើយនៅស-២១ សរុបទាំងអស់ដល់ទៅ៣១នាក់ឯណោះ? ទី២ តើលោកនៅចាំឈ្មោះអ្នកសួរចម្លើយនៅលើបញ្ជីនេះដែរទេ?

**ឆ៖** ទេ។ នៅក្នុងទំព័រ 00443016 ជាៗខ្មែរ ហើយជាអង់គ្លេស ខ្ញុំមិនដឹងទំព័រប៉ុន្មានទេ។ ជា

ខ្មែរ 00443016។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារង បញ្ជាក់ម្តងទៀត ទំនងជាអាចច្រឡំ។ សូមៗបញ្ជាក់លេខ ERN នៅទំព័រដែលពាក់ព័ន្ធ ព្រោះគាត់រកមិនឃើញទេ។ ហើយតាមខ្មែរហ្នឹង ទំនងជា 00443015។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំគិតថា សាក្សីឥឡូវនេះ កំពុងតែពិនិត្យមើលទៅលើទំព័រទី២ ខ្មែរគឺ 00443016 ដែលវាស៊ីសង្វាក់គ្នាទៅនឹងអង់គ្លេស00602544 ដែលជាអង្គការលេខរបស់កងទ័ពភូមិភាគ<ពាយ័ព្យ>។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

[១៥:៥៦:៤៦]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** សុំទោស។ ខ្ញុំចាប់អារម្មណ៍ទៅលើទំព័រទី២មែន ដែលទំព័រ ERN ជាខ្មែរគឺ00443016 និយាយពីអង្គការលេខកងទ័ពភូមិភាគពាយ័ព្យ ពាយ័ព្យ មិនមែនឧត្តរទេ។ ឯចំណែកនិយាយអំពី ទំព័រជាខ្មែរ 00443015 មិនមែនអក្សរបង ម៉ម ណៃ ទេ ក៏ប៉ុន្តែនិយាយអំពីចំនួនអ្នកសួរចម្លើយនៅស-២១។ ត្រជាក់ប៉ុន្មាននាក់ ក្តៅប៉ុន្មាននាក់ អីប៉ុន្មាននាក់។ នេះគឺការចាត់ចែងរៀបចំជំនាន់នុ៎ង។ មិនដឹងជាខ្ញុំរៀបចំ ឬក៏មិត្តហ៊ី រៀបចំទេ។ ប៉ុន្តែការរៀបចំដំបូង គឺវាអ៊ីចឹង។ ឯចំនួនអ្នកសួរ ក៏មានវិវត្តន៍ថយចុះ ហើយនិងកើនឡើង។ ថយចុះ ដោយអ្នកខ្លះមានទោស ដក ឬក៏កម្ទេច ឬក៏ដកប្តូរតំណែង។ ហើយកើនឡើងឧទាហរណ៍រឿងមួយ ពេលដែលអ្នកសួរនេះអស់ទៅ ខ្ញុំឱ្យមិត្តហ៊ី ជ្រើសរើសពួកកងពិសេសបញ្ចូលទៅអ្នកសួរ។ ប្រាក់ ខន ហ្នឹងគឺដកពីកងពិសេស យកទៅសួរចម្លើយទេ មិនមែនដើមឡើយ គឺខ្ញុំកសាងមនុស្សនោះទេ។ ដូច្នេះខ្ញុំទទួលស្គាល់ថា បញ្ជីនេះ វាទោះបីមិនមែនរបស់បង ម៉ម ណៃ ក៏ដោយ ក៏អ្នកសួរចម្លើយដំបូង គឺមាន៣៣នាក់ ពិតមែន។ ហើយចែកជាពួកទី១ អ្នកណា, ពួកទី២ អ្នកណា, ពួកទី៣ អ្នកណា, ពួកទី៤ អ្នកណា គឺចែកអ៊ីចឹងមែន។ មានអ្នកសួរចម្លើយ គេមានគ្នាគេប៉ុន្មានហ្នឹងនាក់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសហព្រះរាជអាជ្ញារង។ បាទ សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើក

បន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី០៩ ខែមិថុនា ឆ្នាំ២០១៦ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្ម កាំង ហ្កេកអ៊ាវ ហៅ ឌុច សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោកសាក្សី។ សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សី នៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប និងលោក កាំង ហ្កេកអ៊ាវ ត្រឡប់ទៅកាន់មន្ទីរឃុំឃាំង អ.វ.ត.ក វិញចុះ។ ហើយដោយដោយបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទទាំងពីររូប និងសាក្សីត្រឡប់ចូលរួមសវនាការវិញនៅថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ហើយចំពោះសាក្សី កាំង ហ្កេកអ៊ាវ បង្គាប់ឲ្យនាំខ្លួនគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០០ នាទី)*